ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ គណៈប្រតិភូថៃអញ្ជើញទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ

◆ ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ តំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហម

◆ ខត្តរោងដំរី

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៧៨ ខែកុម្ភៈ ឆ្នាំ២០២៣

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៧៨ ខែកុម្ភៈ ឆ្នាំ២០២៣



កងកុមារនៅក្នុងរបបខ្មែរក្រហមៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ

◆ គណៈប្រតិភូថៃអញ្ជើញទស្សនកិច្ច ........... ១
◆ ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ តំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហម............. ៤

### ផ្នែកឯកសារ

◆ គីម ភិកតុន៖ អនុក្រុមជួសជុលវិទ្យុ ....... ១០

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ ឈឹម យុត៖ ខ្មែរក្រហមជម្លៀសខ្ញុំពីភូមិភាគបូព៌ាទៅកាន់តំបន់ដីខ្លាញ់នៅខេត្ត......... ១៣
◆ ញឹក ជិន៖ នីរសារ និងប្រធានកងក្នុង.... ១៥
◆ នុត សារ៉ុន៖ កងកុមារនៅក្នុងរបបខ្មែរ... ១៧
◆ ភិន ភាគ៖ កងស្ទូងដក .................... ១៩
◆ មាស ជុំ៖ ធ្វើការទាំងត្រដាបត្រដួស...... ២១
◆ វ៉ាន់ ស៊ិន់៖ កងចល័តក្នុងភូមិ............. ២៣
◆ វត្តពោធិ៍ដំរី................................២៥

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ ការស្រាវជ្រាវតំបន់ប្រវត្តិសាស្ត្រ ........ ២៧
◆ ដំណើរទស្សនកិច្ចសិក្សាស្ដីអំពី «សន្តិភាព និង សិទ្ធិមនុស្ស» មកកាន់តំបន់.......... ២៩
◆ វេទិកាប្រវត្តិសាស្ត្រ និងសុខភាព សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ........ ៣២
◆ វេទិកាថ្នាក់រៀនចុងសប្ដាហ៍ «ស្ដីអំពីការរស់នៅប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចស្មៀង.. ៣៦
◆ វេទិកាថ្នាក់រៀនស្ដីពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)៖... ៤០
◆ វេទិកាថ្នាក់រៀនស្ដីពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ (១៩៧៥-១៩៧៩) ...៤៤
◆ វេទិកាអប់រំសហគមន៍ស្ដីពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)... ៤៧
◆ វេទិកាសហគមន៍នៅក្នុងភូមិទួលប្រាសាទ ... ៥១
◆ វេទិកាអប់រំសហគមន៍ នៅវត្តខ្នារកកោះ ... ៥៣

### ផ្នែកស្រាវជ្រាវរកក្រួសារ

◆ ចាន់ នាង៖ ឪពុកខ្ញុំធ្វើបុណ្យឧទ្ទិសកុសលឲ្យខ្ញុំបីដង ព្រោះគាត់គិតថាខ្ញុំស្លាប់ហើយ..... ៥៩
◆ ទួលពិឃាដ ................................... ៦១

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** សុភ័ក្ត្រ ភាណា, គ្រីស្ដូហ្វ័រ ឌៀរីង, អ៊ីវ ធារី, ផេង ពង្សរ៉ាស៊ី, មេក វិន, ទូច វណ្ណេត,
លី ដេវីត, ឈុំ រ៉ា, រី ស៊ីថា, សួត វិចិត្រ, ហ៊ាន ពិសី និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ផាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# គណៈប្រតិភូថៃអញ្ជើញទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ

*សុភ័ក្ត្រ ភាណា*



ឯកឧត្តម បណ្ឌិត វិចាវ៉ាត់ អ៊ីសារ៉ាផាកឌី អនុរដ្ឋមន្ត្រីក្រសួងការបរទេសនៃព្រះរាជាណាចក្រថៃ អមដំណើរដោយឯកឧត្តម ឆឹតគាត អាដ្ឋករ ឯកអគ្គរាជទូតព្រះរាជាណាចក្រថៃប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូថៃ អញ្ជើញទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ ដោយមានការទទួលការវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឯកឧត្តម បណ្ឌិត វិចាវ៉ាត់ អ៊ីសារ៉ាផាកឌី អនុរដ្ឋមន្ត្រីក្រសួងការបរទេសនៃព្រះរាជាណាចក្រថៃ អមដំណើរដោយឯកឧត្តម ឆឹតគាត អាដ្ឋករ ឯកអគ្គរាជទូតព្រះរាជាណាចក្រថៃប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូថៃ អញ្ជើញទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ នាវេលាម៉ោង៣រសៀល ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣។

ទស្សនកិច្ចនេះប្រព្រឹត្តទៅក្នុងគោលបំណងសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្រកម្ពុជា ជាពិសេសប្រវត្តិសាស្ត្រខ្មែរក្រហម ដែលជាកិច្ចការងារស្នូលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងពិភាក្សាដោះដូរយោបល់ផ្នែកវប្បធម៌រវាងកម្ពុជានិងថៃ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលការវកិច្ចស្វាគមន៍ភ្ញៀវកិត្តិយសយ៉ាងកក់ក្តៅ។ លោកបានបង្ហាញដល់ប្រតិភូនូវបរិក្ខារ និងពិពណ៌នារៀបរាប់យ៉ាងលម្អិតអំពីកិច្ចការងារស្នូលរបស់

បណ្ណាល័យសម្តេចម៉ែ, មជ្ឈមណ្ឌលឯកសារកម្ពុជា និងសាខានៅតាមបណ្តាខេត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានចូលរួមចំណែកនិងបម្រើដល់ ការសិក្សាអប់រំ, ការចងចាំ, យុត្តិធម៌ និងការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា។

ចាប់តាំងពីចាប់បដិសន្ធិឡើងនៅក្នុងឆ្នាំ១៩៩៥ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបំពេញភារកិច្ចយ៉ាងមោះមុតក្នុងការប្រមែប្រមូលចងក្រងឯកសារស្តីពីរបបខ្មែរក្រហម ដើម្បីតម្កល់ការចងចាំជារួមសម្រាប់កម្ពុជា ហើយតាមរយៈការងារនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ជាឯកសាររាប់លានសន្លឹកដល់សាលាក្តីខ្មែរក្រហម។ គួររំឭកថា ព្រះរាជាណាចក្រថៃក៏បានគាំទ្រដល់ដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម តាមរយៈការផ្តល់ជំនួយសប្បុរសដល់សាលាក្តីខ្មែរក្រហម។

ស្របគ្នានេះដែរ ភាគីថៃ គឺលោកស្រី នូសាវ៉ា ថៃថាវ៉ាត់ អ្នកយកព័ត៌មាននៅការសែតបាងកកប៉ុស្តិ៍ ធ្លាប់បានចូលរួមចំណែកជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងការបង្កើតជាសៀវភៅមួយមានឈ្មោះថា "ផ្ទះបាយខ្មែរ" ឬ "The Cuisine of Cambodia" ដែលគឺជាសៀវភៅគ្រឿងផ្សំម្ហូបដំបូងបំផុតសម្រាប់មុខម្ហូបខ្មែរក្រោយពីរបបខ្មែរក្រហមបានដួលរលំទៅនៅឆ្នាំ១៩៧៩។ សៀវភៅនេះបានស្តារឡើងវិញនូវការចងចាំដ៏ស្រស់ត្រកាលអំពីមុខម្ហូបខ្មែរ ដែលប្រជាជនខ្មែរបានបរិភោគក្នុងយុគសម័យរុងរឿង នៅមុនពេលធ្លាក់ចូលទៅក្នុងភ្លក់ភ្លើងសង្រ្គាម។ អមមកជាមួយនឹងអារម្ភកថា ដែលជាព្រះរាជចំណារដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ សៀវភៅមុខម្ហូបដែលជាស្នាដៃរួមគ្នារវាងអ្នកសិក្សាស្រាវជ្រាវជនជាតិខ្មែរនិងជនជាតិថៃនេះ បានបណ្តុះនូវស្មារតីយោគយល់ និងរឹតចំណងមិត្តភាពរវាងកម្ពុជានិងថៃមួយកម្រិតទៀត។



ឯកឧត្តម បណ្ឌិត វិចាវ៉ាត់ អ៊ីសារ៉ាផាកឌី អនុរដ្ឋមន្ត្រីក្រសួងការបរទេសនៃព្រះរាជាណាចក្រថៃ អមដំណើរដោយ ឯកឧត្តម ឆិតតាត អាដ្ឋករ ឯកអគ្គរាជទូតព្រះរាជាណាចក្រថៃប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូថៃ អញ្ជើញទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ ដោយមានការទទួលការស្វាគមន៍យ៉ាងកក់ក្តៅ ពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងឱកាសទស្សនកិច្ចនេះ លោក ឆាំង យុ បានបង្ហាញសៀវភៅមុខម្ហូបខាងលើនិងរៀបរាប់យ៉ាងលម្អិតអំពីគោលបំណងនៃការរៀបរៀងសៀវភៅនេះឡើង។ លោកព្រមទាំងបានពិពណ៌នារៀបរាប់អំពីគម្រោងវិទ្យាស្ថានស្លឹករឹត ដែលជាទីតាំងអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជូនដល់ភ្ញៀវកិត្តិយស។

ទន្ទឹមនឹងនេះ លោកក៏បានលើកយកឯកសារកម្រមួយចំនួននៅក្នុងសមុច្ច័យឯកសារកម្រនានារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បង្ហាញជូនភ្ញៀវកិត្តិយស។ គណៈប្រតិភូ ក៏បានទស្សនាវីដេអូឯកសារ, បណ្ណសារសោតទស្សន៍, ឯកសារប្រភេទក្រដាស, ឯកសាររូបថត និងបរិក្ខារផ្ទុកឯកសារជាទម្រង់ឌីជីថលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានដាក់តម្កល់នៅបណ្ណាល័យសម្តេចម៉ែថែមទៀតផង។



ជាកិច្ចបញ្ចប់ លោក ឆាំង យុ បានរៀបចំកិច្ចពិភាក្សាដោះដូរយោបល់ ដើម្បីផ្តល់ឱកាសជូនគណៈប្រតិភូចែករំលែកការយល់ឃើញ និងចោទជាសំណួរផ្សេងៗ។ ប្រតិភូកិត្តិយស បានបង្ហាញនូវចំណាប់អារម្មណ៍យ៉ាងជ្រាលជ្រៅចំពោះការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងថ្លែងអំណរគុណចំពោះការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីបណ្ណាល័យសម្តេចម៉ែនារីសៀលនេះ។



ឯកឧត្តម បណ្ឌិត វិចាវ៉ាត់ អ៊ីសារ៉ាដាកឌី អនុរដ្ឋមន្ត្រីក្រសួងការបរទេសនៃព្រះរាជាណាចក្រថៃ អមដំណើរដោយ ឯកឧត្តម ឆឹតគាត អាដ្ឋករ ឯកអគ្គរាជទូតព្រះរាជាណាចក្រថៃប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូថៃអញ្ជើញទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ ដោយមានការទទួលការវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖
## តំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហម

*គ្រីស្ទហ្វ័រ ឌៀរីង*



ប្រជាពលរដ្ឋចំនួន២៣នាក់ គឺមានស្រី២០នាក់និងប្រុស៣នាក់ ក្នុងចំណោមប្រជាជនសរុបប្រមាណ១០៧ គ្រួសារ នៃភូមិយាង ខាងត្បូង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មកចូលរួមវេទិកា «លើកកំពស់សិទ្ធិស្ត្រី» រៀបចំដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បេសកកម្មមួយក្នុងចំណោមបេសកកម្មជាច្រើនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្តោតលើការលើកកំពស់ការអប់រំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា។ គម្រោងស្តីពីការអប់រំពីអំពើប្រល័យពូជសាសន៍បានក្លាយជាសកម្មភាពចម្បងមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ គម្រោងនេះត្រូវបានបង្កើតឡើងដើម្បីជំរុញឲ្យមានការជាសះស្បើយ យុត្តិធម៌ ការផ្សះផ្សា និងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា។ សៀវភៅសិក្សាគោលមួយសម្រាប់គម្រោងនេះមានចំណងជើងថា **ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)**។ សៀវភៅសិក្សានេះ និងអត្ថបទពាក់ព័ន្ធដទៃទៀតមានដូចជា សៀវភៅប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង បានក្លាយជាអត្ថបទគន្លឹះសម្រាប់កម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នេះដែរ។

សៀវភៅសិក្សា ***ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង*** មានគោលបំណងតភ្ជាប់ប្រវត្តិសាស្ត្រ «មុនពេល» និង«ក្រោយពេល» របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដើម្បីបង្ហាញទស្សនវិស័យទូលំទូលាយ ស្តីពីព្រឹត្តិការណ៍ដែលបណ្តាលឲ្យកើតមាន

របបខ្មែរក្រហម ព្រមទាំងប្រវត្តិសាស្ត្រដែលបានកើតឡើងបន្តបន្ទាប់មកទៀត តាមរយៈការផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើរយៈកាលក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារប្រវត្តិសាស្ត្រនេះមានទំនាក់ទំនងជាមួយសហគមន៍អន្លង់វែង។

អន្លង់វែងគ្រាន់តែជាភូមិឋានដ៏ស្ងាត់ជ្រងំដែលមានខ្លឹមសារតិចតួចណាស់ផ្នែកប្រវត្តិសាស្ត្រ រហូតដល់ឆ្នាំ១៩៧៩។ បន្ទាប់ពីឆ្នាំ១៩៧៩ និងជាពិសេសបន្ទាប់ពីឆ្នាំ១៩៨៩ ដែលនៅពេលនោះកងទ័ពវៀតណាមបានដកចេញពីប្រទេសកម្ពុជា ភូមិសាស្ត្រទាំងឡាយនៅជុំវិញអន្លង់វែងបានចាប់ផ្តើមស្គាល់ថាជាតំបន់តស៊ូសំខាន់មួយរបស់ចលនាខ្មែរក្រហម។ សហគមន៍នេះមានទីតាំងស្ថិតនៅកៀកនឹងជួរភ្នំដងរែក និងបណ្តោយព្រំដែនកម្ពុជាថៃ ដែលជាមូលហេតុសំខាន់សម្រាប់ការសម្រេចចិត្តរបស់ខ្មែរក្រហមក្នុងការបង្កើតមូលដ្ឋានយោធានៅក្នុងតំបន់នេះ។ អន្លង់វែងគឺជាតំបន់តស៊ូចុងក្រោយនៃចលនានេះ ហើយបានក្លាយទៅជាទីតាំងសំខាន់មួយរហូតដល់ថ្ងៃចុងក្រោយនៃចលនាខ្មែរក្រហម។

ខ្មែរក្រហមគឺជាឈ្មោះដែលព្រះអង្គម្ចាស់ សីហនុ បានដាក់ឲ្យក្រុមកុម្មុយនីស្តនៅកម្ពុជា។ បក្សកុម្មុយនីស្តកម្ពុជាបានព្យាយាមអនុវត្តបដិវត្តន៍សង្គមនិយមបែបឆាប់រហ័ស នៅក្នុងប្រទេសកម្ពុជា តាមរយៈកម្មវិធីកំណែទម្រង់បែបលទ្ធិម៉ៅ និងម៉ាក្សលេនីន។ នៅពេលខ្លួនឡើងកាន់អំណាចនៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានរៀបចំសង្គមឡើងវិញនៅលើគ្រប់វិស័យទាំងអស់ ដោយចាប់ផ្តើមពីការជម្លៀសប្រជាជនចេញពីទីប្រជុំជន។

នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនភាគច្រើនត្រូវបានបណ្តេញដោយបង្ខំចេញពីផ្ទះសម្បែងរបស់ខ្លួនទៅកាន់តំបន់ដាច់ស្រយាលនៅតាមទីជនបទ។ គោលនយោបាយនៃការជម្លៀសប្រជាជនពីកន្លែងមួយទៅកន្លែងមួយទៀត (ការជម្លៀសដោយបង្ខំ) បានបង្កឲ្យមានការឈឺចាប់ និងប៉ះពាល់យ៉ាងខ្លាំងលើប្រជាជននិងសហគមន៍។ ក្នុងរយៈពេល ៤៥ខែ របបខ្មែរក្រហមបានធ្វើការជម្លៀសដោយបង្ខំជាច្រើនដងរវាងតំបន់និងតំបន់ផ្សេងទៀត។

ក្រៅពីនេះ លុយ ទីផ្សារសេរី និងទ្រព្យឯកជនត្រូវបានហាមឃាត់។ ការគោរពប្រតិបត្តិសាសនា និងវប្បធម៌ក៏ត្រូវបានហាមប្រាម ហើយសាលាសាធារណៈ វត្តអារាម វិហារអ៊ីស្លាម វិហារសាសនាគ្រីស្ត និងហាងលក់ទំនិញត្រូវបានបិទ ឬប្រែក្លាយទៅជាមន្ទីរឃុំឃាំង ជំរំកែប្រែឡើងវិញ ឬគោលដៅផ្សេងៗរបស់របបនោះ។ មិនមានសេវាកម្មដឹកជញ្ជូនសាធារណៈ ឬឯកជនឡើយ ហើយសកម្មភាពកម្សាន្តផ្សេងៗត្រូវបានហាមឃាត់យ៉ាងតឹងរឹង។ ប្រជាជនត្រូវបានដកហូតនូវសិទ្ធិមនុស្សជាមូលដ្ឋានរបស់ខ្លួន ហើយមិនអនុញ្ញាតឲ្យចេញពីប្រទេសឡើយ។ ក្រុមគ្រួសារត្រូវបានបំបែកចេញពីគ្នា ជំរំការងារពលកម្មត្រូវបានបង្កើតឡើង ហើយសង្គមធ្វើឲ្យក្លាយទៅជាសមូហភាព។ ខ្មែរក្រហមជឿថា តាមរយៈកម្មវិធីតាមបែបកែប្រែទាំងស្រុងនេះ ខ្មែរក្រហមអាចមានលទ្ធភាពធ្វើឲ្យមានទិន្នផលកសិកម្មទទួលបានច្រើនសម្បូរបែប ហើយជឿថា អាចសម្រេចទៅបានទៀតផង។

រឿងរ៉ាវផ្ទុយស្រឡះបានកើតឡើងខណៈពេលដែលប្រជាជនជាច្រើនបានស្លាប់ដោយសារគ្រោះទុរភិក្ស អត់ឃ្លាន អស់កម្លាំង ឬការកើតមានជំងឺ។ ក្រៅពីនេះដើម្បីការពារបក្សពីសត្រូវខាងក្នុង និងសត្រូវខាងក្រៅ ហើយដើម្បីដោះស្រាយភាពបរាជ័យនៃគោលនយោបាយកែប្រែទាំងស្រុងរបស់ខ្លួន ខ្មែរក្រហមបានបង្កើតនូវកម្មវិធីសន្តិសុខដ៏រឹងមាំ ដែលកំណត់មុខសញ្ញាមនុស្សទាំងឡាយណាដែលជាប់ពាក់ព័ន្ធទៅនឹងរបបមុន។ បញ្ញវន្ត អ្នកមាន ព្រមទាំងអ្នកទាំងឡាយណាដែលខ្មែរក្រហមសង្ស័យ។ ប្រជាជនត្រូវបានចាប់ខ្លួន ហើយជារឿយៗត្រូវបានសម្លាប់ ឬត្រូវបានអស់កម្លាំងល្ហិតល្ហៃស្លាប់នៅក្នុងមន្ទីរសន្តិសុខ ឬជំរំកែប្រែ ដែលអ្នកទោសទាំងអស់នោះបានទទួលរង ហើយបានស្លាប់។ ខ្មែរក្រហមមិនបានស្ទាក់ស្ទើរក្នុងការប្រើប្រាស់ទម្រង់ធ្វើទារុណកម្ម

ដ៏ឃោរឃៅបំផុតដើម្បីធ្វើឲ្យមានភាពអាម៉ាស់ បំផ្លិចបំផ្លាញ ធ្វើឲ្យលែងមានភាពជាមនុស្ស និងកម្ទេចអ្នកទាំង ឡាយណាដែលសង្ស័យថាជាខ្មាំង។ របបនេះក៏មិនស្ទាក់ស្ទើរក្នុងការអនុវត្តយុទ្ធនាការឃោរឃៅទៅលើជនរងគ្រោះគ្រប់ប្រភេទ។ ស្ត្រី កុមារ និងសមាជិកដ៏ស្មោះស្ម័គ្ររបស់របបនេះក៏ទទួលរងនូវអំពើទារុណកម្ម និងការកាប់សម្លាប់ដែរ។ ក្រុមជនជាតិភាគតិចខាងសាសនា និងជាតិពន្ធុ ត្រូវបានទទួលរងគ្រោះ ហើយរបបខ្មែរក្រហមមានការផ្ដោតការយកចិត្តទុកដាក់ជាពិសេសទៅលើអ្នកណាដែលមានប្រវត្តិរូបជាវៀតណាម ឬ(មិនមែនជា ខ្មែរ)។

អន្លង់វែងត្រូវបានបង្កើតឡើងតាំងពីយូរអង្វែងណាស់មកហើយ មុនពេលដែលតំបន់នេះក្លាយទៅជាតំបន់កាន់កាប់ចុងក្រោយដ៏ល្បីល្បាញរបស់ចលនាកុម្មុយនីស្តខ្មែរក្រហម។ នៅឆ្នាំ១៩០៧ តំបន់អន្លង់វែងត្រូវបានទទួលស្គាល់ដោយអ្នកគូរផែនទីជនជាតិបារាំង នៅពេលដែលអ្នកគូរផែនទីបង្កើតខ្សែរបន្ទាត់ព្រំដែនកម្ពុជា ជាមួយនឹងប្រទេសជិតខាងភាគខាងជើង។ ដូចសហគមន៍ផ្សេងៗទៀត ដែលត្រូវបានបង្កើតឡើងនៅតាមបណ្ដោយព្រំដែនខាងទឹកដីថៃដែរ តំបន់អន្លង់វែងមានជនជាតិខ្មែររស់នៅ ដែលបានចំណាកស្រុកមកពីភាគខាងត្បូងនៃទឹកដីសៀម ដែលបច្ចុប្បន្នស្ថិតនៅក្នុង ខេត្តស៊ីសាកេត របស់ប្រទេសថៃ។ នៅចន្លោះឆ្នាំ១៩៤១ដល់ឆ្នាំ១៩៤៦ អន្លង់វែងបានដាក់បញ្ចូលទៅក្នុងខេត្ត ប្រែកភីប៊ុនសង់ក្រាម របស់ថៃ។ ថៃ បានគ្រប់គ្រងទៅលើអ្វីដែលធ្លាប់ជាខេត្តសៀមរាប និងខេត្តបាត់ដំបង របស់ខ្មែរ រហូតដល់ឆ្នាំ១៩៤៦ នៅពេលដែលបារាំង និងថៃ ចុះកិច្ចព្រមព្រៀងលើសន្ធិសញ្ញាព្រំដែន ដែលបានប្រគល់ខេត្តទាំងពីរមកឲ្យកម្ពុជាវិញ។ ចាប់ពីឆ្នាំ១៩៤៦ តំបន់នេះបានក្លាយទៅជាផ្នែកមួយនៃប្រទេសកម្ពុជា។

បារាំង បានបង្កើតប៉ុស្តិ៍ប៉ូលិសព្រំដែនតូចមួយនៅតាមបណ្ដោយព្រំដែននេះដើម្បីការពារ ការវាយប្រហារពីក្រុមចោរព្រៃ ដែលបង្កជាបញ្ហាខ្លាំងនៅក្នុងតំបន់នោះ។ នៅឆ្នាំក្រោយៗមកទៀត ភាពដាច់ស្រយាលរបស់អន្លង់វែងបានធ្វើឲ្យតំបន់នេះក្លាយទៅជាគោលដៅងាយស្រួលបំផុតសម្រាប់ការជ្រៀតចូល និងការកាន់កាប់របស់ខ្មែរក្រហម។ ខ្មែរក្រហមបានគ្រប់គ្រងអន្លង់វែងនៅក្នុងឆ្នាំ១៩៧០



ប្រជាពលរដ្ឋចំនួន២៣នាក់ គឺមានស្រី២០នាក់និងប្រុស៣នាក់ ក្នុងចំណោមប្រជាជនសរុបប្រមាណ១០៧ គ្រួសារ នៃភូមិយាងខាងត្បូង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មកចូលរួមវេទិកា «លើកកំពស់សិទ្ធិស្ត្រី» រៀបចំដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ហើយនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ប្រជាជនអន្លង់វែងក៏បានមើលឃើញពីការផ្លាស់ប្តូរទាំងស្រុង នៃរបៀបរបបរស់នៅតាមបែបប្រពៃណីរបស់ខ្លួន។ មនោគមន៍វិជ្ជាបដិវត្តន៍របស់ខ្មែរក្រហមបានតម្រូវឲ្យប្រជាជនបោះបង់ចោលនូវវប្បធម៌ និងការគោរពប្រតិបត្តិផ្សេងៗរបស់សហគមន៍។

ជីវភាពរស់នៅមានការលំបាកយ៉ាងខ្លាំងនៅក្រោមរបបខ្មែរក្រហម។ មិនមានអាហារហូបចុកគ្រប់គ្រាន់ទេ ហើយប្រជាជនរស់នៅក្នុងភាពភ័យខ្លាច អ៊ីក៏ដោយក៏អាចបន្តទៅជាការសង្ស័យដែរ។ ឧទាហរណ៍៖ អ្នករស់រានមានជីវិតម្នាក់បាននិយាយរំលឹកឡើងវិញថាធ្លាប់បានឃើញមនុស្សត្រូវបានដឹកតាមរទេះហើយបានទម្លាក់នៅកន្លែងសម្លាប់មួយកន្លែង ដោយគ្រាន់តែជនរងគ្រោះនោះចំណាយពេលយូរពេកនៅក្នុងបន្ទប់ទឹក ឬនៅកន្លែងការដ្ឋានការងារ។ ទីកន្លែងសម្លាប់នោះគឺ នៅក្នុងស្រុកក្រឡាញ់ ហើយត្រូវបានជឿថា នៅក្បែរឡពិឃាតភ្នំទ្រង់បាត្រ។ នៅទីតាំងនោះ មានការរាយការណ៍មកថាមនុស្សរាប់រយនាក់ ហើយប្រហែលជារាប់ពាន់នាក់ដែលត្រូវបានយកទៅសម្លាប់។ ក្នុងរយៈកាលនៃរបបខ្មែរក្រហម អន្លង់វែងត្រូវបានបោះបង់ចោលដោយសារតែមនុស្សនៅក្នុងសហគមន៍នេះត្រូវបានបង្ខំឲ្យផ្លាស់ប្តូរទីកន្លែងរស់នៅទៅកាន់តំបន់កសិកម្ម។ នៅចុងឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានវាយផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ហើយនៅត្រឹមខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ។ នៅពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅនៅដើមឆ្នាំ១៩៧៩ ប្រជាជនអន្លង់វែងបានត្រឡប់មកកាន់សហគមន៍របស់ខ្លួនវិញ ដែលបន្ទាប់មកប្រជាជនទាំងអស់នោះក៏ប្រឈមនឹងការលំបាកម្តងទៀតដោយត្រូវបានស្ថិតនៅចន្លោះកណ្តាលនៃកងកម្លាំងទ័ពដែលមានភាពស្មោះស្ម័គ្រនឹងកងកម្លាំងរដ្ឋាភិបាល និងកងកម្លាំងខ្មែរក្រហម។ កម្លាំងសេសសល់របស់ខ្មែរក្រហមក៏បានស្វែងរកទីជ្រកកោននៅតាមតំបន់ជួរភ្នំដងរែក ខណៈពេលដែលកងកម្លាំង នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងវៀតណាមបានដណ្តើមកាន់កាប់តំបន់អន្លង់វែងទាំងមូល។

ចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ កងទ័ពខ្មែរក្រហម និងប្រជាជនរស់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ឬនៅតាមជំរំភៀសខ្លួនផ្សេងៗនៅក្នុងទឹកដីថៃ។ មូលដ្ឋានរបស់កងទ័ពខ្មែរក្រហមធំៗចំនួនពីរ ដែលមានសម្ព័ន្ធភាពជាមួយនឹងតំបន់អន្លង់វែង ត្រូវបានស្គាល់ថាជាភ្នំ១០០១ និងភ្នំ១០០៣។ ចំពោះប្រជាជនដែលរស់នៅតាមជួរភ្នំដងរែក ឬអន្លង់វែង គឺមានស្ថានភាពរស់នៅលំបាកយ៉ាងខ្លាំង។ ប្រជាជនទាំងអស់នោះបានពណ៌នាអំពីជីវិតរបស់ខ្លួនថាជា ការរស់នៅប្រកបដោយភាពភ័យខ្លាច និងគ្មានទីជម្រកច្បាស់លាស់។ ការប្រយុទ្ធគ្នារវាងកងកម្លាំងខ្មែរក្រហម និងកងកម្លាំងវៀតណាម បានកើតឡើងជាញឹកញាប់ ហើយដើម្បីការពារសហគមន៍របស់ខ្លួន ស្ត្រីនិងកុមារ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ត្រូវធ្វើការងារមួយចំនួនដូចជា បិតចម្រូង និងដឹកជញ្ជូនស្បៀង ឬគ្រឿងសព្វាវុធផ្សេងៗ ។

ដោយសារតែកងទ័ពវៀតណាមបានដកចេញនៅក្នុងឆ្នាំ១៩៨៩ ខ្មែរក្រហមបានបើកការវាយលុក និងធ្វើការគ្រប់គ្រងនូវតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា។ នៅចុងឆ្នាំ១៩៨៩ ខ្មែរក្រហមនៅភ្នំ១០០៣ ដែលស្ថិតនៅក្រោមការដឹកនាំរបស់មេបញ្ជាការកងទ័ពថ្នាក់កណ្តាលឈ្មោះ ឈិត ជឿន ឬហៅថា តាម៉ុក បានធ្វើការវាយលុកដណ្តើមកាន់កាប់អន្លង់វែង។ ខ្មែរក្រហមបានកាន់កាប់អន្លង់វែងនៅក្នុងខែធ្នូ ឆ្នាំ១៩៨៩ ហើយតាម៉ុក បានចាប់ផ្តើមប្រមែប្រមូលប្រជាជនជាច្រើន មកពីជំរំជនភៀសខ្លួនឲ្យមករស់នៅអន្លង់វែង។ នៅពេលដែលអន្លង់វែងចាប់ផ្តើមមានមនុស្សរស់នៅសារជាថ្មី ខ្មែរក្រហមក៏បានរៀបចំភូមិស្ថានឲ្យស្របទៅតាមរចនាសម្ព័ន្ធកងទ័ពនីមួយៗ។

សហគមន៍នេះបានពឹងផ្អែកយ៉ាងខ្លាំងទៅលើ

តាម៉ុក បើទោះបីជា តាម៉ុក ធ្លាប់មានកិត្តិនាមថាជាមនុស្សឃោរឃៅក៏ដោយ។ កងកម្លាំងរបស់ តាម៉ុក បានទទួលខុសត្រូវលើការសម្លាប់ប្រជាជន និងកម្មាភិបាលខ្មែរក្រហមនៅក្នុងភូមិភាគបូព៌ា កាលពីជំនាន់របបកម្ពុជាប្រជាធិបតេយ្យ ហើយតាម៉ុកក៏ត្រូវបានស្គាល់ថា «តាម៉ុក៖ មេពេជ្ឈឃាដ»។ ទោះបីជាមានកិត្តិនាមបែបនេះក៏ដោយ តាម៉ុក ក៏ត្រូវបានស្គាល់ថាជាមនុស្សគួរឲ្យគោរពនៅក្នុងសហគមន៍នេះដែរ។ ភាគច្រើនតាម៉ុក បានចំណាយពេលជាមួយនឹងប្រជាជននៅតាមមូលដ្ឋាន ហើយគាត់បានអនុវត្តនូវគម្រោងសាងសង់ជាច្រើនដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍។

ដោយមានការគាំទ្រពីអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា (ហៅកាត់ថា អ៊ុនតាក់) រដ្ឋាភិបាលកម្ពុជាបានរៀបចំឲ្យមានការបោះឆ្នោតនៅក្នុងឆ្នាំ១៩៩៣។ ការបោះឆ្នោតនេះ ត្រូវបានខ្មែរក្រហមធ្វើពហិការមិនព្រមចូលរួម។ បន្ទាប់ពីការបោះឆ្នោតនេះបញ្ចប់ទៅ ជំនួយគាំទ្ររបស់បរទេសមកកាន់ខ្មែរក្រហម ក៏ត្រូវបានកាត់ផ្តាច់ទាំងស្រុង ហើយចលនាខ្មែរក្រហមក៏បានបាត់បង់កម្លាំងរបស់ខ្លួនអស់រយៈពេលជាច្រើនឆ្នាំ ដែលកម្រិតនៅត្រឹមតំបន់តូចមួយ។ សមាជិកជាន់ខ្ពស់មួយចំនួនរបស់ខ្មែរក្រហម (ប៉ុល ពត, សុន សេន, នួន ជា, ខៀវ សំផន និងតាម៉ុក) ចាប់ផ្តើមមានជម្លោះផ្ទៃក្នុង និងសង្ស័យថាមានការក្បត់គ្នាទៅវិញទៅមក។ នៅល្ងាចថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៧ ប៉ុល ពត បានបញ្ជូនមេបញ្ជាការរបស់គាត់ឈ្មោះ សារឿន ឲ្យទៅសម្លាប់ សុន សេន និងប្រពន្ធរបស់គាត់ ដែលរស់នៅក្នុងផ្ទះមួយដែលកសាងដោយតាម៉ុក។ នៅក្នុងអំឡុងម៉ោងប្រហែល១១យប់ សារឿន បានដឹកនាំទាហានមួយក្រុមដោយមានគ្នាប្រមាណជា ២០-៣០នាក់ ធ្វើដំណើរទៅកាន់ផ្ទះ សុន សេន។ ក្រុមទាហានទាំងនោះបានបាញ់សម្លាប់ សុន សេន ព្រមទាំងក្រុមគ្រួសារទាំងមូល។ នៅពេលទទួលបានព័ត៌មានអំពីការស្លាប់របស់ សុន សេន តាម៉ុក បានបញ្ជាឲ្យប្រមូលកម្លាំង ហើយជម្លោះ៥ថ្ងៃក៏បានកើតឡើងរវាងកងកម្លាំងដែលស្មោះស្ម័គ្រជាមួយនឹងតាម៉ុក និងកងកម្លាំងដែលស្មោះស្ម័គ្រជាមួយនឹងប៉ុល ពត។ បន្ទាប់ពីការវាយប្រយុទ្ធអស់រយៈពេល ៥ថ្ងៃ កងកម្លាំងរបស់ ប៉ុល ពត បានសុំចុះចាញ់ ហើយប៉ុល ពត និងមេបញ្ជាការកងទ័ពរបស់ខ្លួនព្រមទាំងមេដឹកនាំផ្សេងៗទៀតក៏ត្រូវបានចាប់ខ្លួន។ មេបញ្ជាការកងទ័ពមួយចំនួនត្រូវបានដាក់ក្នុងទ្រុងដែកចំនួនពីរ ដែលបច្ចុប្បន្នយើងអាចឃើញទ្រុងដែកនេះនៅផ្ទះក្បែរមាត់បឹងរបស់តាម៉ុក។ ប៉ុល ពត ក៏ត្រូវបានថ្កោលទោសនៅចំពោះមុខតុលាការប្រជាជនដែលជាការរៀបចំឡើងដោយខ្មែរក្រហម។ តុលាការនេះមានទម្រង់បែបជាការសូត្រសុន្ទរកថា ដើម្បីថ្កោលទោស ប៉ុល ពត។ នៅទីបញ្ចប់ ប៉ុល ពត ត្រូវបានកាត់ទោសឲ្យជាប់ទោសអស់មួយជីវិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក។

នៅក្នុងអំឡុងពេលឈានទៅដល់ការបោះឆ្នោតជាតិ ដែលជាការរៀបចំដោយអង្គការសហប្រជាជាតិនៅកម្ពុជាកាលពីឆ្នាំ១៩៩៣ មេបញ្ជាការកងទ័ពខ្មែរក្រហមក៏បានសហការជាមួយនឹងមន្ត្រីរដ្ឋាភិបាលនៃរបបសាធារណៈរដ្ឋកម្ពុជា ឬរដ្ឋកម្ពុជា។ មេបញ្ជាការរបស់ខ្មែរក្រហម ទាំងអស់នេះបានបង្កើតនូវទំនាក់ទំនងល្អ និងសម្របសម្រួលឲ្យមានការចរចាដើម្បីធ្វើសមាហរណកម្មចុងក្រោយនៃកងកម្លាំងខ្មែរក្រហមនៅអន្លង់វែង។ ក្នុងការចរចានេះមានការព្រមព្រៀងគ្នា ដើម្បីផ្តាច់ខ្លួនចេញពីការគ្រប់គ្រងរបស់តាម៉ុក។ នៅពេលដែលការព្រមព្រៀងគ្នានេះបានលេចឮទៅដល់តាម៉ុក បានធ្វើឲ្យកើតមានការប្រយុទ្ធគ្នារវាងអ្នកដែលផ្តាច់ខ្លួន និងកម្លាំងដែលស្មោះស្ម័គ្រជាមួយតាម៉ុកនៅក្នុងខែមីនា ឆ្នាំ១៩៩៨។ ការប្រយុទ្ធគ្នានេះបានបន្តអស់រយៈពេលជាច្រើនខែ។ នៅក្នុងអំឡុងពេលនៃការប្រយុទ្ធគ្នានេះ ប៉ុល ពតដែលកំពុងមានសុខភាពទន់ខ្សោយ ក៏បានស្លាប់ដោយសារជំងឺគាំងបេះដូង។ ដោយសារតែកង្វះអុកស៊ីសែន និងថ្នាំពេទ្យ ទើបធ្វើឲ្យកងកម្លាំងតាម៉ុក

មិនអាចមើលថែទាំ ប៉ុល ពត បានឡើយ។ ក្នុងអំឡុងពេលនៃការដកថយរបស់កងទ័ព ប៉ុល ពត ក៏បានស្លាប់នៅលើគ្រែក្នុងថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ដោយមានប្រពន្ធវ័យក្មេង និងកូនស្រីនៅក្បែរគាត់។ ពីរថ្ងៃក្រោយមក សពរបស់ ប៉ុល ពត ត្រូវបានបូជានៅលើគ្រែ រួមជាមួយនឹងសំបកកង់ ឡាន។

បន្តិចម្តងៗក្រុមទាហានរបស់ តាម៉ុក បានចុះចូល ព្រោះកងកម្លាំងរបស់តាម៉ុកកាន់តែមានភាពទន់ខ្សោយ និងបាត់បង់ស្មារតីក្នុងការប្រយុទ្ធ។ នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៩៨ ភាគីទាំងសងខាងបានឈានដល់ការព្រមព្រៀងគ្នាធ្វើសមាហរណកម្មចុងក្រោយបង្អស់នៃកងកម្លាំងខ្មែរក្រហម និងធ្វើការរំលាយអង្គភាពទ័ពខ្មែរក្រហមទាំងអស់។ នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ ពិធីសមាហរណកម្មផ្លូវការត្រូវបានធ្វើឡើងនៅក្នុងស្រុកអន្លង់វែង។ ដំបូងឡើយ តាម៉ុក ត្រូវបានឃុំខ្លួននៅក្នុងផ្ទះ។ ប៉ុន្តែក្រោយមក តាម៉ុកក៏ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់គុកលាយោធានៅក្នុងទីក្រុងភ្នំពេញ ដើម្បីរង់ចាំការកាត់ទោស។ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ តាម៉ុក ក៏បានស្លាប់នៅក្នុងអាយុ៨០ឆ្នាំ។ សពរបស់គាត់ត្រូវបានបញ្ជូនត្រឡប់ទៅកាន់អន្លង់វែងវិញ ហើយពិធីបុណ្យសពក៏បានធ្វើឡើងយ៉ាងអធិកអធម។ ចេតិយយ៉ាងធំរបស់តាម៉ុក ត្រូវបានកសាងឡើងនៅក្នុងវត្តស្រះឈូក។

ទីតាំងដែលត្រូវទស្សនកិច្ចនៅក្នុងស្រុកអន្លង់វែង ដោយមានការសហការពីក្រសួងទេសចរណ៍ សហគមន៍មូលដ្ឋាន និងមជ្ឈមណ្ឌលឯកសារកម្ពុជា បានកំណត់ទីតាំងចំនួន១៤ ដែលមានសារសំខាន់ផ្នែកប្រវត្តិសាស្ត្រ ឬបរិស្ថាន។ សម្រាប់ដំណើរទស្សនកិច្ចដែលមានរយៈពេលកន្លះថ្ងៃ ទេសចរទាំងឡាយត្រូវបានលើកទឹកចិត្តឲ្យធ្វើទស្សនកិច្ចទៅកាន់ទីតាំងមួយចំនួនដូចខាងក្រោម៖

- ផ្ទះតាម៉ុក ឬសារមន្ទីរតាម៉ុក និង
- ផ្ទះតាម៉ុក(ផ្ទះកណ្តាលរបស់តាម៉ុក នៅលើខ្នងភ្នំដងរែក) ហើយក៏ជាទីតាំងនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

ដោយរាប់បញ្ចូលទាំងទីតាំងផ្សេងៗទៀត៖ (ក). ទីតាំងបូជាសព សុន សេន និងគ្រួសារ (ខ). ទីតាំងបូជាសពប៉ុល ពត (គ). បឹងអន្លង់វែង និង(ឃ). ស្ពានតាម៉ុក។







ប្រជាពលរដ្ឋក្នុងសហគមន៍អន្លង់វែងចូលរួមវេទិកា «លើកកំពស់សិទ្ធិស្ត្រី» រៀបចំដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គីម ភិកគុន ៖ អនុក្រុមជួសជុលវិទ្យុមន្ទីរ ខ៦៦

ដារ៉ារដ្ឋ មេត្តា



កម្មាភិបាលខ្មែរក្រហមនៅតាមមន្ទីរៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ គីម ភិកគុន ភេទប្រុស អាយុ៣៥ឆ្នាំ (នៅក្នុងឆ្នាំ១៩៧៧)។ ខ្ញុំរៀបការរួចហើយ។ ខ្ញុំមានស្រុកកំណើតនៅភូមិក្រឡាញ់ ឃុំក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប។ នៅខែតុលា ឆ្នាំ១៩៥៦ ខ្ញុំរៀននៅថ្នាក់ទី៥ ហើយចូលជាសមាជិកអង្គការវិទ្យាល័យស្កុត (ក្រុមកាយរិទ្ធ?) ខេត្តសៀមរាប។ ដោយសារស្រឡាញ់ឯកសណ្ឋានស្កុតមានសម្លៀកបំពាក់ខោគគី កន្សែងរុំក ពណ៌ក្រហម-ខៀវ, ស្បែកជើងនិងស្រោមជើង។ ពេលនោះមានសាស្ត្រាចារ្យឈ្មោះ ព្រុំ នួនថុល គឺជាប្រធាន។ ក្នុងនាមជាសមាជិកស្កុតនៅវ័យក្មេង ខ្ញុំចាប់ផ្តើមទទួលការអប់រំមនោសញ្ចេតនាឲ្យស្រឡាញ់អាមេរិក តាមរយៈការផ្សាយ ទស្សនាវដ្តី និងរូបភាព។

នៅក្នុងឆ្នាំ១៩៥៩ ខ្ញុំត្រូវមករៀននៅវិទ្យាល័យដេកាត ក្រុងភ្នំពេញហើយ សាស្ត្រាចារ្យ ព្រុំ នួនថុល ក៏ផ្លាស់មកសាលាវិចិត្រសិល្បៈ ក្រុងភ្នំពេញដែរ។ មុនចូលរៀនរយៈពេល៤ទៅ៥ថ្ងៃសាស្ត្រាចារ្យ ព្រុំ នួនថុល ហៅខ្ញុំទៅជួបក្នុងការិយាល័យប្រាប់ថា៖ តួនាទីរបស់ខ្ញុំជាស្កុតគឺចប់ហើយ នឹងចាប់ពីពេលនេះតទៅ ខ្ញុំមានតួនាទីជា សេ-អ៊ី-អា។ គាត់ប្រាប់ខ្ញុំ នៅ

វិទ្យាល័យដេកាត មានសេ-អ៊ី-អា ចំនួន៤នាក់ដើម្បីរាយការណ៍ប្រាប់គាត់រួមមានៈ ជុំ សារ៉ាត់ គឺជានិស្សិតថ្នាក់បញ្ចប់ឆ្នាំ១៩៧៤វិស្វករនៅក្រសួងប្រៃសណីយ៍, ឈាង គឹមសួរ គឺជានិស្សិតថ្នាក់បញ្ចប់ហើយនៅឆ្នាំ១៩៧៤វិស្វករ នៅក្រសួងប្រៃសណីយ៍,ប៉ា ផេង និស្សិតថ្នាក់បញ្ចប់នៅក្នុងឆ្នាំ១៩៧៥ វិស្វករ នៅក្រុមហ៊ុនទំនប់ទឹកធំ និង លឿង យ៉ុណ្ណា និស្សិតថ្នាក់ទី១សាលាដេកាតនៅក្នុងឆ្នាំ១៩៧៥វិស្វករ ក្រសួងសាធារណការ។

នៅឆ្នាំ១៩៦១ ខ្ញុំត្រូវទៅរៀននៅប្រទេសបារាំង ហើយខ្ញុំនៅប៉ារីស បានរយៈពេល៣ទៅ៤ថ្ងៃ បារាំងបញ្ជូនខ្ញុំឲ្យទៅរៀននៅក្រុងរូអង់។ នៅខែកក្កដា ខ្ញុំមកប៉ារីស ដើម្បីរៀននៅសាលាទូរគមនាគមន៍។ នៅក្នុងឆ្នាំ១៩៦៥ ខ្ញុំចូលជាសមាជិក«សហភាពនិស្សិតខ្មែរ»ពេញលក្ខណៈ។ នៅខែសីហា ឆ្នាំ១៩៦៧ ខ្ញុំត្រឡប់មកដល់ប្រទេសកម្ពុជាវិញ ហើយខ្ញុំបានជួបឌី ផុន ធ្វើពេទ្យធ្មេញនៅផ្លូវមុន្នីវង្ស ។

នៅខែកញ្ញាឆ្នាំ១៩៧០ឌី ផុននាំខ្ញុំទៅខ្មែរក្រហមទៅខ្ទេសនាមឲ្យស្គាល់ ឈ្មោះ សៀង ប៉ោសែ គឺជានាយកសុរិយោដី ដែលមានឈ្មោះបដិវត្តន៍ នាគ ហើយនៅក្នុងឆ្នាំ១៩៧០មាននាទីភ្ជាប់បញ្ជូនក្រុង។ ខ្ញុំនៅខ្សែបងនាគ បានរយៈពេល៤ខែហើយ ខិតខំបំពេញភារកិច្ចដែល បងនាគ ប្រគល់ឲ្យដើម្បីឲ្យគាត់ទុកចិត្ត។ ភារកិច្ចចុងក្រោយ បងនាគ ប្រគល់ឲ្យខ្ញុំគឺធ្វើប្លង់មូលដ្ឋានអាកាសចរណ៍ពោធិ៍ចិនតុងចំនួន២ច្បាប់គឺមួយច្បាប់ប្រគល់ឲ្យ បងនាគ និងមួយច្បាប់ ប្រគល់ឲ្យឈ្មោះ សាម គឺជាប្រធានយោធាក្រុង។ នៅខែមករា ឆ្នាំ១៩៧១ ឈ្មោះ សាម ត្រូវប៉ូលិសក្រុងចាប់ខ្លួននិង សារភាពខ្ញុំគឺជាអ្នកធ្វើប្លង់។ ក្រោយមកមានប៉ូលិសពិសេស និងប៉េអឹម (PM) មួយក្រុមមកចាប់ខ្លួនខ្ញុំដល់ផ្ទះរួចបញ្ជូនខ្ញុំទៅគុលាការសឹក។ នៅចុងខែធ្នូគុលាការសឹក បានបញ្ជូនខ្ញុំមកគុកធំទីក្រុងភ្នំពេញ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំចេញពីគុកធំ រួចដើរតម្រង់ទៅផ្ទះគ្រួសារនៅម្តុំផ្លូវកម្ពុជាក្រោមហើយត្រូវអង្គការជម្លៀសទៅដល់ភូមិផ្តៅជុំ ឃុំផ្តៅជុំ ស្រុកដើមព្រៃ តំបន់៤១ ភូមិភាគឧត្តរនៅដើមខែឧសភា។ នៅពាក់កណ្តាលខែតុលា បងហាន និង បងដែក ទៅយកខ្ញុំពីសហករណ៍ផ្តៅជុំមកភ្នំពេញវិញ។ ខ្ញុំស្នាក់នៅរោងចក្រទឹក ស្ថិតនៅភូមិព្រែក។ នៅរោងចក្រទឹកបានរយៈពេល៤ទៅ៥ថ្ងៃ ខ្ញុំជួប បងព្រាប ហើយគាត់ហៅខ្ញុំមកជួបប្រាប់ថាខ្លួនគាត់គឺជាអ្នកឲ្យទៅយកខ្ញុំនៅសហករណ៍ផ្តៅជុំដោយសារទទួលការណែនាំពីអង្គការក្រុង(បងសុខ)។ ក្រោយមកខ្ញុំត្រូវទៅបំពេញតួនាទីជាអ្នកខ្ទេសនាម បច្ចេកទេសវិទ្យុនៅសាលវិទ្យុក្នុងផ្លូវដីហុក្តាល(បច្ចុប្បន្នឃ្លាំងវ១) ប្រហែលជារយៈពេល២ខែ។ បន្ទាប់ពីនេះខ្ញុំត្រូវមានភារកិច្ចទៅបំពេញការងារអចិន្ត្រៃយ៍នៅមន្ទីរវិទ្យុទាក់ទង សេនាធិការគឺជាកន្លែងមានសារសំខាន់ខ្លាំងណាស់ហើយ លាក់ការណ៍ក៏ខ្លាំងណាស់ដែរ។ រហូតដល់ខែធ្នូ ខ្ញុំនៅណែនាំបច្ចេកទេសវិទ្យុក្នុងសាលវិទ្យុដីហុក្តាល ប៉ុន្តែមិនហ៊ានធ្វើសកម្មភាពអ្វីជាសម្ងាត់ឡើយ។ ពេលនោះមានបងហាន គឺជាប្រធានសាល។ បងព្រាប ដឹកខ្ញុំនិងមិត្តពីរនាក់ ឈ្មោះ គង់ នៅកងពល៨០១ និង អៀង នៅកងពល៧០៣មកប្រគល់ឲ្យមន្ទីរវ៦៦ដែលមានបងតែម ទទួលខុសត្រូវ និងមានបងណាតគ្រប់គ្រងផ្ទាល់។ នៅមន្ទីរ វ៦៦ ខ្ញុំនិងមិត្តចំនួន១៥នាក់ ត្រូវទៅរៀនបច្ចេកទេសវិទ្យុពីអ្នកបច្ចេកទេសចិនជារៀងរាល់ថ្ងៃ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៦ ខ្ញុំទទួលការអនុញ្ញាតទៅលេងគ្រួសារ នៅសហករណ៍សេនាធិការជិតរោងចក្រកែវ ចំការដូងហើយខ្ញុំជួបបងព្រាប នៅទីនោះ។ បងព្រាប មកកាន់នាទីថ្មី គឺជាប្រធានសហករណ៍សេនាធិការ រយៈពេល១ខែមកហើយ។ បងព្រាប សួរនាំអំពីការងាររបស់ខ្ញុំហើយខ្ញុំរាយការណ៍ឲ្យ បងព្រាប តាមដំណើរ ជាពិសេសនៅក្រុមស្ថានីយវិទ្យុ។ ខ្ញុំចាត់តាំងរួចជាស្រេចមាន ស្ថានីយវិទ្យុផ្សាយ១នៅទួលស្វាយព្រៃនិងស្ថានីយវិទ្យុ១ទៀតនៅសាលាស៊ីសុវត្ថិ។ ស្ថានីយវិទ្យុទាំងពីរនេះទុកសម្រាប់សេនា-ធិការធ្វើការទាក់ទងទូរលេខទៅកងពលនានានៅតំបន់រតនគិរី មណ្ឌលគិរី បូព៌ា កំពង់សោម កោះកុង

ពាយ័ព្យ និង ខត្តរមានជ័យ។ ឥឡូវអង្គការយើង (ក្បត់) ក្ដាប់បានហើយអំពីសារសំខាន់ដ៏ធំនៃស្ថានីយវិទ្យុទាក់ទងទាំងពីរនេះ។ ប្រសិនបើកងពលណាមួយដាច់ការទាក់ទងជាមួយសេនាធិការគឺដូចជាកងពលនោះដាច់ក្បាលដូច្នេះដែរ។ បងព្រាប ក៏បានប្រាប់ខ្ញុំឲ្យដឹងទៀតថា«អង្គការយើង(អង្គការក្បត់) បានលើកផែនការធ្វើរដ្ឋប្រហារកម្ទេចក្បាលម៉ាស៊ីន រួចឈានទៅក្ដាប់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ឲ្យបានទាំងស្រុងដណ្ដើមរួចរដ្ឋអំណាចទូទាំងប្រទេស។ នៅចុងខែមិថុនា នៅផ្ទះឈ្មោះ វៀង ក្នុងរោងចក្រអគ្គិសនីផ្សារតូច មានការប្រជុំបច្ចេកទេសសម្រាប់រៀបចំរដ្ឋប្រហារ។ ប៊ុន ហៅខ្ញុំឲ្យទៅចូលរួមប្រជុំដែរហើយ អ្នកចូលរួមមាន៖ វុត គឺជាប្រធានបណ្ដាញអគ្គិសនី គឺជាប្រធានអង្គប្រជុំ, វៀង គឺជាប្រធានរោងចក្រអគ្គិសនីផ្សារតូច, សំ និង ផែន ធ្វើការនៅក្រសួងសាធារណការ, កន និង លី ធ្វើការនៅបណ្ដាញអគ្គិសនី, លឹម ធ្វើការនៅអគ្គិសនីផ្សារតូច, ផុស និង កុង ធ្វើការនៅរោងចក្រទឹកភូមិព្រែក, ប៊ុន ធ្វើការនៅវិទ្យុទាក់ទង, ខ្ញុំ, សែន និង លី ធ្វើការនៅ ឡានពន្លត់អគ្គិសភ័យ។ ក្រោយមក វុត ចាប់ផ្ដើមមានមតិថា គោលដៅប្រជុំពេលនេះ គឺបញ្ជាក់ពីភារកិច្ចបច្ចេកទេសរៀបចំផែនការធ្វើរដ្ឋប្រហារ, ឲ្យអ្នកបច្ចេកទេសស្គាល់គ្នាទៅវិញទៅមកងាយស្រួលធ្វើការនៅថ្ងៃមុខ។

នៅពាក់កណ្ដាលខែកញ្ញា ខ្ញុំឃើញ រិន និង សែង ធ្វើការនៅមន្ទីរតាមដានវិទ្យុ មកចូលរួមក្នុងវគ្គនយោបាយពីរថ្ងៃនៅសាលា៧០១ ស្ថិតនៅខាងលិចសាលាស៊ីសុវត្ថិ ដែលមានបងណាត គឺជាអ្នកខ្ទេសនាមឯកសារ។ រិន និង សែង បានឆ្លៀតមានមតិប្រាប់ខ្ញុំស្ងាត់ៗថា សម្ភារសម្រាប់រាវរកទីតាំងផ្សាយដែលគាត់ទទួលបាននោះពិតមែនតែពុំសូវទៀងទាត់ល្អតែអាចបម្រើការងារបាន។

នៅខែតុលា ខ្ញុំសង្កេតឃើញសកម្មភាពទាក់ទងនឹងការធ្វើរដ្ឋប្រហារមានការរយាលទៅៗ ចំណែកមតិណែនាំថ្មីពី វៀង ឬ វុត មិនឃើញមកទៀតឡើយ។ ខ្ញុំ និង ប៊ុន ក៏អនុវត្តន៍មតិណែនាំទទួលបានកាលពីមុនគឺ បន្តតាមដានដំណើរការវិទ្យុផ្សាយនិងវិទ្យុទទួលដើម្បីក្ដាប់ស្ថានីយវិទ្យុទាំងពីរឲ្យជាប់។ នៅថ្ងៃរដ្ឋប្រហារសម្រេចថាខ្ញុំត្រូវតែនៅប្រចាំការឯស្ថានីយផ្សាយទួលស្វាយព្រៃហើយ ប៊ុន ត្រូវនៅប្រចាំការស្ថានីយជិតសាលាស៊ីសុវត្ថិព្រោះជាស្ថានីយបញ្ជូន។ នៅខែវិច្ឆិកា ស៊ុន នៅកងពល១៦៤ ក៏បានឡើងកាន់នាទីទទួលខុសត្រូវស្ថានីយវិទ្យុទួលស្វាយព្រៃ ជំនួស អឿន គឺជាកងពល៨០១។ ខ្ញុំក្រៅពីបំពេញភារកិច្ចនៅក្នុងកន្លែងរបស់ខ្ញុំហើយបានទៅបំពេញភារកិច្ចនៅខាងក្រៅដោយទៅជួយតម្លើងវិទ្យុសេ២៥ និងអង់តែនទុកសម្រាប់ទាក់ទងនៅថ្ងៃរដ្ឋប្រហារ រហូតដល់ខែមករា ឆ្នាំ១៩៧៧ ទើបខ្ញុំតម្លើងរួចរាល់។ នៅខែកក្កដា ឆ្នាំ១៩៧៧ អង្គការចាប់ខ្ញុំមកសួរចម្លើយ។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារJ០០៦២៧។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ គឹម ភិកតុន ពិតបុយ៉ាងណានោះទេ?**



កម្មាភិបាលខ្មែរក្រហមដើរនៅវាលស្រែ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឈឹម យុត៖ ខ្មែរក្រហមជម្លៀសខ្ញុំពីភូមិភាគបូព៌ាទៅកាន់តំបន់ជីខ្មាញ់នៅខេត្តពោធិ៍សាត់

អ៊ីវ ធាវី



ឈឹម យុត អាយុ៦៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ( អ៊ីវ ធាវី/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ខ្ញុំឈ្មោះ ឈឹម យុត អាយុ៦៩ឆ្នាំ រស់នៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ឪពុករបស់ខ្ញុំឈ្មោះ ឈឹម ប៉ុល និង ម្ដាយឈ្មោះ ស៊ុំ ញឹម។ ខ្ញុំមានបងប្អូនបង្កើតចំនួន ៧ នាក់ បាត់បង់ជីវិតអស់៥នាក់នៅក្នុងរបប ប៉ុល ពត។ កាលពីកុមារ ខ្ញុំរៀនដល់ថ្នាក់ទី៩ក៏ឈប់រៀន ដោយសារប្រទេសកើតមានសង្គ្រាមបន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុនៅថ្ងៃទី១៨ខែមីនា ឆ្នាំ១៩៧០។ អំឡុងពេលនោះ ស្ថានភាពនៅក្នុងប្រទេសមានការបាញ់ផ្ដោងពីវៀតណាមខាងត្បូង, ការដាក់ទ័ពរបស់លន់ នល់ និងមានអំពើចោរប្លន់ចាប់រំលោភជាដើម។ ឪពុករបស់ខ្ញុំត្រូវទាហានចាប់ជំរុញយកមាស។ ខ្ញុំនិងក្រុមគ្រួសាររស់នៅក្នុងភូមិមិនមានសុវត្ថិភាពនោះទេ ព្រោះនៅជាប់ព្រំដែនត្រូវរត់គេចពីសង្គ្រាមជាប់រហូត។ នៅឆ្នាំ១៩៧៣ ខ្ញុំបានរៀបការជាមួយបុរសម្នាក់នៅឃុំព្រៃឈរ។ គូរបស់ខ្ញុំជាគូដឹបូង១ដែលអង្គការរៀបចំឲ្យ។ ពេលខ្ញុំរៀបការខ្មែរក្រហមមិនមានភ្លេង ប៉ុន្តែនៅមានព្រះសង្ឃនៅឡើយ។ ក្រោយពេលរៀបការរួច ខ្ញុំមករស់នៅក្នុងភូមិវិញ។

បន្ទាប់ពី ខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៦ មានការបង្កើតសហករណ៍ធ្វើការងាររួមហូបរួម។ ខ្មែរក្រហមចាត់ឲ្យខ្ញុំបុកស្រូវកាន់តែច្រើនឡើង១ពីមួយថ្ងៃទៅមួយថ្ងៃ រហូតខ្ញុំមិនអាចទ្រាំទ្រនឹងការងារបាននេះបាន ក៏សូមប្ដូរមកធ្វើការងារដឹកប្រឡាយ និងលើកទំនប់វិញ។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានអង្គការគៀបសង្កត់ជាខ្លាំង ព្រោះបងប្រុសរបស់

ខ្ញុំរត់ទៅវៀតណាមចុះចូលជាមួយកងទ័ពរំដោះ។ មានថ្ងៃមួយ ប្អូនស្រីរបស់ខ្ញុំឈ្មោះ ឈឹម កាន បានទៅលួចចាប់ត្រីមកធ្វើម្ហូប ជាអកុសលយៀកណាមផ្ទោងគ្រាប់ត្រូវស្លាប់ភ្លាមៗនៅហ្នឹងកន្លែង។ ខ្មែរក្រហមមានជម្លោះជាមួយវៀតណាម ដូចនេះ មានការវាយប្រហារនៅតាមព្រំដែន អង្គការក៏បានកៀរប្រជាជនទាំងអស់ទៅនៅភូមិព្រែកន្សា និងពេជ្ជីរតន៍រយៈពេលមួយឆ្នាំ។

ក្រោយមកនៅឆ្នាំ១៩៧៨ ប្រជាជនទាំងនោះក៏ត្រូវបានអង្គការបញ្ជូនទៅតំបន់ដីខ្វាញ់ ក្រោមហេតុផលលើកឡើងថា ទីនោះដីមានជីវជាតិ និងមានរបបអាហារហូបគ្រប់គ្រាន់។ ខ្ញុំបានដឹងរួចជាស្រេចថាខ្មែរក្រហមជម្លៀសក្រុមគ្រួសារខ្ញុំយកទៅសម្លាប់ ក៏យំឱបលាគ្នា។ ពេលទៅដល់អ្នកលឿងមានប្រជាជនជាច្រើនត្រូវខ្មែរក្រហមជម្លៀសទៅតំបន់ដីខ្វាញ់។ ខ្ញុំឡើងកប៉ាល់មិនទាន់ផុតស្រួលបួលផង ខ្មែរក្រហមរុញច្រានខ្ញុំក្នុងគោលបំណងឲ្យធ្លាក់ពីលើកប៉ាល់ស្លាប់។ ខ្ញុំជិះកប៉ាល់ដល់ច្បារអំពៅ ខ្មែរក្រហមបញ្ជូនឲ្យជិះរថភ្លើងបន្តទៅដល់ខេត្តពោធិ៍សាត់។ ខ្ញុំត្រូវខ្មែរក្រហមជម្លៀសទៅដាក់នៅសហករណ៍អន្លង់វិលដោយបំបែកគ្រួសារខ្ញុំឲ្យរស់នៅផ្សេងគ្នាទាំងអស់។ ប្តីរបស់ខ្ញុំត្រូវខ្មែរក្រហមចាត់ឲ្យទៅកាប់ដើមព្រិចនៅកន្លែងផ្សេងៗ។ ខ្ញុំត្រូវខ្មែរក្រហមចាត់ឲ្យទៅនៅបុស្សី១០០គុម្ព ប៉ុន្តែខ្ញុំទើបតែសម្រាលកូនបានរយៈពេល៥ខែក៏សុំអង្គការរស់នៅសហករណ៍អន្លង់វិលបន្ត។ ខ្មែរក្រហមបានដាក់ទណ្ឌកម្មខ្ញុំដោយប្រើឲ្យខ្ញុំរែកទឹកមួយថ្ងៃ១០០អម្រែក។ ខ្ញុំរស់នៅទីនោះគ្រោះថ្នាក់ណាស់ ព្រោះពេលមានប្រជាជនធ្វើខុសនឹងត្រូវខ្មែរក្រហមយកទៅសម្លាប់ភ្លាមៗ។ មុនពេលកងទ័ពវៀតណាមវាយចូលមកពីរបីថ្ងៃមានការសម្លាប់ប្រជាជនយ៉ាងរង្គាល ដោយខ្មែរក្រហមប្រើឲ្យប្រូតស្រូវប្រណាំងគ្នាបើអ្នកណាទៅដល់មុនរួចពីការសម្លាប់។ ក្រុមរបស់ខ្ញុំប្រូតរួចមុនគេ ទើបបានរួចពីសេចក្តីស្លាប់។ បន្ទាប់ពីនោះ បានប៉ុន្មានថ្ងៃកងទ័ពវៀតណាមក៏វាយចូលមកដល់ ខ្ញុំបាត់បង់ប្អូនប្រុសម្នាក់ឈ្មោះ ឈឹម អាន។ ខ្ញុំនិងក្រុមគ្រួសារបានស្វែងរកគាត់ប៉ុន្តែរកមិនឃើញបាត់ដំណឹងរហូតមកដល់បច្ចុប្បន្ន។ នៅតាមផ្លូវពោរពេញទៅដោយអ្នកដែលខ្មែរក្រហមសម្លាប់នៅថ្មីៗនៅឡើយ ដោយអ្នកខ្លះស្លាប់ទាំងជាប់ចំណងនៅនឹងគល់ឈើ។ ខ្ញុំនិងគ្រួសារធ្វើដំណើរត្រឡប់មករស់នៅស្រុកកំណើតវិញដោយមានការការពារពីសំណាក់កងទ័ពវៀតណាម។ ប្រជាជនមួយចំនួនត្រូវខ្មែរក្រហមកៀរយកទៅក្នុងព្រៃវិញ។



ប្រជាជននៅស្រុកកំពង់ត្របែកខេត្តព្រៃវែង ដឹកស្រូវពីវាលស្រែយកទៅផ្ទះ បន្ទាប់ពីប្រូតកាត់ និងបោកបែនរួចៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ញ៉ឹក ជិន ៖ នីរសារ និង ប្រធានកងក្នុងរបបខ្មែរក្រហម

**អ៊ីវ ធាវី**



ញ៉ឹក ជិន អាយុ៧២ឆ្នាំ សព្វថ្ងៃរស់នៅភូមិចាម ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
( អ៊ីវ ធាវី/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ខ្ញុំឈ្មោះ ញ៉ឹក ជិន អាយុ៧២ឆ្នាំ រស់នៅភូមិចាម ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ខ្ញុំមានស្រុកកំណើតនៅភូមិតាហ៊ិរ ឃុំថ្កូវ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ កាលពីកុមារ ខ្ញុំរៀនដល់ថ្នាក់ទី១០ពីសង្គមចាស់ នៅសាលាវត្តគ្រីស។ ខ្ញុំឈប់រៀនដោយសារមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ។ ខ្ញុំនិងសិស្សរាប់រយនាក់នាំគ្នាទៅធ្វើបាតុកម្មនៅកអណ្តើក ហើយត្រូវទាហាន លន់ នល់ ចាប់ដាក់គុក។ ខ្ញុំត្រូវរត់គេចខ្លួនរហូតដោយសារមានការផ្គោងគ្រាប់ពីសំណាក់យោធាខ្មែរក្រហម និងការដាក់ទ័ពរបស់ទាហាន លន់ នល់។ នៅឆ្នាំ១៩៧២ ខ្ញុំបានរៀបការជាមួយភរិយារបស់ខ្ញុំឈ្មោះ ជ័យ ប៉ាន់។ នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានអង្គការចាត់ឲ្យធ្វើនីរសារ។ ខ្ញុំត្រូវខ្មែរក្រហមប្រើឲ្យរត់សំបុត្រពីភូមិតាហ៊ិរ ទៅស្រុកទាំងយប់អាធ្រាត្រ ពេលនោះខ្ញុំភ័យខ្លាចទាហាន លន់ នល់ បាញ់សម្លាប់ខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនហ៊ានប្រកែកឡើយ។ ក្រោយមក ខ្ញុំក៏សុំខ្មែរក្រហមឈប់ធ្វើជានីរសារ ខ្មែរក្រហមក៏ចាត់ខ្ញុំឲ្យធ្វើជាប្រធានក្រុមប្រវាស់ដៃវិញ។ មិនយូប៉ុន្មាន ខ្ញុំក៏សុំខ្មែរក្រហមឈប់ទៀត។ ក្រោយមក ខ្មែរក្រហមចាត់ខ្ញុំឲ្យលើកប្រព័ន្ធភ្លឺស្រែ តាំងពីម៉ោង ១២ ឬម៉ោង ១រំលងអាធ្រាត្រ។ ចំពោះការហូបចុកវិញពុំគ្រប់គ្រាន់ឡើយ។ ខ្មែរក្រហមបែងចែកកម្លាំងសម្រាប់ធ្វើការងារ។ កម្លាំងទី១យុវជនប្រុសៗត្រូវខ្មែរក្រហមចាត់ឲ្យទៅភ្ជួរ ស្រីៗត្រូវទៅដកស្ទូង និងបុកស្រូវ។ ចំពោះ

កុមារត្រូវដើររើសអាចម៍គោ និងកាប់ទន្ទ្រានខែត្រធ្វើជី។ រីឯយាយៗ មើលក្មេង ចំណែកតាៗវេញខ្សែ។

បន្ទាប់ពីខ្មែរក្រហមវាយបែកទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ នៅក្នុងភូមិរបស់ខ្ញុំមានប្រជាជនថ្មីជាច្រើនដែលខ្មែរក្រហមជម្លៀសចេញពីទីក្រុងចូលមករស់នៅក្នុងភូមិ។ ប្រជាជនថ្មីទាំងនោះមកនៅមិនទាន់បានប៉ុន្មានផងក៏ត្រូវខ្មែរក្រហមបញ្ជូនយកទៅដាក់គុកទួលម្រេញអស់ ហើយបាត់ខ្លួនរហូតមកដល់សព្វថ្ងៃ។ នៅចន្លោះឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ស្ថានការណ៍កាន់តែពិបាកឡើង អ្នកណាធ្វើខុសបន្តិចបន្តួចនឹងត្រូវខ្មែរក្រហមចាប់យកទៅដាក់គុកទួលម្រេញ គ្មានថ្ងៃបានវិលត្រឡប់មកវិញឡើយ។ ទន្ទឹមនឹងនោះដែរមានការចល័តប្រជាជនឲ្យទៅតំបន់ដីខ្សាច់ ដោយខ្មែរក្រហមចោទថាជាប់សន្តិសម្ព័ន្ធឬជាប់និន្នាការមិនល្អ។ ការចល័តប្រជាជនពីភូមិភាគបូព៌ាទៅតំបន់ដីខ្សាច់នេះចែកចេញជាច្រើនដំណាក់កាល។ ប្រជាជនដែលត្រូវខ្មែរក្រហមបញ្ជូនទៅតំបន់ដីខ្សាច់ដំបូងៗមិនឃើញវិលត្រឡប់មកវិញទេ។ ចំណែកអ្នកដែលត្រូវខ្មែរក្រហមបញ្ជូនទៅក្រោយៗមានអ្នកវិលត្រឡប់មកវិញខ្លះ។

នៅឆ្នាំ១៩៧៩ ខ្ញុំនិងប្រជាជនផ្សេងទៀតត្រូវខ្មែរក្រហមនាំយកទៅសម្លាប់ ប៉ុន្តែដោយសារនៅជាប់ខេត្តស្វាយរៀងក្បែរព្រំដែនកងទ័ពវៀតណាមក៏វាយចូលមកដល់ ពេលនោះខ្មែរក្រហមសម្លាប់ខ្ញុំនិងប្រជាជនផ្សេងទៀតមិនទាន់ក៏កៀរពួកខ្ញុំទៅដល់ស្រុកព្រះស្ដេច កងទ័ពវៀតណាមតាមទាន់ក៏ប្រាប់ឲ្យខ្ញុំនិងប្រជាជនផ្សេងទៀតត្រឡប់ក្រោយមកភូមិកំណើតវិញ។ ពេលខ្ញុំមកដល់ភូមិវិញប្រជាជនមួយចំនួននាំគ្នាដេញកាប់សម្លាប់ខ្ញុំហៀបតែស្លាប់ដោយចោទថាខ្ញុំជាបក្សពួក ប៉ុល ពត ប៉ុន្តែសំណាងល្អខ្ញុំត្រូវកងទ័ពវៀតណាមចាប់ខ្លួនយកទៅសួរចម្លើយនៅព្រៃពន្លាចក្រ និងបញ្ជូនខ្ញុំបន្តរហូតទៅដល់តាជ័យ ខេត្តស្វាយរៀង។ កងទ័ពវៀតណាមចាត់ឲ្យខ្ញុំ និងអ្នកទោសរាប់រយនាក់ទៀត ធ្វើការងារនៅស្វាយរៀងអស់រយៈពេល ៣ខែ ២៥ថ្ងៃ ខ្ញុំក៏បានលួចរត់ចេញមកកាន់ភូមិចាមស្រុកខាងប្រពន្ធបានបីថ្ងៃ។ ដោយសារស្ថានការណ៍មិនស្រួល ខ្ញុំបន្តរត់ទៅខេត្តកំពង់ចាមមួយរយៈទៀតទើបត្រឡប់មករស់នៅជួបជុំប្រពន្ធកូនវិញ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំបាត់បង់បងប្អូនបង្កើតដែលជាយោធាខ្មែរក្រហមប្រធាន «ខ» និងយោធាកងពលលេខ ៤ អស់ជាច្រើននាក់ ដោយសារខ្មែរក្រហមសម្លាប់។ ខ្ញុំស្អប់របបខ្មែរក្រហមដែលសម្លាប់ជីវិតប្រជាជនស្លូតត្រង់អស់រាប់លាននាក់និងមិនចង់ឲ្យរបបខ្មែរក្រហមកើតឡើងវិញម្ដងទៀតនោះទេ។



ផ្ទះរបស់ប្រជាជននៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# នុត សារ៉ុន ៖ កងកុមារនៅក្នុងរបបខ្មែរក្រហម

**អ៊ីវ ធារី**



នុត សារ៉ុន អាយុ៥៤ឆ្នាំ សព្វថ្ងៃរស់នៅភូមិកន្សា ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (អ៊ីវ ធារី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នុត សារ៉ុន អង្គុយនៅក្រោមផ្ទះពោរពេញដោយទេសភាពធម្មជាតិជុំវិញស្រស់បំព្រងបានរៀបរាប់ដំណើរជីវិតរបស់ខ្លួនដែលចងចាំមិនភ្លេចពីរបបខ្មែរក្រហមថា៖ ខ្ញុំមានអាយុ៥៤ឆ្នាំ (ឆ្នាំ២០២២) រស់នៅភូមិកន្សា ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ពេលខ្មែរក្រហមឡើងកាន់អំណាចឆ្នាំ១៩៧៥ នៅក្នុងភូមិរបស់ខ្ញុំមានប្រជាជនថ្មីជាច្រើន ដែលត្រូវខ្មែរក្រហមជម្លៀសមកពីទីក្រុងភ្នំពេញ។ ពូរបស់ខ្ញុំគឺជាប្រជាជនថ្មី គាត់ធ្លាប់ធ្វើជាអ្នកបោះពុម្ពកាសែត ខ្មែរក្រហមបញ្ជូនគាត់ទៅកាន់គុកទួលស្រែញ។ នៅទីនោះ ខ្មែរក្រហមប្រើគាត់ឲ្យធ្វើការងារជាទម្ងន់គ្មានពេលសម្រាក និងមិនមានអាហារសម្រាប់ហូបគ្រប់គ្រាន់។ ប្រជាជនដទៃទៀតដែលត្រូវខ្មែរក្រហមបញ្ជូនទៅកាន់គុកទួលស្រែញត្រូវអង្គការសម្លាប់ចោលស្ទើរតែទាំងអស់។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំនៅវ័យកុមារប៉ុន្តែខ្មែរក្រហមមិនអនុញ្ញាតឲ្យខ្ញុំរស់នៅជាមួយក្រុមគ្រួសារឪពុកម្តាយទេ ដោយឪពុកម្តាយត្រូវអង្គការចាត់ឲ្យទៅធ្វើចម្ការ។ ចំណែក បងប្រុសត្រូវអង្គការចាត់ឲ្យទៅធ្វើយោធានៅស្រុកបាភ្នំ ខេត្តព្រៃវែង។ ខ្ញុំធ្វើការងារពលកម្មលំបាកវេទនាគ្មានពេលសម្រាក។ ខ្ញុំមានការភ័យខ្លាចនៅពេលឃើញខ្មែរក្រហមបណ្តើរមនុស្សទៅ និងមិនដែលឃើញអ្នកទាំងនោះត្រឡប់មកវិញ។ ខ្ញុំខំប្រឹងធ្វើការងារមិនហ៊ានត្អូញត្អែរពីមួយថ្ងៃទៅមួយថ្ងៃ ព្រោះខ្លាចខ្មែរក្រហមបញ្ជូនទៅកាន់ទួលស្រែញ។ ពីដំបូងខ្មែរក្រហមចាត់ឲ្យខ្ញុំបកដើមល្ពាក់ក្នុងមួយថ្ងៃប្រាំដំបរ។ ក្រោយមកទៀត អង្គការបានចាត់ខ្ញុំឲ្យទៅជញ្ជូនត្រីសម្រាប់ធ្វើម្ហូបនៅរោងបាយសហករណ៍។ ក្រៅពីនេះ ខ្ញុំត្រូវដកសំណាប កាប់

ដើមទន្ទ្រានខែត្រ មកចិញ្រ្ចាំលាយលាមកសត្វ និងលាមកមនុស្សដើម្បីធ្វើជីលេខមួយ។ ខ្មែរក្រហមចាត់ខ្ញុំឲ្យបុកលាមកមនុស្សរួចវែងធ្វើជីលេខមួយ។ ចំពោះរបបអាហារវិញ ពុំទទួលបានគ្រប់គ្រាន់ទេ។ ពេលខ្លះខ្ញុំលួចលាក់បេះត្រួយអំពិលយកមកបុកលាយដះតិចៗ ដើម្បីហូបលាយអាហារដែលអង្គការផ្ដល់ឲ្យ។

ពេលខ្មែរក្រហមមានជម្លោះជាមួយវៀតណាម យោធាខ្មែរក្រហមស្រុកបាភ្នំមកស្នាក់នៅក្នុងភូមិរបស់ខ្ញុំ។ ថ្ងៃមួយ យោធាម្នាក់ប្រឡុំបាញ់ប្រជាជន ព្រោះស្មានថាខ្មាំងក៏ត្រូវប្រធាន «ខ» វាយចំនួន ៣ស៊ុយកាំភ្លើង រួចយកទៅចងហាលថ្ងៃបង្អត់បាយ បង្អត់ទឹក ដោយហាមមិនឲ្យនរណាយកអាហារ និងទឹកឲ្យគាត់ឡើយ។ ពេលឃើញម្ដាយរបស់ខ្ញុំដើរកាត់នោះ គាត់ក៏សុំទឹកពីម្ដាយរបស់ខ្ញុំផឹក។ ម្ដាយរបស់ខ្ញុំអាណិតក៏ឲ្យទឹកគាត់ផឹក ត្រូវខ្មែរក្រហមហៅម្ដាយខ្ញុំទៅកសាង។ ប្រសិនបើអ្នកផ្សេងក្រៅពីម្ដាយរបស់ខ្ញុំ ត្រូវខ្មែរក្រហមសម្លាប់បាត់ទៅហើយ ប៉ុន្តែគាត់បានរួចជីវិតដោយសារបងប្រុសរបស់ខ្ញុំជាយោធា។ ចំណែក ទាហានម្នាក់នោះវិញ ត្រូវប្រធាន «ខ» ធ្វើទារុណកម្មរហូតដល់ស្លាប់យ៉ាងអណោចអធមជាទីបំផុត។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនដែលមានចំណេះដឹងធ្លាប់ជាអតីតមន្ត្រីរដ្ឋការជំនាន់មុន និងអ្នកមានទោស ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅទួលម្រេញ និងទួលតាអន។ ពូរបស់ខ្ញុំបានរួចផុតពីការសម្លាប់ដោយសារគាត់មានក្មួយធ្វើជាយោធា។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ គាត់រួចចេញពីគុកទួលម្រិញត្រឡប់មកភូមិស្រុកវិញ ដោយគាត់មានរាងកាយស្គមស្គាំងស្បែកដណ្ដប់ឆ្អឹង និងមានស្លាកស្នាមដាក់ខ្នោះដៃខ្នោះជើងនៅលើខ្លួនរបស់គាត់។

នៅឆ្នាំ១៩៧៩ ប្រជាជនភាគច្រើនត្រូវខ្មែរក្រហមជម្លៀសទៅភាគខាងលិចនៃប្រទេស។ ខ្ញុំក៏បានត្រឡប់មករស់នៅភូមិកំណើតវិញ។ ក្រោយពេលដួលរលំរបបខ្មែរក្រហម ខ្ញុំបានឃើញក្បាលខ្មោចដែលត្រូវខ្មែរក្រហមសម្លាប់នៅទួលតាអនក្នុងមួយអន្លង់៨០នាក់។



ផ្លូវលំនៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ភិន ភាគ ៖ កងស្ទូងដក

**អ៊ីវ ឆាវី**



ភិន ភាគ មានអាយុ៦៨ឆ្នាំ (ក្នុងឆ្នាំ២០២២) រស់នៅក្នុងភូមិជីពាយ ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ភិន ភាគ មានអាយុ៦៨ឆ្នាំ (ក្នុងឆ្នាំ២០២២) រស់នៅក្នុងភូមិជីពាយ ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់ចូលកងនារី ក្នុងរបបខ្មែរក្រហម។ សព្វថ្ងៃ ខ្ញុំមានជំងឺប្រចាំកាយ គឺលើសឈាម ខ្សោយបេះដូង ហើមមុខ និងចុកពោះ។ ខ្ញុំមានឪពុកឈ្មោះ ភិន ឡាញ់ និងម្តាយឈ្មោះ ភឿក ស៊ឹម និងមានបងប្អូនបង្កើតចំនួន៦នាក់។ សព្វថ្ងៃ បងប្អូនរបស់ខ្ញុំនៅរស់តែ៤នាក់ប៉ុណ្ណោះ ចំណែកបងប្អូនពីនាក់ទៀតស្លាប់ដោយសារជំងឺ។

ខ្ញុំធ្លាប់បានសិក្សារៀននៅសាលាផ្សារខាន់ ត្រឹមថ្នាក់ទី១១ កាលពីសង្គមចាស់ ក៏ឈប់រៀន ដោយសារឪពុកឈឺ។ ឆ្នាំ១៩៧២ ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំ ឈឹម រិន។ ខ្ញុំរៀបការទាំងភ័យព្រួយ ព្រោះពេលនោះមានការលុកលុយពី កងទ័ពធីវគី (វៀតណាមខាងត្បូង)។ បន្ទាប់ពីរៀបការរួច ខ្ញុំ ព្រមទាំងក្រុមគ្រួសារ និងអ្នកភូមិទាំងអស់នាំគ្នារត់គេចគ្រាប់ផ្លោងរហូត។ ខ្ញុំពុំសូវបានស្នាក់នៅផ្ទះនៅក្នុងភូមិឡើយ។ កងទ័ពធីវគីខ្លះកាចៗណាស់ និងខ្លះទៀតពេលជួបស្រីៗដែលមានរូបឆោមស្អាតបានចាប់ធ្វើបាប។ ខ្ញុំបានរត់គេចពីកងទ័ពធីវគីទៅលាក់ខ្លួននៅឃុំប្រធាតុ បន្ទាប់មកទៅនៅស្រុកមេសាង និងខេត្តស្វាយរៀង។

ចាប់ពីឆ្នាំ១៩៧៤ លែងមានវត្តមានកងទ័ពធីវគីទៀតហើយ ប៉ុន្តែស្រាប់តែឃើញមានកងទ័ពបដិវត្តន៍ខ្មែរក្រហមចូលមកជំនួស។ ដំបូងឡើយខ្មែរក្រហមបង្កើតជាក្រុមប្រវាស់ដៃនិងឲ្យប្រជាជនហូបបាយឯកជននៅតាមផ្ទះធម្មតា។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបាន

វាយបែកទីក្រុងភ្នំពេញ រួចជម្លៀសប្រជាជនចេញទាំងអស់ចេញពីផ្ទះសម្បែង។ ពេលនោះប្រជាជនជម្លៀសមួយចំនួនបានមករស់នៅភូមិរបស់គាត់។ មិនយូរបានប៉ុន្មានខ្មែរក្រហមនាំយកប្រជាជនជម្លៀសទាំងនោះចេញពីភូមិ ដោយប្រាប់ថា «ប្តូរទីកន្លែង» ហើយអ្នកទាំងនោះពុំដែលឃើញត្រឡប់មកវិញទេ។ ក្រោយមកទើបខ្ញុំដឹងថាអ្នកទាំងនោះត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅទួលម្រេញ ដែលមានទីតាំងនៅខាងជើងកអណ្តើក ក្នុងស្រុកកំពង់ត្របែក។

នៅក្នុងភូមិ ខ្មែរក្រហមបានដើរប្រមូលរបស់របរបស់ប្រជាជនដាក់ជារបស់រួមទាំងអស់។ ប្រជាជនគ្មានសេសសល់កម្មសិទ្ធិអ្វីទេ គឺខ្មែរក្រហមទុកតែកំសៀវទឹកឲ្យមួយតែប៉ុណ្ណោះ។ ពេលនោះហើយដែលខ្ញុំជួបការលំពិបាក ព្រោះខ្មែរក្រហមឲ្យហូបតែបបរមួយថ្ងៃពីរពេលតែប៉ុណ្ណោះជាមួយសម្លរដើមចេក។ ចំណែកការងារគឺខ្ញុំធ្វើការគ្មានពេលទំនេរឡើយ។ នៅពេលនោះខ្ញុំមានកូនខ្ចីទើបតែអាយុបានកន្លះខែតែប៉ុណ្ណោះ ប៉ុន្តែខ្មែរក្រហមចាត់តាំងខ្ញុំឲ្យទៅរែកដី, ទៅស្ទូង និងបុកស្រូវក្នុងមួយថ្ងៃឲ្យបាន៣តៅអង្ករ។

នៅខណ:ពេលដែលមានការប៉ះទង្គិចគ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម ខ្ញុំត្រូវបានប្រធានកងចាត់តាំងឲ្យទៅស្ទូងពេលយប់ ព្រោះបើទៅស្ទូងពេលថ្ងៃវៀតណាមឃើញ និងបាញ់ផ្លោងដាក់។ ខ្ញុំស្ទូងរហូតដល់ម៉ោង១២រំលងអធ្រាត្រ ឬម៉ោង១ទៀបភ្លឺ ទើបប្រធានកងឲ្យត្រឡប់មកផ្ទះវិញ ប៉ុន្តែពេលខ្លះប្រធានកងបានចាត់ខ្ញុំឲ្យស្ទូងទល់ភ្លឺទើបឲ្យត្រឡប់មកវិញ។ ពេលត្រឡប់មកដល់ផ្ទះវិញខ្ញុំពុំបានសម្រាកទេ ព្រោះខ្ញុំត្រូវបានចាត់តាំងឲ្យទៅដកសំណាបឲ្យបានមួយផ្លូនទុកសម្រាប់ស្ទូង។ ការរស់នៅក្នុងសម័យខ្មែរក្រហម គឺខ្ញុំប្រុងប្រយ័ត្នខ្លាំងណាស់។ ខ្ញុំគ្មានសិទ្ធិសេរីភាពទេ ហើយក្នុងមួយអាទិត្យម្តងខ្មែរក្រហមដើរត្រួតពិនិត្យមើល ខ្លាចខ្ញុំលាក់របស់របរទុក។ ប្រសិនបើខ្មែរក្រហមឃើញខ្ញុំលាក់ទុកប្រាកដជាយកខ្ញុំទៅដាក់គុក ឬក៏សម្លាប់ខ្ញុំចោលតែម្តង។

នៅដើម ឆ្នាំ១៩៧៩ ពេលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមវាយចូលមក ខ្ញុំនិងអ្នកភូមិត្រូវបានខ្មែរក្រហមកៀរទៅស្រុកព្រះស្តេច ទើបយើងនាំគ្នាត្រឡប់មកភូមិកំណើតវិញ។ ខ្ញុំនិងប្រជាជនចាប់ផ្តើមហូបបាយឯកជននៅតាមផ្ទះរៀងៗខ្លួនវិញ។ ប៉ុន្តែនៅពេលរបបខ្មែរក្រហមដួលរលំទៅថ្មីៗ ខ្ញុំនៅជួបការលំបាកខ្វះខាតទងនឹងការហូបចុក។ ដូច្នេះ ប្តីរបស់ខ្ញុំ បានទៅទិញនំប័ុងនៅបាវិត ក្នុងខេត្តស្វាយរៀង យកទៅលក់នៅភ្នំពេញ។ កាលនោះពុំមានម៉ូតូ ឬឡានឈ្នួលឡើយ ដូច្នេះប្តីរបស់ខ្ញុំត្រូវធាក់កង់ដឹកនំប័ុងលក់។ ខ្ញុំនិងប្តីខិតខំតស៊ូព្យាយាមរកស៊ីរហូតមានជីវភាពសមរម្យរហូតមកដល់សព្វថ្ងៃ។



វាលស្រែនៅក្នុងភូមិដកពរ ឃុំជ្រៃ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មាស ជុំ ៖ ធ្វើការទាំងត្រូវជាបត្រូវដួស ដើម្បីបានរស់ជីវិត

អ៊ីវ ឆាវី



មាស ជុំ អាយុ៧៨ឆ្នាំ (នៅក្នុងឆ្នាំ២០២២) រស់នៅភូមិចាម ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ មាស ជុំ អាយុ៧៨ឆ្នាំ (នៅក្នុងឆ្នាំ ២០២២) រស់នៅភូមិចាម ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ សព្វថ្ងៃខ្ញុំដាំដំណាំបន្លែបន្ការដើម្បីហូបចុក និងលក់យកប្រាក់ផ្គត់ផ្គង់ជីវភាពគ្រួសារ ។ រាល់ថ្ងៃខ្ញុំឈឺសន្លាក់ និងគ្មានកម្លាំងឡើយ។

ខ្ញុំមិនបានសិក្សារៀនសូត្រទេ ដោយសារឪពុកម្ដាយមានជីវភាពក្រីក្រ និងម្យ៉ាងទៀត រស់នៅជិតតំបន់ព្រំដែនដាច់ស្រយាល។ ក្រោយរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ចេញពីអំណាច នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក៏មានការផ្ទោងគ្រាប់ និងការទម្លាក់គ្រាប់ពីកងទ័ពវៀតណាមខាងត្បូង។ ខ្ញុំនិងក្រុមគ្រួសារ ក៏ដូចជាប្រជាជនក្នុងភូមិនាំគ្នាគេចចេញពីគ្រាប់ និងការចាប់ធ្វើបាបរបស់កងទ័ពអាធិរាជ។ នៅឆ្នាំ១៩៧៣ ទើបខ្ញុំត្រឡប់មកភូមិកំណើតវិញ។

ក្រោយមកកងទ័ពបដិវត្តន៍ខ្មែរក្រហមបានចូលមក។ ដំបូងឡើយខ្ញុំចូលរួមក្រុមប្រវាស់ដៃបង្កបង្កើនជាមួយខ្មែរក្រហម និងហូបបាយឯកជន។ រយៈពេលបីឆ្នាំក្រោយមក ខ្មែរក្រហមចាប់ផ្ដើមប្រមូលប្រជាជនឲ្យហូបបាយរួម។ ពេលនោះ ខ្ញុំនិងប្រជាជនក្នុងភូមិរស់នៅយ៉ាងលំបាកវេទនា ដោយខ្មែរក្រហមចាត់តាំងខ្ញុំឲ្យទៅដក ស្ទូង និងធ្វើដីគ្មានពេលសម្រាកឡើយ។ ចំណែកការហូបចុក គឺខ្ញុំពុំដែលទទួលបានរបបអាហារគ្រប់គ្រាន់ឡើយ។ ខ្ញុំហូបបបរក្នុងមួយថ្ងៃពីរពេល ហើយយូរម្ដងៗ ខ្ញុំបានហូបបាយជាមួយសម្លរម្ជូរដើមចេកពេលល្ងាច។

ចំណែកប្ដីរបស់ខ្ញុំ ត្រូវបានខ្មែរក្រហមចាត់ឲ្យទៅជីកប្រឡាយ និងកាប់ខ្សនៅលើភ្នំឈើកាច់។ នៅសម័យនោះ មនុស្សមានកម្លាំងពេញត្រូវបានខ្មែរក្រហមចាត់ឲ្យទៅជីកប្រឡាយឆ្ងាយៗ ព្រោះខ្មែរក្រហមចាត់ទុកអ្នកទាំងនោះគឺជាកម្លាំងស្រួច។

រហូតដល់កងទ័ពខ្មែរក្រហមវាយបែកទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំប្រជាជនមកពីទីក្រុងភ្នំពេញ (ឬហៅថា ប្រជាជនថ្មី) ជាច្រើនគ្រួសារមករស់នៅភូមិរបស់ខ្ញុំ។ ប៉ុន្តែមិនបានប៉ុន្មានផងខ្មែរក្រហមបានយកប្រជាជនជម្លៀសទាំងនេះចេញទៅបាត់រហូតដល់ពេលបច្ចុប្បន្ន។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំរស់នៅក្នុងភាពភ័យខ្លាចជារៀងរាល់ថ្ងៃ។ ខ្ញុំភិតភ័យពេលឃើញកងឈ្លបមកបណ្ដើរមនុស្សចេញពីកង។ ខ្ញុំនឹកគិតក្នុងចិត្តថា ថ្ងៃណាមួយកងឈ្លបមកនាំខ្ញុំទៅដែរមិនខាន។ ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំមិនដែលហ៊ានប្រកែក ឬត្អូញត្អែរជាមួយការងារដែលអង្គការដាក់ឲ្យខ្ញុំធ្វើឡើយ។ ខ្ញុំខំធ្វើការទាំងត្រដាបត្រដួសដោយធ្វើយ៉ាងណាឲ្យខ្ញុំបានរស់ជីវិត។ ខ្ញុំខំធ្វើការងារដោយគ្មានពេលសម្រាកឡើយ ព្រោះបើមិនធ្វើការប្រាកដជាចុងភៅមិនបើករបបអាហារឲ្យហូបឡើយ។

មួយរយៈក្រោយមក ខ្មែរក្រហមបានបញ្ជូនប្រជាជនមួយចំនួនឲ្យទៅរស់នៅតំបន់ដីខ្លាញ់ នៅខេត្តពោធិ៍សាត់។ ក្រោយរបបខ្មែរក្រហមដួលរលំ ប្រជាជនខ្លះបានត្រឡប់មកផ្ទះវិញ ហើយអ្នកខ្លះទៀតបានបាត់ខ្លួនមកដល់សព្វថ្ងៃ។

ចំណែកខ្ញុំ និងអ្នកភូមិខ្លះ ត្រូវបានខ្មែរក្រហមកៀរទៅដល់ទួលល្ហុង ក្នុងស្រុកព្រះស្ដេច ក៏ជួបទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម ហើយកងទ័ពទាំងនេះបានប្រាប់ខ្ញុំឲ្យត្រឡប់មកផ្ទះវិញ។ ក្រោយរបបខ្មែរក្រហមដួលរលំភ្លាមៗ ខ្ញុំនៅជួបការលំបាកនៅឡើយ ព្រោះមិនទាន់មានអាហារហូបគ្រប់គ្រាន់។ រយៈពេលពីរឆ្នាំក្រោយមក ទើបជីវភាពគ្រួសាររបស់ខ្ញុំបានល្អប្រសើរហូតមកដល់ពេលបច្ចុប្បន្ន។



មាស ជុ ដាំដំណាំបន្ទាប់បន្សំនៅផ្ទះដើម្បីផ្គត់ផ្គង់ការហូបចុកនៅក្នុងគ្រួសារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# វ៉ាន់ ស៊ន់ ៖ កងចល័តក្នុងភូមិ

អ៊ីវ ធាវី



វ៉ាន់ ស៊ន់ អាយុ៦៨ឆ្នាំ (នៅឆ្នាំ២០២២) សព្វថ្ងៃរស់នៅក្នុងភូមិជីពាយ ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ វ៉ាន់ ស៊ន់ អាយុ៦៨ឆ្នាំ (នៅឆ្នាំ២០២២) រស់នៅក្នុងភូមិជីពាយ ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ នៅសម័យនោះ ខ្ញុំរៀបការរួចហើយ ព្រមទាំងមានកូន ២នាក់។ ខ្មែរក្រហមចាត់តាំងខ្ញុំចូលក្នុងកងនារី។ សព្វថ្ងៃ ខ្ញុំមានជំងឺក្រពះ និងពោះវៀន។

ខ្ញុំគឺជាកូនស្រីទី៣ ក្នុងចំណោមបងប្អូន ៨នាក់។ ខ្ញុំពុំធ្លាប់បានសិក្សារៀនសូត្រទេ ព្រោះកាលពីសង្គមចាស់ឪពុកម្តាយរបស់ខ្ញុំប្រកាន់យកគំនិត គឺកូនស្រីពុំចាំបាច់រៀនសូត្រច្រើនទេ ហើយបើកាលណារៀនសូត្រចេះដឹង នឹងចេះសរសេរសំបុត្រស្នេហាផ្ដេសផ្ដាស់មិនខាន។ នៅឆ្នាំ១៩៧០ ខ្ញុំបានរៀបការជាមួយបុរសឈ្មោះជា ហ៊ិន។ នៅថ្ងៃចូលរោងការរបស់ខ្ញុំស្រាប់តែទាហានធីវគី (កងទ័ពវៀតណាមខាងត្បូង) ចូលមកបោះទីតាំងនៅក្នុងភូមិ ដូច្នេះខ្ញុំនិងប្តីរបស់ខ្ញុំនាំគ្នាផ្លាស់ប្តូរកន្លែងរៀបការទៅទីតាំងផ្សេងដែលស្ថិតនៅក្នុងឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ នៅពេលនោះ ទាហានធីវគីមួយចំនួនបានប្រព្រឹត្តអសីលធម៌ទៅលើប្រជាជន ហើយឲ្យតែឃើញស្ត្រីស្អាតៗនៅក្នុងភូមិ ទាហានធីវគីតែងតែចាប់ធ្វើបាប។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានវាយយកបានទីក្រុងភ្នំពេញ។ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញឲ្យមករស់នៅតាមទីជនបទដាច់ស្រយាល។ ចំណែកការរស់នៅរបស់ខ្ញុំក៏បែកពីគ្រួសារដែរ គឺខ្មែរក្រហមចាត់តាំងខ្ញុំឲ្យធ្វើការងារក្នុងភូមិ ដូចជា បុកស្រូវមួយថ្ងៃឲ្យបានបីតៅ ដាំដំឡូង ស្ទូង បាចទឹកបញ្ចូលស្រែ និងរែកដីបាតស្រះចាក់ស្រែ។ ចំណែកប្តីរបស់ខ្ញុំ គឺប្រធានកងចាត់តាំងឲ្យធ្វើការងារភ្ជួររាស់នៅក្នុងកងចល័ត។ នៅសម័យនោះ ខ្មែរក្រហមចាត់ខ្ញុំឲ្យធ្វើការគ្មានពេលសម្រាកឡើយ ចំណែកការហូបចុកវិញ គឺខ្ញុំពុំទទួលបានរបបអាហារគ្រប់គ្រាន់ឡើយ។ ដោយសារតែហូបមិនឆ្អែត ខ្ញុំបានបេះស្លឹកដ្ឋី ត្រកួន ស្លឹកដំឡូង យកមកស្រុះហូបជាមួយអំបិល។

ក្រោយមក ប្រធានកងខ្មែរក្រហមបានដើរស្រង់ឈ្មោះក្រុមគ្រួសារ ឪពុកម្តាយបងប្អូនរបស់ខ្ញុំដើម្បីរៀបចំបញ្ជូនទៅនៅខេត្តផ្សេងៗ។ នៅខណៈនោះដែរ ខ្មែរក្រហមក៏ប្រមូលយកអ្នកមានកូនខ្ចីបញ្ជូនទៅ

ព្រៃគុយ ស្ថិតនៅក្នុងឃុំជ្រៃ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង បម្រុងនឹងសម្លាប់ចោល ប៉ុន្តែដោយសារកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមវាយចូលដល់ស្វាយរៀង ទើបធ្វើឲ្យខ្មែរក្រហមមកពីភូមិភាគនិរតីជ្រួលច្របល់ ហើយកៀរខ្ញុំ និងអ្នកភូមិទាំងអស់ទៅទិសខាងលិចវិញ។ ពេលខ្ញុំមកដល់ស្រុកព្រះស្ដេច ខេត្តព្រៃវែង កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមបានតាមទាន់ និងប្រាប់ខ្ញុំឲ្យត្រឡប់មកស្រុកកំណើតវិញ។



វ៉ាន់ ស៊ិន់ ដាំដំណាំបន្ទាប់បន្សំនៅផ្ទះ ដើម្បីផ្គត់ផ្គង់ការហូបចុកនៅក្នុងគ្រួសារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# វត្តរោងដំរី

**សោម ប៊ុនថន**



វត្តរោងដំរី ស្ថិតនៅក្នុងសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





អំឡុងពេលចុះធ្វើការងារនៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ក្រុមការងារបានយកទស្សនាវដ្ដីស្វែងរកការពិតដែលបានបោះពុម្ពផ្សាយអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទៅប្រគេនព្រះអង្គ យាង ភាល័គ ព្រះចៅអធិការវត្តរោងដំរី ស្ថិតនៅក្នុងសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ដែលមានចម្ងាយប្រមាណ ២គីឡូម៉ែត្រពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ ព្រះតេជគុណ យាង ភាល័គ មានសង្ឃដីកាថា កាលពីសម័យដើម វត្តរោងដំរី មានព្រះអង្គធ្វើពីសំរឹទ្ធសុទ្ធមួយអង្គដែលបានដាក់តម្កល់ទុកនៅព្រះវិហារ។ ក្រោយមកនៅអំឡុងសម័យសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជាក៏

មានការទម្លាក់គ្រាប់បែកយ៉ាងច្រើននៅជុំវិញវត្តរោងដំរី និងលើព្រះវិហារវត្តរោងដំរីនេះ ប៉ុន្តែគ្រាប់បែកដែលទម្លាក់មកទាំងនោះមិនផ្ទុះ និងពុំដែលចំព្រះវិហារឡើយ ព្រោះនៅក្នុងព្រះវិហារមានព្រះអង្គធ្វើពីសំរិទ្ធសុទ្ធដែលតាមវិទ្យាសាស្ត្រសំរិទ្ធគឺមានសារធាតុដែលមិនអាចឲ្យគ្រាប់បែកផ្ទុះ ហើយម្យ៉ាងទៀតដោយសារមានជំនឿថាវត្តនេះមានបារមីស័ក្តិសិទ្ធិ។

មកដល់របបខ្មែរក្រហម កម្មាភិបាលខ្មែរក្រហមបានយកកុដិព្រះសង្ឃដែលសង់អំពីថ្មធ្វើជាមន្ទីរពេទ្យព្យាបាលអ្នកជំងឺ និងយកព្រះវិហារធ្វើជាកន្លែងចិញ្ចឹមជ្រូក ហើយទីតាំងធម្មសាលា ខ្មែរក្រហមប្រើប្រាស់សម្រាប់ការងារប្រចាំថ្ងៃ។ ចំណែកព្រះអង្គសំរិទ្ធិគឺរក្សាទុកនៅព្រះវិហារដដែល។ ព្រះអង្គមានសង្ឃដីកាបន្តថា ក្រោយពីរបបខ្មែរក្រហមដួលរលំ លោកយាយ លោកតា និងពុទ្ធបរិស័ទបាននាំគ្នាបោសសម្អាតព្រះវិហារដែលបន្សល់ទុកសុទ្ធតែលាមកជ្រូកនិងទីធ្លាវត្តដើម្បីរៀបចំប្រើប្រាស់ជាកន្លែងគោរពបូជាឡើងវិញ។ ដោយសារព្រួយបារម្ភពីការបាត់បង់ព្រះអង្គសំរិទ្ធ ពុទ្ធបរិស័ទបាននាំគ្នាសែងព្រះអង្គសំរិទ្ធពីបល្ល័ងមករក្សាទុកនៅកុដិព្រះសង្ឃវិញ ប៉ុន្តែមិនអាចរំកិលព្រះអង្គសំរិទ្ធបានឡើយ។ ក្រោយមកទើបអាចារ្យ និងពុទ្ធបរិស័ទលេងភ្លេងពិណពាទ្យចំនួន៧បទថ្វាយ និងបន់ស្រន់ទើបអាចរំកិលព្រះអង្គសំរិទ្ធចេញពីបល្ល័ង្កបាន។ នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ព្រះអង្គសំរិទ្ធនោះត្រូវបានចោរចូលមកយកនៅវេលាម៉ោង ៣ ទៀបភ្លឺ ទោះបីពេលនោះព្រះសង្ឃនិងអាចារ្យវត្តដឹងក៏ដោយក៏មិនអាចធ្វើការទប់ស្កាត់បានដែរ ព្រោះក្រុមចោរបានប្រើកាំភ្លើងដើម្បីគំរាម។ ចាប់តាំងពីពេលនោះមក គឺនៅសល់តែបល្ល័ងព្រះអង្គសំរិទ្ធតែប៉ុណ្ណោះ។

បច្ចុប្បន្ន នៅក្នុងបរិវេណវត្តរោងដំរីនេះនៅមានសេសសល់សំណង់ចេតិយដែលមានអាយុយ៉ាងតិច៦០ឆ្នាំជាច្រើន, កុដិ និងធម្មសាលាមានអាយុកាលច្រើនឆ្នាំ ត្រូវបានថែរក្សាទុកបានយ៉ាងល្អ។ ចំណែកផ្នែកខ្លះនៃព្រះវិហារត្រូវបានកែលម្អដោយដាក់ពិដាន និងមានការគូរគំនូរ ហើយដំបូលត្រូវបានជំនួសដោយគ្រឿងថ្មី ក្រៅពីនោះគឺនៅរក្សាទម្រង់ដើមដដែល ដូចជា ផ្លោង ផ្កាន ធ្មឹម ហោជាង ទ្វារ បង្អួច ដែលសាងសង់ពីឈើ ចំណែកជញ្ជាំងសង់ពីឥដ្ឋលាយបាយអរ។ តាមសង្ឃដីការបស់ព្រះចៅអធិការវត្ត សសរទាំងអស់នៅព្រះវិហារនេះគឺសង់អំពីឈើទាំងអស់ ដែលដឹកតាមកប៉ាល់មកពីខេត្តក្រចេះនៅមុនសម័យបារាំងទៅទៀត។ សសរឈើទាំងនេះនៅរឹងមាំ និងទ្រទ្រង់ព្រះវិហារបាននៅឡើយ ដោយគ្រាន់តែមានការលាបថ្នាំ និងគូរគំនូរពីលើ។ ដោយសារវត្តរោងដំរីមានអាយុកាលច្រើនឆ្នាំ និងមានសំណង់ ព្រមទាំងចេតិយបុរាណច្រើនទើបមានពុទ្ធបរិស័ទ និងក្រុមការងារព្រះបរមរាជវាំងមកធ្វើបុណ្យជាញឹកញាប់។









វត្តរោងដំរី ស្ថិតនៅក្នុងសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការស្រាវជ្រាវតំបន់ប្រវត្តិសាស្ត្រ តាមរយៈការចងចាំ

ផេង ពង្សរ៉ាស៊ី



ស្ពានតាម៉ុកៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ទំនប់តាម៉ុកៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ស្ពានតាម៉ុក

ស្ពានតាម៉ុក ដែលទ្រុឌទ្រោមប្រើការលែងបាន ធ្វើពីស៊ីម៉ងត៍ ត្រូវប្រជាជនក្នុងតំបន់ស្គាល់គ្រប់គ្នាថាជាស្ពានតាម៉ុក ត្រូវបានសាងសង់ឡើងដំណាលគ្នាជាមួយនឹងផ្ទះ និងព្រែកជីក តាម៉ុកៗ ស្ពាននេះ អាចមើលឃើញពីត្រើយម្ខាងបានយ៉ាងច្បាស់ និងមានសភាពស្ងាត់ជ្រងំៗ ជារៀងរាល់ថ្ងៃប្រជាកសិករធ្វើដំណើរតាមទូកឆ្លងកាត់ក្រោមស្ពាននេះដើម្បីធ្វើស្រែៗ ពុំមានផ្លូវថ្នល់ ឬផ្លូវដែលអាចធ្វើដំណើរដោយថ្មើរជើងឬជិះទៅកាន់ទីនោះឡើយ ក្រៅពីធ្វើដំណើរដោយទូកឬទូកកាណូតៗ ផ្លូវដែលតភ្ជាប់ពីស្ពាននេះ ទាំងមុខនឹងក្រោយគឺជាទំនប់ដ៏ធំមួយ ដែលប្រើការលែងបាននាពេលបច្ចុប្បន្នៗ នៅប្រមាណជា៣០០ម៉ែត្រពីគល់ស្ពានភាគខាងជើងគឺជាប្រឡាយដ៏ធំ ដែលតភ្ជាប់រហូតដល់ប្រទេសវៀតណាមៗ ទំនប់តាម៉ុកត្រូវបានកាត់ផ្ដាច់ត្រង់ប្រឡាយនេះនៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ដើម្បីបើកច្រកចេញចូលពីប្រទេសកម្ពុជាទៅកាន់ប្រទេសវៀតណាមៗ

## ទំនប់ តាម៉ុក

ទំនប់ តាម៉ុក ដ៏ធំត្រូវបានលើក ក្នុងរបបខ្មែរក្រហម ក្នុងស្រុកបូរីជលសារ ក្រោមការដឹកនាំរបស់តាម៉ុកៗ ទំនប់នេះ បានដាច់ដោយអន្លើៗនាពេលបច្ចុប្បន្ន និងមិនអាចធ្វើចរាចរបានឡើយៗ ពីត្រើយម្ខាងដែលជាថ្នល់ជាតិ យើងអាចមើលឃើញទំនប់

នេះ លឹមៗនៅចំកណ្ដាលវាលស្រែដ៏ធំល្វឹងល្វើយ។ បើតាមលោកអភិបាលរងស្រុក បានឲ្យដឹងថា រាជរដ្ឋាភិបាលនឹងកសាងទំនប់នេះឡើងវិញក្នុងពេលអនាគតដ៏ខ្លីៗ នៅក្បាលទំនប់នេះមានផ្ទះតូចមួយសង់នៅពីលើ ហើយនៅប្រមាណតែកន្លះគីឡូពីផ្ទះតូចនោះ មានផ្ទះតូចល្មមមួយទៀត ក៏ត្រូវបានសាងសង់ឡើងនៅជាប់នឹងគល់ស្ពានតាម៉ុក។ ក្រៅពីផ្ទះពីរខ្នងនេះ ពុំឃើញមានការសាងសង់អ្វីពីលើទំនប់នេះទៀតទេ។

## ព្រែកជីក តាម៉ុក

តភ្ជាប់ពីស្ពានតាម៉ុក យើងឃើញមានព្រែកជីកមួយដែលមានទំហំទទឹងប្រមាណ ២០ម៉ែត្រ លាតសន្ធឹងយ៉ាងវែងកាត់ពីស្រុកបូរីជលសារ រហូតដល់ស្រុកអង្គរបូរី។ ព្រែកជីកនេះ ត្រូវបានជីកឡើងនៅក្នុងឆ្នាំ១៩៧៥ ដោយកម្លាំងប្រជាជន។ ផ្ទះតាម៉ុកស្ថិតនៅចម្ងាយប្រមាណ៥០ម៉ែត្រពីព្រែកនេះ។

## ផ្ទះតាម៉ុក

ក្រៅពីផ្ទះវីឡាដ៏ធំស្កឹមស្កៃស្ថិតនៅចំកណ្ដាលផ្ទៃទឹកនាក្រុងដូនកែវ ទីរួមខេត្តតាកែវ តាម៉ុក នៅមានផ្ទះចំនួនពីរខ្នងទៀត ស្ថិតនៅដាច់សង្វែងពីភូមិប្រជាជន គឺនៅក្នុងវាលស្រែដ៏ធំល្វឹងល្វើយ ក្នុងភូមិកំពង់អំពិល ឃុំបូរីជលសារ ស្រុកបូរីជលសារ ខេត្តតាកែវ។ ផ្លូវទៅកាន់ផ្ទះតាម៉ុក គឺផ្លូវទឹក។ ផ្ទះនេះសព្វថ្ងៃនៅសេសសល់តែខឿន ជណ្ដើរ និងអាងទឹកប៉ុណ្ណោះ។ បើតាមសាក្សីជាម្ចាស់ទូកកាណូត ដែលមានអាយុ ៤៣ឆ្នាំ បានឲ្យដឹងថា គាត់ធ្លាប់មកឃ្វាលគោនៅ ទីទួលក្បែរផ្ទះតាម៉ុក កាលពីអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៩០ និងបានឃើញផ្ទះនេះស្ថិតនៅក្នុងទ្រង់ទ្រាយដើមដែលមានប្រក់ក្បឿងក្បាច់ ពាសដំបូលនិងក្ដារ និងរៀបបេតុងនៅផ្នែកខាងក្រោម។ ម្ចាស់ទូកកាណូតបានប្រាប់ថា ផ្ទះខ្នងធំជាងគេ មានទំហំប្រមាណ៨គុណនឹង ៩ម៉ែត្រ ហើយផ្ទះតូចៗនៅក្បែរផ្ទះធំ មានទំហំប្រមាណ៥គុណនឹង៦ម៉ែត្រ។ ជួបតាមទូរសព្ទជាមួយមេឃុំបូរីជលសារ លោកមេឃុំបានប្រាប់ថា តាម៉ុក ស្នាក់នៅផ្ទះនេះ ត្រឹមតែរយៈខ្លីៗ និងម្ដងម្កាលប៉ុណ្ណោះ ក្នុងពេលដែលគាត់ធ្វើដំណើរឆ្លងកាត់ទៅកាន់ស្រុកអង្គរបូរី តាមទំនប់ដ៏ធំមួយជីកដោយកម្លាំងប្រជាជនក្នុងអំឡុងពេលកាន់កាប់ដោយខ្មែរក្រហម។ ចំណែកម្ចាស់ទូក បានប្រាប់ទៀតថា ផ្ទះរបស់តាម៉ុក ត្រូវប្រជាជនរុះរើអស់គ្មានសល់នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ហើយជើងសសរផ្ទះដែលមានទំហំធំៗ ត្រូវប្រជាជននាំយកទៅប្រគេនព្រះសង្ឃក្នុងវត្តចំនួនពីរ នាស្រុកបូរីជលសារ។ លោកអភិបាលរងនៃគណៈអភិបាលស្រុកបូរីជលសារ មានប្រសាសន៍ថា ទីទួលដីអតីតផ្ទះតាម៉ុក គឺស្ថិតនៅក្រោមការកាន់កាប់ពីអាជ្ញាធរស្រុក ដើម្បីរក្សាទុកជាកេរ្ដិ៍ដំណែលប្រវត្តិសាស្ត្រនៃផ្ទះតាម៉ុក។



ព្រែកជីកតាម៉ុក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ផ្ទះតាម៉ុក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ដំណើរទស្សនកិច្ចសិក្សាស្ដីអំពី «សន្តិភាព និង សិទ្ធិមនុស្ស» មកកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង

*មេក ខិន*



សិស្សានុសិស្សមកពីវិទ្យាល័យ តេជោ សែន សំរោង ធ្វើដំណើរមកទស្សនកិច្ចសិក្សាស្ដីពី«សន្តិភាពនិងសិទ្ធិមនុស្ស» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងតំបន់ប្រវត្តិសាស្ត្រអន្លង់វែង កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំទទួលស្វាគមន៍សិស្សានុសិស្សមកពីវិទ្យាល័យ តេជោ សែន សំរោង ចំនួន២៣នាក់ ក្នុងនោះមានសិស្សស្រីចំនួន១៣នាក់ និងសិស្សប្រុសចំនួន១០នាក់។ ទស្សនកិច្ចសិក្សានេះគឺដើម្បីឈ្វេងយល់អំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង «ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង»។

សិស្សានុសិស្សមួយចំនួនបានបង្ហាញពីចំណាប់អារម្មណ៍ខ្លាំងក្នុងការធ្វើដំណើរមកកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងតំបន់ប្រវត្តិសាស្ត្រអន្លង់វែង។ ភន់ សុវណ្ណលីណាត លើកឡើងថា «តាមពិតទៅខ្ញុំមានចិត្តសប្បាយរីករាយយ៉ាងខ្លាំងនៅពេលទទួលដំណឹងថាខ្ញុំបានមកទស្សនកិច្ចសិក្សានៅតំបន់អន្លង់វែង ជាស្រុកមួយនៅក្នុងខេត្តឧត្ដរមានជ័យ ដែលមានភាពទាក់ទាញជាងគេ»។

រឿងរ៉ាវដែល សុវណ្ណលីណាត បានដឹងនោះគឺអន្លង់វែងមានតំបន់ប្រវត្តិសាស្ត្រជាច្រើនដែលបានបន្សល់ទុកពីរបបកម្ពុជាប្រជាធិបតេយ្យ។ ដំណើរទស្សនកិច្ចសិក្សានេះ គឺសិក្សាពីទីតាំងសារមន្ទីរផ្ទះ

តាម៉ុក ទីកន្លែងបូជាសពគ្រួសាររបស់ សុន សេន។ សុន សេន គឺជាមេដឹកនាំមួយរូបនៅជំនាន់ខ្មែរក្រហម ដែល មានតួនាទីគឺជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ។ សុនសេនមានប្រពន្ធឈ្មោះយុន យ៉ាត ដែលមានឈ្មោះបដិវត្តន៍ហៅថា សមមិត្ត អាត។





យុន យ៉ាត បានរៀបការជាមួយ សុន សេន ហៅខៀវ គឺជាមេដឹកនាំជាន់ខ្ពស់មួយរូបក្នុងចំណោមមេដឹកនាំដទៃទៀតរបស់របបកម្ពុជាប្រជាធិបតេយ្យ។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ បក្សកុម្មុយនីស្តកម្ពុជា យុន យ៉ាត ហៅ អាត ត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវលើកិច្ចការឃោសនាអប់រំទាំងផ្ទៃក្នុងបក្ស និងខាងក្រៅបក្ស។

ជាបន្តបន្ទាប់មកទៀតនៅឆ្នាំ១៩៧៧ យុន យ៉ាត ត្រូវបានតែងតាំងឲ្យធ្វើជារដ្ឋមន្ត្រីក្រសួងឃោសនាការ នៃកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីមានការចាប់ខ្លួនអតីតរដ្ឋមន្ត្រី ហ៊ូ នឹម។

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៩៧ សុន សេន ព្រមទាំងប្រពន្ធកូនស្រី នីសារ និងអ្នកបើកឡានរបស់គាត់ត្រូវបានបាញ់សម្លាប់យ៉ាងសាហាវឃោរឃៅ។ មិនត្រឹមតែប៉ុណ្ណោះ កូនស្រី២នាក់របស់ សុន សេន



សិស្សានុសិស្សមកពីវិទ្យាល័យ តេជោ សែន សំរោង ធ្វើដំណើរមកទស្សនកិច្ចសិក្សាស្តីពី«សន្តិភាពនិងសិទ្ធិមនុស្ស» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងតំបន់ប្រវត្តិសាស្ត្រអន្លង់វែង កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





ត្រូវបានអូសទៅរំលោភ និងសម្លាប់នៅក្បែរអូរ។

នៅក្នុងកម្មវិធីដំណើរទស្សនកិច្ចសិក្សានេះដែរ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក៏បានដឹកនាំសិស្សានុសិស្សបន្តដំណើរដោយថ្មើរជើងទៅកាន់ចេតិយរបស់ តាម៉ុក ដែលស្ថិតនៅក្នុងវត្តស្រះឈូក ដើម្បីឲ្យសិស្សានុសិស្សបានស្គាល់ និងឃើញទីតាំងផ្ទាល់។ តមកសិស្សានុសិស្សទៅទស្សនកិច្ចសិក្សាទីតាំងដុតសពរបស់ ប៉ុល ពត នៅលើខ្នងភ្នំដងរែកនៃស្រុកអន្លង់វែង។ នៅឆ្នាំ១៩៩៧ ប៉ុល ពត ត្រូវបានតាម៉ុក ចាប់ខ្លួន និងកាត់ទោសនៅចំពោះមុខតុលាការប្រជាជនដោយចោទថា ប៉ុល ពត បានបញ្ជាឲ្យសម្លាប់ សុន សេន និងក្រុមគ្រួសារ។ ប៉ុល ពត បានស្លាប់ដោយសារជំងឺចាស់ជរា នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨។

ចេញពីទីតាំងដុតសពរបស់ ប៉ុល ពត សិស្សានុសិស្សបានធ្វើដំណើរមកកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង (អតីតផ្ទះប្រជុំតាម៉ុក) នៅលើខ្នងភ្នំដងរែក ដែលបច្ចុប្បន្នត្រូវប្រែក្លាយទៅជាទីកន្លែងអប់រំអំពីសន្តិភាព និងសិទ្ធិមនុស្ស ដល់យុវជនជំនាន់ក្រោយ។

បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានរៀបរាប់នូវខ្លឹមសារសំខាន់ៗ ទាក់ទងនឹងទីតាំងនេះទៅកាន់សិស្សានុសិស្សដែលបានចូលរួមថា ផ្ទះនេះគឺជាទីកន្លែងស្នាក់នៅ និងជាទីកន្លែងជួបប្រជុំរបស់ តាម៉ុក ជាមួយមេដឹកនាំកំពូលៗរបស់ខ្មែរក្រហម ដូចជា ប៉ុល ពត, ខៀវ សំផន, នួន ជា, សុន សេន និងមេបញ្ជាការកងពលមួយចំនួនទៀត។

ម៉ា រិទ្ធី អាយុ១៨ឆ្នាំ បានបង្ហាញចំណាប់អារម្មណ៍ថា «ខ្ញុំពិតជាមានសេចក្តីត្រេកអរ និងរំភើបជាខ្លាំង នៅពេលដែលបានធ្វើដំណើរមកកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង។ ខ្ញុំចង់ដឹងពីប្រវត្តិរឿងរ៉ាវនៅទីនេះជាយូរមកហើយ។ ខ្ញុំទទួលបានចំណេះដឹងកាន់តែច្រើនអំពីតំបន់អន្លង់វែង និងមានការសោកស្តាយដែលប្រទេសជាតិធ្លាក់ចុះដោយសារតែរបបកម្ពុជាប្រជាធិបតេយ្យ»។ ខ្ញុំក៏ចាប់អារម្មណ៍ទៅលើមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៅលើខ្នងភ្នំដងរែក និងវត្តអូរក្រញូង ដោយសារតែនៅទីនោះមានទេសភាពស្រស់ស្អាតប្លែកភ្នែកជាពិសេសមានរូបបដិមាគួបផ្សំជាមួយខ្យល់ត្រជាក់ដែលធ្វើឲ្យខ្ញុំចង់មកម្តងទៀត។



សិស្សានុសិស្សមកពីវិទ្យាល័យ តេជោ សែន សំរោង ធ្វើដំណើរមកទស្សនកិច្ចសិក្សាស្តីពី«សន្តិភាពនិងសិទ្ធិមនុស្ស» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងតំបន់ប្រវត្តិសាស្ត្រអន្លង់វែង កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាប្រវត្តិសាស្ត្រ និងសុខភាព សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការ នៅស្រុកកោះសូទិន

ទូច វណ្ណាត និង លី ដេវីត



នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំវេទិកាប្រវត្តិសាស្ត្រ និងសុខភាព សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការ នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ដោយមានការចូលរួមពីលោក ឡឿន គឹមសាន មេភូមិទី៨, អ្នកគ្រូ ម៉ៅ វណ្ណា តំណាងសមាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងឃុំកោះសូទិន រួមទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០នាក់មកពីស្រុកកោះសូទិន និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃព្រហស្បតិ៍ទី២៣ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំវេទិកាប្រវត្តិសាស្ត្រ និងសុខភាព សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការ នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិនដោយមានការចូលរួមពីលោក ឡឿន គឹមសានមេភូមិទី៨, អ្នកគ្រូម៉ៅ វណ្ណា តំណាងសមាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងឃុំកោះសូទិនរួមទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០នាក់មកពីស្រុកកោះសូទិន និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។ វេទិកានេះដែលបានប្រព្រឹត្តទៅនៅក្រោយផ្ទះរបស់អ្នកភូមិទី៨ ឃុំកោះសូទិន ក្នុងគោលបំណងដើម្បីបង្កើតឲ្យមានឱកាសជួបសួរសុខទុក្ខ និងឈ្វេងយល់អំពីបទពិសោធន៍ជីវិតក្នុងរបបខ្មែរក្រហម និងស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ជាការចាប់ផ្តើម លោក ស៊ាង ចិន្តា នាយកមជ្ឈ-



មណ្ឌលឯកសារខេត្តកំពង់ចាម បានថ្លែងបើកវេទិកាដោយបានរំឭកអំពីសារសំខាន់នៃការចងចាំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលប្រជាជនកម្ពុជាឆ្លងកាត់រាល់ទុក្ខវេទនា, ការបែកបាក់គ្រួសារ និងការបាត់បង់ជីវិតៗ ផ្អែកតាមការស្រាវជ្រាវរបស់ក្រុមការងារ និងអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលបានជួបសួរសុខទុក្ខ និងសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅស្រុកកោះសូទិនចំនួនប្រហែល៣០០នាក់ មានជនរងគ្រោះជាច្រើនត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់នៅវត្តចុងកោះ ខណៈពេលដែលអ្នកភូមិផ្សេងទៀតត្រូវបានបញ្ជូនទៅធ្វើការងារផ្សេងៗនៅក្នុងកងចល័ត នៅតាមការដ្ឋាន ក្នុងនោះគឺ ការដ្ឋានឆ្ន័ត្រៗ អ្នករស់រានមានជីវិតនៅមូលដ្ឋានកោះសូទិននៅតែចងចាំមិនភ្លេចរាល់ទុក្ខវេទនា និងការបាត់បង់សមាជិកគ្រួសាររបស់ខ្លួនក្នុងរបបខ្មែរក្រហមៗ អ្នករស់រានមានជីវិតភាគច្រើនបន្តទទួលរងផលប៉ះពាល់ពីរបបខ្មែរក្រហម ទាំងសុខភាពរាងកាយ និងសុខភាពផ្លូវចិត្តៗ



នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯសារកម្ពុជា រៀបចំវេទិកាប្រវត្តិសាស្ត្រ និងសុខភាព សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការ នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ដោយមានការចូលរួមពីលោក ឡៀន គឹមសាន មេភូមិទី៨, អ្នកគ្រូ ម៉ៅ វណ្ណា តំណាងសមាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងឃុំកោះសូទិនរួមទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០នាក់មកពីស្រុកកោះសូទិន និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាៗ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាកិច្ចបន្ត លោក សោម សេរី សមាជិកក្រុមប្រឹក្សាឃុំកោះសូទិនបានថ្លែងចំណាប់អារម្មណ៍ថា វេទិកានេះគឺល្អដែលក្រុមការងារបានចុះមកជួប និងសួរសុខទុក្ខអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋាន



នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំវេទិកាប្រវត្តិសាស្ត្រ និងសុខភាព សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការ នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ដោយមានការចូលរួមពីលោក ឡឿន គឹមសាន មេភូមិទី៨, អ្នកគ្រូ ម៉ៅ វណ្ណា តំណាងសមាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងឃុំកោះសូទិន រួមទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០នាក់មកពីស្រុកកោះសូទិន និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។ ( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

កោះសូទិន ដើម្បីដឹងអំពីបទពិសោធន៍ក្នុងរបបខ្មែរក្រហម និងស្ថានភាពសុខភាព ក៏ដូចជាការផ្តោតយកចិត្តទុកដាក់ដល់ជនពិការក្នុងមូលដ្ឋាននេះ។

បន្ទាប់មក អ្នកស្រី សូ ហ្វារីណា នាយិការង មជ្ឈមណ្ឌលឯកសារកម្ពុជា បានលើកឡើងអំពីគម្រោងប្រវត្តិសាស្ត្រ និងសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលអ្នកស្ម័គ្រចិត្តកម្ពុជាបានចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទូទាំងប្រទេស។ ក្នុងជំនួបវេទិកានេះផងដែរ ក្រុមការងារនឹងផ្តោតទៅលើការចែករំលែកបទពិសោធន៍ជីវិតរបស់អ៊ំប្រុសអ៊ំស្រីក្នុងរបបខ្មែរក្រហម ស្ថានភាពសុខភាព និងតម្រូវការរបស់ជនពិការ។

អ្នកគ្រូ ម៉ៅ វណ្ណា តំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានកោះសូទិន បានថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានចុះមកជួបផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិទី៨នេះ។ អ្នកគ្រូ វណ្ណា បន្តថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅមូលដ្ឋាននេះ ដែលមានអាយុកាន់តែច្រើន និងសុខភាពកាន់តែខ្សោយ នៅតែចងចាំអំពីការរងទុក្ខវេទនា និងការស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ អ្នកគ្រូ វណ្ណា បានរំឭកអំពីរឿងរ៉ាវរបស់គាត់ដែលស្ទើរតែត្រូវបានយកទៅសម្លាប់ និងការសម្លាប់របស់ខ្មែរក្រហមទៅលើគ្រួសាររបស់គាត់ ដោយបានចាប់ចង និងសម្លាប់ទម្លាក់ចូលក្នុងទឹកទន្លេ។ អ្នកគ្រូ វណ្ណា បានបាត់បង់សមាជិកគ្រួសារជាទីស្រឡាញ់រួមមានឪពុកម្តាយ និងបងប្អូនប្រុសស្រីចំនួន៤នាក់។ ជាចុងក្រោយ អ្នកគ្រូ វណ្ណា ក៏បានលើកឡើងផងដែរអំពីស្ថានភាពចុះខ្សោយរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រួមទាំងអ្នកគ្រូផ្ទាល់ និងសារសំខាន់នៃការបន្តនិយាយប្រាប់ក្មេង

ជំនាន់ក្រោយអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងមូលដ្ឋានក្នុងរបបខ្មែរក្រហម។

អ៊ំស្រី ស៊ិន ហ៊ីម អាយុ៧៩ឆ្នាំ រស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន មានកូនប្រុសស្រីសរុបចំនួន៦នាក់ ប៉ុន្តែជាអកុសល កូនប្រុសម្នាក់របស់អ៊ំស្រីឈ្មោះ លាង បច្ចុប្បន្នអាយុ៤៥ឆ្នាំ កើតមកមិនគ្រប់ទឹកនៅឆ្នាំ១៩៨០។ នៅឆ្នាំ១៩៧៥ អ៊ំស្រី ហ៊ីម ចាប់ផ្តើមធ្វើការកងប្រវាស់ដៃដើម្បីជួយច្រូតស្រូវ និងប្រមូលផលដំណាំចែកគ្នាហូប។ នៅពេលដែលសហករណ៍ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៦ អ្នកភូមិត្រូវបានដាក់ចូលធ្វើការនៅតាមកងចល័តនៅតាមការដ្ឋានរែកដីលើកទំនប់នៅចុងកោះ។ អ៊ំស្រី ហ៊ីម ដែលនៅពេលនោះមានអាយុប្រហែល៣០ឆ្នាំ ត្រូវបានចាត់តាំងធ្វើការនៅកងចល័តនារី ដោយត្រូវងើបពីម៉ោង៤ និងចេញទៅប្រជុំជួរប្រហែលរយៈពេលកន្លះម៉ោងដើម្បីប្រាប់ពីការចាត់ចែងឲ្យទៅធ្វើការតាមគោលដៅកំណត់។ អ៊ំស្រី ហ៊ីម ត្រូវធ្វើការចាប់ពីម៉ោង៦ដល់ម៉ោង១១ទើបបានឈប់សម្រាកហូបបាយថ្ងៃត្រង់ និងបន្តធ្វើការងារចាប់ពីម៉ោង១ដល់ម៉ោង៥ល្ងាច។ នៅឆ្នាំ១៩៧៧ អ៊ំស្រី ហ៊ីម និងគ្រួសារ ត្រូវបានខ្មែរក្រហមជម្លៀសទៅល្វាឯមដោយជិះទូក។ អ៊ំស្រី ហ៊ីម បន្តធ្វើការគ្មានអាហារហូប និងពេលសម្រាកគ្រប់គ្រាន់នៅកងចល័តរួមមាន ដកស្ទូង និងច្រូតស្រូវ រហូតដល់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានចូលមករំដោះប្រជាជននៅដើមឆ្នាំ១៩៧៩។ អ៊ំស្រី ហ៊ីម បានរួចផុតពីការធ្វើការងារហួសកម្លាំង និងសេចក្តីអត់ឃ្លាននៅពេលនោះ។ នៅដើមឆ្នាំ១៩៨០ អ៊ំស្រី ហ៊ីម បានបង្កើតកូនប្រុសម្នាក់ ឈ្មោះ ឈុន លាង ដែលមានជំងឺខ្សោយបញ្ញាតាំងពីកំណើត។





នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំវេទិកាប្រវត្តិសាស្ត្រ និងសុខភាព សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនពិការ នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ដោយមានការចូលរួមពីលោក ឡឿន គឹមសាន មេភូមិទី៨, អ្នកគ្រូ ម៉ៅ វណ្ណា តំណាងសមាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងឃុំកោះសូទិន រួមទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០នាក់មកពីស្រុកកោះសូទិន និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនចុងសប្តាហ៍

## «ស្តីអំពីការរស់នៅប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចស្អៀងនៅស្រុកមេមត់ក្នុងរបបខ្មែរក្រហម»

*ឈុំ រ៉ា និង វី ស៊ីថា*



*សិស្សានុសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ក្តុលផ្សារចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍«ស្តីអំពីការរស់នៅប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចស្អៀងនៅស្រុកមេមត់ក្នុងរបបខ្មែរក្រហម» កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅវេលាម៉ោង៧:៣០នាទីព្រឹកថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣ យុវជននៅឃុំទន្លូងបានចូលរួមវេទិកាចុងសប្តាហ៍ស្តីអំពី«ការរស់នៅប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចស្អៀងនៅស្រុកមេមត់ក្នុងរបបខ្មែរក្រហម» រៀបចំដោយមជ្ឈមណ្ឌលឯកសារកោះថ្ម។ យុវជនចំនួន ២៦នាក់ ភាគច្រើនគឺជាជនជាតិដើមភាគតិចស្អៀងមកពីឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម បានដឹកនាំយុវជនដើរទស្សនាពិព័រណ៍ បណ្តុំរូបថតរូបគំនូរ និងផែនទីទាំង១៣៣នៅក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារកោះថ្ម។ បន្ទាប់មក លោក ឡុង ដានី ធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ (១៩៧៥-១៩៧៩) ស្តីអំពីការរស់នៅប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចស្អៀងនៅស្រុកមេមត់ក្នុងរបបខ្មែរក្រហម ដូចខាងក្រោម៖

**១)ការបង្កើតសហករណ៍៖** សហករណ៍គឺជាកន្លែងដែលឲ្យប្រជាជនរស់នៅជុំគ្នា ធ្វើការងាររួមគ្នា ហូបរួមគ្នា និងចែករំលែកការកំសាន្តជាសមូហភាព។ ខ្មែរក្រហមបង្កើតសហករណ៍ គឺជាផ្នែកមួយដែល



លុបបំបាត់កម្មសិទ្ធិឯកជន របបមូលធនិយម និងពង្រឹងវណ្ណៈកសិករ និងកម្មករ។ នៅឆ្នាំ១៩៧៥ ភូមិកោះថ្ម និងភូមិផ្សេងៗទៀត នៅក្នុងឃុំទន្លូង ស្រុកមេមត់ ត្រូវបានខ្មែរក្រហមបង្កើតជាសហករណ៍នៅចុងឆ្នាំ១៩៧៥និងដើមឆ្នាំ១៩៧៦។

**២) វណ្ណៈសង្គមពីរថ្មី**៖ ក) ប្រជាជនថ្មីឬប្រជាជន ១៧ មេសា គឺប្រជាជនដែលខ្មែរក្រហមជម្លៀសមកពីទីក្រុងភ្នំពេញ និងទីប្រជុំជននានាឲ្យរស់នៅទីជនបទនៅក្នុងឆ្នាំ១៩៧៥ ដើម្បីធ្វើការងារពលកម្មនៅតាមវាលស្រែ។ ខ) ប្រជាជនចាស់ឬប្រជាជនមូលដ្ឋាន គឺប្រជាជនរស់នៅតាមភូមិឃុំដែលខ្មែរក្រហមគ្រប់គ្រងតាំងពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ប្រជាជនមូលដ្ឋាន ត្រូវបែងចែកជាពីរ គឺប្រជាជនពេញសិទ្ធិ និងប្រជាជនត្រៀម។ នៅក្នុងស្រុកមេមត់ មានប្រជាជនថ្មីត្រូវខ្មែរក្រហមជម្លៀសមកពីភ្នំពេញចូលមករស់នៅតាមភូមិជាច្រើន។ ប្រជាជនថ្មីមួយចំនួនត្រូវខ្មែរក្រហមចាប់ទៅសម្លាប់ដោយចោទជាខ្មាំង និងមួយចំនួនទៀតស្លាប់ដោយសារជំងឺ។ ជនជាតិដើមភាគតិចស្មៀងត្រូវជម្លៀសចេញពីភូមិក្នុងស្រុកមេមត់នៅចុងឆ្នាំ១៩៧៧ ពីព្រោះខ្មែរក្រហម បានធ្វើសង្គ្រាមជាទ្រង់ទ្រាយធំនៅតាម





សិស្សានុសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ក្តុលផ្សារចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍«ស្តីអំពីការរស់នៅប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចស្មៀងនៅស្រុកមេមត់ក្នុងរបបខ្មែរក្រហម» កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រំដែនជាមួយប្រទេសវៀតណាម។ ជនជាតិដើមភាគតិចស្អៀង និងប្រជាជនមួយចំនួនធំត្រូវបានខ្មែរក្រហមជម្លៀសទៅរស់នៅស្រុកស្នួល ខេត្តក្រចេះធ្វើការងារពលកម្មលំបាកវេទនា អត់ឃ្លាន។ ក្រោយមកប្រជាជនទាំងអស់ត្រូវបញ្ជូនត្រឡប់មកវិញពីខេត្តក្រចេះ ដឹកតាមការណូតទៅភូមិភាគកណ្តាលក្នុងស្រុកចំការលើ និង ស្រុកបារាយណ៍។

**៣) ពិធីរៀបមង្គលការ ៖** មានរបៀបដូចជាពិធីបើកវគ្គប្រជុំ។ ពិធីរៀបការតូចមានចំនួន៣ ទៅ១០គូ ចំណែកពិធីរៀបការធំមានចំនួន ២០ ទៅ ១០០គូ។ ពិធីមង្គលការជនជាតិដើមភាគតិចស្អៀងនៅក្នុងស្រុកមេមត់ក៏ដូចជាពិធីរៀមង្គលការផ្សេងៗទៀតនៅទូទាំងប្រទេសដែរ គឺភាគច្រើនត្រូវចាប់បង្ខំជាពិសេសនារី។ ការរៀបការម្តងៗចាប់ពី១០ ទៅ២០គូ។ ឪពុកម្តាយ បងប្អូនសាច់ញាតិមិនត្រូវអនុញ្ញាតឲ្យចូលរួមឡើយ។ ខ្មែរក្រហមអនុញ្ញាតឲ្យយុវជនយុវនារី ជនជាតិដើមភាគតិចស្អៀងរៀបការមិនមែនចង់ឲ្យពួកគេបង្កើតគ្រួសារទេគឺគ្រាន់តែចង់ឲ្យពួកគេបង្កើតកូនដើម្បីធ្វើបដិវត្តន៍បន្តទៀត។

**៤) ការរំលោភលើសិទ្ធិ និងពលកម្មរបស់កុមារ ៖** នៅក្នុងរបបខ្មែរក្រហមកុមារជនជាតិដើមភាគតិចស្អៀងត្រូវបំបែកចេញពីឪពុកម្តាយ និងបង្ខំឲ្យធ្វើពលកម្មផ្សេងៗដូចលើកអាចម៍គោ កាប់ដើមទន្ទ្រានខែត្រ សម្រាប់ធ្វើជីដាក់ស្រែ។ ការរៀនសូត្រ គឺមានរយៈពេលប្រហែលមួយម៉ោងក្នុងថ្ងៃ។

**៥)ការបង្ខំឱ្យធ្វើការជាធម្ងន់ ៖** ជនជាតិដើមភាគតិចស្អៀងក៏ដូចជាប្រជាជនកម្ពុជាទូទាំងប្រទេសត្រូវខ្មែរក្រហមបង្ខំឲ្យធ្វើការងារពលកម្មនៅតាមទីវាលស្រែលើសពី១២ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ ហើយមិនមានអាហារហូបចុកគ្រប់គ្រាន់។

**៦) បន្សុទ្ធកម្ម និងការសម្លាប់រង្គាល ៖** ជនជាតិដើមភាគតិចស្អៀង ត្រូវបានចាប់យកទៅដាក់គុក ធ្វើទារុណកម្ម និងសម្លាប់ដូចប្រជាជនកម្ពុជាដទៃទៀត



សិស្សានុសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ក្តុលដង្ហារចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍«ស្តីអំពីការរស់នៅប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចស្អៀងនៅស្រុកមេមត់ក្នុងរបបខ្មែរក្រហម» កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាពិសេសនៅក្នុងឆ្នាំ១៩៧៧ និង១៩៧៨ នៅពេលដែលកងទ័ពនិងកម្មាភិបាលភូមិភាគនិរតី ចូលមកបានចាប់ជនជាតិដើមភាគតិចស្អៀងដែលធ្លាប់បម្រើការងារជាមេក្រុម មេកង មេភូមិ មេឃុំជាដើមត្រូវបានខ្មែរក្រហមចាប់ខ្លួនយកទៅរៀនសូត្រ និងបាត់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ។ នៅពេលជម្លៀសទៅរស់នៅក្នុង ស្រុកស្នួល ខេត្តក្រចេះ មានជនជាតិដើមភាគតិចស្អៀងមួយចំនួនបានស្លាប់ដោយសារធ្វើទារុណកម្ម សម្លាប់ ធ្វើការងារហួសកម្លាំង ឈឺគ្មានថ្នាំព្យាបាល និងអត់អាហារ។ បន្តមកទៀត លោក ឡុង ដានី ធ្វើបទបង្ហាញបន្ថែមលើប្រធានបទស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ការប្រើប្រាស់អំពើហិង្សា ការរើសអើង និងផលវិបាក។

មុនពេលបញ្ចប់វេទិកាថ្នាក់រៀនយុវជនមានចំណាប់អារម្មណ៍ដូចខាងក្រោម ៖

ខ្ញុំឈ្មោះ សិទ្ធី ដានីន ភេទស្រី អាយុ១៧ឆ្នាំ មក





សិស្សានុសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ក្ដុលដ្យារចូលរួមវេទិកាថ្នាក់រៀនចុងសប្ដាហ៍«ស្ដីអំពីការរស់នៅប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចស្ទៀងនៅស្រុកមេមត់ក្នុងរបបខ្មែរក្រហម» កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីវិទ្យាល័យប៊ុនរ៉ានី ហ៊ុន សែន ក្ដុលដ្យារ នៅឃុំទន្លូង ស្រុកមេមត់។ ថ្ងៃនេះខ្ញុំពិតជារំភើបចំពោះការមកទស្សនកិច្ចនៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម ព្រោះវាជាលើកទីមួយដែលខ្ញុំមកចូលរួម។ ពេលចូលមកដល់ភ្លាម ខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំង ទៅលើផ្ទាំងគំនូរ និងដែនទីដែលរៀបចំនៅមជ្ឈមណ្ឌលឯកសារកោះថ្ម គឺបង្ហាញពីអ្នករស់រានមានជីវិតដែលពួកគាត់ធ្លាប់បានឆ្លងកាត់ការលំបាកវេទនាពីរបបប្រល័យពូជសាសន៍នេះ។ មុនពេលខ្ញុំមកទស្សនកិច្ចនៅក្នុងថ្ងៃនេះ ខ្ញុំគ្រាន់តែដឹងថាខ្មែរក្រហមធ្វើឲ្យមនុស្សស្លាប់ ប៉ុន្តែមិនបានដឹងថាខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីស្រុកកំណើត ហើយឲ្យប្រជាជនធ្វើការហួសកម្លាំងពលកម្មដោយធ្វើស្រែចម្ការច្រើនម៉ោង មិនបានទទួលទានអាហារគ្រប់គ្រាន់ បណ្ដាលឲ្យកើតជំងឺ និងស្លាប់ ព្រមទាំងបំបិទវត្តអារាម សាលារៀន និងមន្ទីរពេទ្យ។ បន្ទាប់មកបានប្រែក្លាយវត្តអារាមទៅជាគុកសម្រាប់ឃុំឃាំងមនុស្ស។ ខ្ញុំបានដឹងរឿងរ៉ាវច្រើនក្រោយពេលខ្ញុំបានមកចូលរួមវេទិកាថ្នាក់រៀនចុងសប្ដាហ៍។ លោក ឡុង ដានី ធ្វើបទបង្ហាញទៅលើផ្ទាំងរូបភាពនីមួយៗធ្វើឲ្យខ្ញុំកាន់តែដឹងរឿងរ៉ាវថ្មីៗថែមទៀត ដែលពីមុនមកខ្ញុំពុំធ្លាប់បានដឹង។ ជាចុងក្រោយខ្ញុំសូមអរគុណដែលបានឲ្យខ្ញុំមានវត្តមាននៅក្នុងថ្ងៃនេះ។

ខ្ញុំឈ្មោះ អេង ដារីត ភេទប្រុស អាយុ១៧ឆ្នាំ មកពីវិទ្យាល័យប៊ុនរ៉ានី ហ៊ុន សែន ក្ដុលដ្យារ នៅឃុំទន្លូង ស្រុកមេមត់។ មុនពេលខ្ញុំចូលរួមនៅក្នុងវេទិកា ខ្ញុំពុំសូវដឹងរឿងរ៉ាវច្រើនទេ ព្រោះមិនមានអ្នកណានិយាយរៀបរាប់ប្រាប់ឡើយ។ ក្រោយពេលមកចូលរួមនៅក្នុងវេទិកានៅថ្ងៃនេះ ទើបខ្ញុំបានដឹងថាខ្មែរក្រហមបានធ្វើបាបប្រជាជនយ៉ាងឃោរឃៅបំផុត ដោយមានការជម្លៀសប្រជាជនចំនួន៣ដង លើកទី១) នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥, លើកទី២) នៅចុងឆ្នាំ១៩៧៥ និងលើកទី៣) នៅចុងឆ្នាំ១៩៧៧, ការបង្កើតសហករណ៍, លុបបំបាត់វណ្ណៈផ្សេងៗ និងការរើសអើងវណ្ណៈ។ ខ្ញុំបានដឹងផែនការ ៤ឆ្នាំរបស់ខ្មែរក្រហម, ការនាំចេញផលិតផលកសិកម្ម និងនាំចូលគ្រឿងអាវុធ គ្រឿងចក្រកសិកម្ម ការសម្លាប់អ្នកចេះដឹងនៅក្នុងប្រទេស ការរៀបចំពិធីមង្គលការដោយការបង្ខិតបង្ខំ, ការលុបបំបាត់សាសនា, សាលារៀន, ការបំបិទសិទ្ធសេរីភាពផ្សេងៗចំពោះប្រជាជន, ការប្រើប្រជាជនឲ្យធ្វើការហួសកម្លាំង និងការផ្ដល់របបអាហារឲ្យប្រជាជនហូបពុំគ្រប់គ្រាន់។ ការសម្លាប់ប្រជាជនដោយចោទថា គឺជាភ្នាក់ងារស៊ើបការណ៍របស់សហភាពសូវៀត សហរដ្ឋអាមេរិក និងវៀតណាមជាដើម។ ជាចុងក្រោយខ្ញុំចង់ឲ្យប្អូនៗជំនាន់ក្រោយបានមកចូលរួមវេទិកាថ្នាក់រៀននៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្មដូចខ្ញុំដែរ ។

# វេទិកាថ្នាក់រៀនស្តីពី

## ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)៖ ការជម្លៀសប្រជាជនដោយបង្ខំ ចេញពីទីក្រុង និងទីប្រជុំជន និងក្រុមប្រជាជនដែលត្រូវបានខ្មែរក្រហមបែងចែក»

**លី ដេវីត និង ទូច វណ្ណោត**



នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣ សិស្សានុសិស្សមកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ ថ្នាក់វិទ្យាសាស្ត្រសង្គម ចំនួន៤០នាក់បានចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលប្រព្រឹត្តទៅនៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣ សិស្សានុសិស្សមកពីវិទ្យាល័យ ឈីនលានហាន់ជ័យ ថ្នាក់វិទ្យាសាស្ត្រសង្គម ចំនួន៤០នាក់បានចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលប្រព្រឹត្តទៅនៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមៗ វេទិកាថ្នាក់រៀននេះធ្វើឡើងក្នុងគោលបំណងបង្កើនចំណេះដឹងដល់សិស្សានុសិស្សស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជានាពេលអនាគតៗ

ជាកិច្ចចាប់ផ្តើម លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ចាប់ផ្តើមធ្វើបទបង្ហាញរបស់ខ្លួនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយបានផ្តោតទៅលើព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងរបបខ្មែរក្រហមរួមមាន៖ ការចូលកាន់កាប់ទីក្រុងភ្នំពេញ,




នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣ សិស្សានុសិស្សមកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ ថ្នាក់វិទ្យាសាស្ត្រសង្គម ចំនួន៤០នាក់បានចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលប្រព្រឹត្តទៅនៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)








ការជម្លៀស ប្រជាជនដោយបង្ខំចេញ ពីទីក្រុង និងទីប្រជុំជន, ការកាប់សម្លាប់ទៅលើប្រជាជន និងជាចុងក្រោយ ដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬហៅថា សាលាក្តីខ្មែរក្រហម។ លោក ដេង ពង្សរ៉ាស៊ី ក៏បានពន្យល់បន្ថែមទៅលើនិយមន័យ និងវិធីសាស្ត្រទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងអំពើប្រល័យពូជសាសន៍។

បន្ទាប់ពីបទបង្ហាញរបស់លោក ដេង ពង្សរ៉ាស៊ី បានបញ្ចប់, លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តដឹកនាំសិស្សានុសិស្សពិភាក្សាទៅលើព្រឹត្តិ ការណ៍ ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង និងទីប្រជុំជន និង ក្រុមប្រជាជនដែលត្រូវបានខ្មែរក្រហមបែងចែក។ មិនយូរប៉ុន្មានបន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរ ក្រហមបានផ្ទុះឡើង។

ចាប់តាំងពីពាក់កណ្ដាលឆ្នាំ១៩៧០ កងទ័ពរំដោះខ្មែរក្រហមបាន វាយរំដោះភូមិ សាស្ត្រជាច្រើននៅក្នុងខេត្តកំពង់ចាម។ ប្រជាជនរស់នៅតំបន់រំដោះនៅពេលនោះ ត្រូវ បានចាត់ទុកថា ប្រជាជនចាស់ (ឬហៅថា ប្រជាជន៧០) ដែលត្រូវបាន កងទ័ពរំដោះខ្មែរ ក្រហមរំដោះចាប់តាំងពីឆ្នាំ១៩៧០។

នៅចន្លោះឆ្នាំ១៩៧២ និងឆ្នាំ ១៩៧៣ សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមផ្ទុះកាន់តែខ្លាំងឡើង ស្របពេលដែលកងទ័ពរំដោះខ្មែរក្រហមបន្តវាយ រំដោះកន្លែងជាច្រើនទៀត។ នៅពាក់កណ្ដាលឆ្នាំ១៩៧៣ កងទ័ពរំដោះខ្មែរក្រហមបានវាយចូលដល់ទីរួមខេត្តកំពង់ចាម និងបានរំដោះពាក់កណ្ដាលនៃទីរួមខេត្ត។ កងទ័ពរំដោះ ខ្មែរក្រហមបានជម្លៀសប្រជាជន ទាំងនេះចេញពីផ្ទះសម្បែងរបស់ខ្លួនឲ្យទៅនៅ ទីជនបទនានា ឬទៅរស់នៅភូមិកំណើតរបស់ខ្លួន។ ប្រជាជនដែលកងទ័ពរំដោះខ្មែរក្រហម ចូលមករំដោះបាននៅឆ្នាំ១៩៧៣ ត្រូវបានចាត់ទុកថា ប្រជាជនកណ្ដាល (ឬហៅថា ប្រជាជន៧៣)។

បន្ទាប់ពីកងទ័ពរំដោះខ្មែរក្រហមវាយរំដោះទីក្រុងភ្នំពេញ និងទីរួមខេត្តកំពង់ចាម បានទាំងស្រុង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានហៅប្រជាជនទាំងនោះ ថា ប្រជាជន៧៥ ឬ ប្រជាជន ១៧ មេសា។ ប្រជាជនថ្មីទាំងនោះត្រូវបានខ្មែរក្រហមជម្លៀសចេញពីទីក្រុង និងទីរួមខេត្តមកកាន់ភូមិនានា។ ប្រជាជនថ្មីទទួលរងការកាប់ សម្លាប់ច្រើនជាងគេ។

ជាកិច្ចបន្ត សិស្សានុសិស្សទាំងអស់បានចូលទស្សនាបណ្ណាល័យខ្មែរក្រហមដែលមានតម្កល់សៀវភៅ ទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហមរាប់ពាន់ក្បាលសម្រាប់អាន និង សម្ភារឧបទេសសម្រាប់សិស្សានុសិស្សសិក្សាស្រាវជ្រាវ។

ចុងបញ្ចប់នៃវេទិកាថ្នាក់រៀននេះ គឺការចុះទស្សនាកិច្ចសិក្សានៅចេតិយរំឭកសម្រាប់សហគមន៍ និងការជួបសន្ទនាដោយផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ សិស្សានុសិស្សបានមកដល់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍ដែលស្ថិតនៅវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម និងឈ្វេងយល់បន្ថែមអំពីទីតាំងសម្លាប់ចំនួន៣នៅក្នុងនៅឃុំគគរ រួមមាន ៖ ទំនប់គគរ, វត្តគគរ និង ឡដុតថ្នាំជក់។ ម៉ម ស្រឿន ដែលធ្លាប់ដឹក



នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣ សិស្សានុសិស្សមកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ ថ្នាក់វិទ្យាសាស្ត្រសង្គម ចំនួន៤០នាក់បានចូលរួមវេទិកាថ្នាក់រៀនស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលប្រព្រឹត្តទៅនៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣ សិស្សានុសិស្សមកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ ថ្នាក់វិទ្យាសាស្ត្រសង្គម ចំនួន៤០នាក់បានចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលប្រព្រឹត្តទៅនៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជញ្ជូនអ្នកទោសយកទៅសម្លាប់នៅការដ្ឋានទំនប់គគរ និងដឹកសម្ភារមកទុកនៅមន្ទីរសន្តិសុខគគរ ចែករំលែកហេតុការណ៍នៃការដឹកប្រជាជនខ្មែរ និងចាមក្នុងមូលដ្ឋានឃុំគគរ និងបទពិសោធន៍ជីវិតក្នុងរបបខ្មែរក្រហមទៅកាន់សិស្សានុសិស្សចូលរួមទាំងអស់។

បន្ទាប់ពីចូលរួមវេទិកាថ្នាក់រៀន យុវសិស្សបានបញ្ចេញចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម៖

សិស្ស ស្រ៊ាន ស្រីមុំ រៀនថ្នាក់ទី១២-C ផ្នែកវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ បានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនថា «ខ្ញុំទទួលបានចំណេះដឹងថ្មីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ រឿងរ៉ាវនៃការជម្លៀសប្រជាជនធ្វើឲ្យខ្ញុំនឹកដល់រឿងរ៉ាវដែលអ៊ំស្រីរបស់ខ្ញុំធ្លាប់បាននិយាយ។ អ៊ំស្រីខ្ញុំឈ្មោះ សែ យាន អាយុ៥៧ឆ្នាំ ធ្លាប់ប្រាប់ខ្ញុំពីការរត់គេចពីគ្រាប់ផ្លោង ការរស់នៅក្នុងតំបន់រំដោះ ការធ្វើការងារលំបាកវេទនា និងការហូបចុកមិនគ្រប់គ្រាន់។ បន្ទាប់ពីចូលរួមវេទិកាថ្នាក់រៀននេះ ខ្ញុំនឹងយកអ្វីដែលខ្ញុំទទួលបានទៅសួរអ៊ំស្រី យាន បន្ថែម»។

សិស្ស ហែម រដ្ឋា រៀនថ្នាក់ទី១២-C ផ្នែកវិទ្យាសាស្ត្រសង្គមនៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ បានរៀបរាប់ថា «ខ្ញុំទទួលបានចំណេះដឹងលើសពីអ្វីដែលខ្ញុំរំពឹងទុកចេញពីការធ្វើបទបង្ហាញរបស់លោកគ្រូៗ និងការស្តាប់សាច់រឿងរបស់អ៊ំប្រុសដែលរស់រានមានជីវិតពីរបបខ្មែរក្រហម។ នៅពេលដែលខ្ញុំស្តាប់ឮអំពីការជម្លៀសប្រជាជនក្នុងរបបខ្មែរក្រហម ខ្ញុំនឹកឃើញដល់យាយរបស់ខ្ញុំឈ្មោះ អ៊ុម យឿន អាយុ៧៥ ដែលធ្លាប់និយាយប្រាប់ខ្ញុំអំពីការរត់គេចក្នុងអំឡុងពេលសង្គ្រាម និងការឃើញប្រជាជនជម្លៀសមកពីទីរួមខេត្តកំពង់ចាម និងទីក្រុងភ្នំពេញ។ ខ្ញុំមានការអាណិតអាសូរដល់ប្រជាជនដែលរងទុក្ខវេទនាពីសង្គ្រាម និងបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម»។

សិស្ស ហ៊ាង លីស៊ីង រៀនថ្នាក់ទី១២-C ផ្នែកវិទ្យាសាស្ត្រសង្គមនៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ បង្ហាញទស្សនយល់ឃើញរបស់ខ្លួនចំពោះវេទិកាថ្នាក់រៀននេះថា «ខ្ញុំទទួលបានចំណេះដឹងថ្មីៗអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ពីការធ្វើបទបង្ហាញរបស់វាគ្មិន និងការទស្សនារូបភាពប្រវត្តិសាស្ត្រជាច្រើន។ ខ្ញុំធ្លាប់ស្តាប់ការនិយាយប្រាប់ពីយាយរបស់ខ្ញុំឈ្មោះ ធាង យេត អាយុ៧៧ឆ្នាំ ដែលរស់នៅភូមិកោះពីរ ឃុំកោះពីរ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។ យាយរបស់ខ្ញុំរៀបរាប់ពីការជម្លៀសក្រុមគ្រួសារទៅខេត្តបាត់ដំបង។ នៅពេលនោះ គាត់បានបែកបាក់គ្រួសារបងប្អូន និងស្លាប់អស់កូនចំនួន៦នាក់ ដោយសារតែគ្មានអាហារហូបចុកគ្រប់គ្រាន់។ ក្នុងនាមជាយុវជនជំនាន់ក្រោយ ខ្ញុំនឹងខិតខំរៀនសូត្រ និងចូលរួមទប់ស្កាត់កុំឲ្យរបបនេះវិលមកវិញម្តងទៀត»។



នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣ សិស្សានុសិស្សមកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ ថ្នាក់វិទ្យាសាស្ត្រសង្គម ចំនួន៤០នាក់បានចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលប្រព្រឹត្តទៅនៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនស្តីពី

## ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅស្រុកអន្លង់វែងការយល់ដឹងពីរឿងរ៉ាវប្រវត្តិសាស្ត្រ គឺដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍

**ស្លូត វិចិត្រ**



*សិស្សានុសិស្សចំនួន២៦នាក់ ក្នុងនោះមានសិស្សប្រុស១២នាក់ និងស្រី១៤នាក់ នៃវិទ្យាល័យអន្លង់វែង ចូលរួមនៅក្នុងវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

សិស្សានុសិស្សចំនួន២៦នាក់ ក្នុងនោះមានសិស្សប្រុស១២នាក់ និងស្រី១៤នាក់ នៃវិទ្យាល័យអន្លង់វែង បានចូលរួមនៅក្នុងវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣។ វេទិកាថ្នាក់រៀននេះ មានគោលបំណងលើកកម្ពស់ការយល់ដឹងដល់យុវជនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត។

លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើបទបង្ហាញផ្តោតទៅលើហេតុការណ៍ដែលបានកើតឡើងនាជំនាន់ខ្មែរក្រហម រួមមាន ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីប្រជុំជន ការធ្វើទារុណកម្ម និងការសម្លាប់រង្គាលទៅលើប្រជាជន និងមន្ត្រីរដ្ឋការ លន់នល់ ព្រមទាំងទិដ្ឋភាពផ្លូវច្បាប់នៅក្នុងដំណើរការនៃអង្គជំនុំជម្រះ

វិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬតុលាការខ្មែរក្រហម ដែលបានកាត់ទោសទៅលើមេដឹកនាំកំពូលៗ ឬអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបខ្មែរក្រហម។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបខ្មែរក្រហមបានជម្លៀសប្រជាជនទ្រង់ទ្រាយធំលើកដំបូង និងបានសម្លាប់រង្គាលទៅលើទាហាន នល់ នល់ និងអ្នកដែលពាក់ព័ន្ធនឹងរបបនេះ។ ទួលពោធិ៍ជ្រៃ គឺជាទីវាលដែលស្ថិតនៅកៀកនឹងទន្លេសាប ព្រៃនាម និងត្រូវបានស្គាល់ថា ជាទីកន្លែងដែលខ្មែរក្រហមកាប់សម្លាប់ទៅលើទាហាន លន់ នល់ និងប្រជាជនស៊ីវិលរាប់ពាន់នាក់។ មានការប៉ាន់ប្រមាណថា ទាហាន នល់ នល់ ចន្លោះពី ២ ០០០នាក់ ទៅ ៨០០០ នាក់ ត្រូវបានសម្លាប់នៅទីនោះ។ សិស្សម្នាក់ចោទសួរនៅក្នុងវេទិកាថា ហេតុអ្វីបានជាខ្មែរក្រហមបានដាក់គោលដៅនៃការសម្លាប់ទៅលើទាហាន និងមន្ត្រីរដ្ឋការក្នុងរបប លន់ នល់?

នៅក្នុងដំណើរការស្វែងរកយុត្តិធម៌ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបែងចែកសំណុំរឿងដាច់ដោយឡែកពីគ្នារួមមាន៖ សំណុំរឿង ០០១, ០០២, ០០៣ និង ០០៤ ។ សំណុំរឿង ០០១ ពាក់ព័ន្ធនឹងការជម្រះក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធានមន្ទីរសន្តិសុខស-២១។ អ្នកទោសប្រមាណជាង១ម៉ឺននាក់ត្រូវបានធ្វើទារុណកម្មនៅក្នុងមន្ទីរស-២១ និងយកទៅសម្លាប់នៅវាលពិឃាដបឹងជើងឯក។

នៅក្នុងឆ្នាំ១៩៩៩ ឌុច ត្រូវបានចាប់ខ្លួនពីសំណាក់អាជ្ញាធរកម្ពុជា និងបញ្ជូនទៅឃុំឃាំងក្នុងតុលាការយោធារហូតដល់ឆ្នាំ២០០៧ មុនពេលបញ្ជូនខ្លួនទៅកាន់មន្ទីរឃុំឃាំងបណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមដីកាបង្គាប់របស់ចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿង ០០១។ នៅខែសីហា ឆ្នាំ២០០៨ ឌុច ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋព្រហ្មទណ្ឌ ហើយការជម្រះក្តីផ្នែកសំខាន់ៗត្រូវបានធ្វើឡើងនៅឆ្នាំ២០០៩។ នៅខែកក្កដា ឆ្នាំ២០១០ ឌុចត្រូវបានជម្រះក្តីនៅសាលាដំបូង។ នៅទីបំផុត ឌុច ត្រូវបានតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុង





សិស្សានុសិស្សចំនួន២៦នាក់ ក្នុងនោះមានសិស្សប្រុស១២នាក់ និងស្រី១៤នាក់ នៃវិទ្យាល័យអន្លង់វែង ចូលរួមនៅក្នុងវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ហ្សីណៃវឆ្នាំ១៩៨៩។ ឌុចបានស្លាប់ដោយសារជំងឺរលាកទងសួត នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត កាលពីខែកញ្ញា ឆ្នាំ២០២០។

សំណុំរឿង០០២ ពាក់ព័ន្ធនឹងបទចោទប្រកាន់ទៅលើ អៀង សារី, នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ។ សំណុំរឿង០០២ វគ្គ០២ ៖ នៅខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះវិសាមញ្ញ បានបើកសវនាការជាលើកដំបូង ដើម្បីជំនុំជម្រះលើសំណុំរឿង០០២ វគ្គ០២ ដោយផ្តោតទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តឡើងនៅសហករណ៍ ការដ្ឋានការងារ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សមួយចំនួនដែលជាប់ទាក់ទងនឹងក្រុមគោលដៅជាក់លាក់ ដូចជា ជនជាតិចាម វៀតណាម អ្នកកាន់ព្រះពុទ្ធសាសនា និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ នៅក្នុងសំណុំរឿង០០២ វគ្គ០២ នេះ មានតែ ខៀវ សំផន ប៉ុណ្ណោះដែលនៅរស់រានមានជីវិតនៅក្នុងពន្ធនាគារ បន្ទាប់ពី នួន ជា បានស្លាប់កាលពីថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩កន្លងទៅ។

សំណុំរឿង ០០៣ និង០០៤ ត្រូវបានបង្កើតឡើងនៅខែកញ្ញា ឆ្នាំ២០០៩ នៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាបញ្ជូនឲ្យស៊ើបសួរទៅកាន់សហចៅក្រមស៊ើបអង្កេត ស្នើឲ្យមានការស៊ើបអង្កេតលើឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងជនសង្ស័យចំនួន៥រូប រួមមាន មាស មុត និង ស៊ូ មេត ត្រូវបានដាក់បញ្ចូលឈ្មោះថា ជាជនសង្ស័យក្នុងសំណុំរឿង០០៣។ ចំណែកឯ អោ អាន, អ៊ឹម ចែម និង យឹម ទិត្យ ត្រូវបានដាក់បញ្ចូលឈ្មោះថាជាជនសង្ស័យក្នុងសំណុំរឿង០០៤។ ដោយឈរលើមូលដ្ឋានថាខ្វះដែនសមត្ថកិច្ចក្នុងការអនុវត្ត អង្គបុរេជំនុំជម្រះបានសម្រេចទម្លាក់ចោលការចោទប្រកាន់ទៅលើបុគ្គលខាងលើនេះ។

នៅផ្នែកចុងក្រោយនៃវេទិកា គឺវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ត្រូវបានបង្ហាញដល់សិស្សានុសិស្ស។ សិស្សម្នាក់ក្នុងចំណោម២៦នាក់យល់ឃើញថា ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ គឺផ្តើមចេញពីការមិនគាំទ្រនូវសកម្មភាពរើសអើង ឈ្វេងយល់ពីរឿងរ៉ាវប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍ក្នុងសង្គម និងមិនគាំទ្រដល់ការបង្កើតឲ្យមានរបបកុម្មុយនីស្ត។







សិស្សានុសិស្សចំនួន២៦នាក់ ក្នុងនោះមានសិស្សប្រុស១២នាក់ និងស្រី១៤នាក់ នៃវិទ្យាល័យអន្លង់វែង បចូលរួមនៅក្នុងវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាអប់រំសហគមន៍ស្តីពី

## ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅស្រុកកោះសូទិន ៖ «ការងារមួយថ្ងៃនៅកងចល័តក្នុងរបបខ្មែរក្រហម»

*ទូច វណ្ណាត និង លី ដេវីត*



*នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំ សហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការងារមួយ ថ្ងៃនៅកងចល័តក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីលោក សោម សេរី និង លោក លឹម ផល្លី សមាជិកក្រុមប្រឹក្សាឃុំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវសិស្សមកពីវិទ្យាល័យកោះសូទិនៗ (លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំ សហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការងារមួយ ថ្ងៃនៅកងចល័តក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីលោក សោម សេរី និង លោក លឹម ផល្លី សមាជិកក្រុមប្រឹក្សាឃុំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សមកពីវិទ្យាល័យកោះសូទិនៗ វេទិកាអប់រំសហគមន៍ រៀបចំឡើងនៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ក្នុងគោលបំណងដើម្បីបង្កើតឱកាសឲ្យមានកិច្ចសន្ទនាអន្តរជំនាន់រវាងអ្នកកើតមុន និងក្រោយរបបខ្មែរក្រហម រួមទាំងជំរុញឲ្យមានការយល់ដឹងអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងសហគមន៍របស់ខ្លួនក្នុងរបបខ្មែរក្រហមៗ

ចាប់ផ្តើមកម្មវិធី លោក សោម សេរី សមាជិកក្រុមប្រឹក្សាឃុំ បានឡើងនិយាយបើកវេទិកាអប់រំសហគមន៍ និងប្រាប់អំពីសារសំខាន់ក្នុងការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហមដែលប្រជាជនកម្ពុជាឆ្លងកាត់រាល់ទុក្ខវេទនា, ការបែកបាក់គ្រួសារ, ការបាត់បង់



នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការងារមួយថ្ងៃនៅកងចល័តក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីលោក សោម សេរី និង លោក លឹម ផល្លី សមាជិកក្រុមប្រឹក្សាឃុំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវសិស្សមកពីវិទ្យាល័យកោះសូទិន។ (លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)





ជីវិតដោយសារតែសង្គ្រាម និងអំពើប្រល័យពូជសាសន៍។ សមាជិកក្រុមប្រឹក្សាឃុំរំឭកទៅកាន់យុវសិស្សអំពីការជម្លៀសចេញពីគ្រួសារ ការបង្ខំឲ្យធ្វើការនៅតាមការដ្ឋានទំនប់ និងការរៀបការនៅវត្តស្លូនពេជ្រ។ ពេលវេលា និងសកម្មភាពទាំងនេះក្នុងរបបខ្មែរក្រហមគឺនៅតែស្ថិតក្នុងការចងចាំរបស់គាត់។ បន្ទាប់ពីនិយាយបើកវេទិកាអប់រំសហគមន៍ លោក សោម សេរី លើកទឹកចិត្តដល់យុវសិស្សឲ្យខិតខំរៀនសូត្រ និងចូលរួមថែរក្សាសុខសន្តិភាព។

លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានធ្វើបទបង្ហាញស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់ពីធ្វើបទបង្ហាញចប់ លោក ស៊ាង ចិន្តា ដឹកនាំកិច្ចពិភាក្សាទៅលើប្រធានបទស្តីអំពី«ការងារមួយថ្ងៃក្នុងកងចល័តនៅក្នុងរបបខ្មែរក្រហម។» សិស្សត្រូវបានបែងចែកទៅជា៣ក្រុម ដែលក្រុមនីមួយៗទទួលបានប្រធានបទពិភាក្សារៀងៗខ្លួន និងការជួបសន្ទនាផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ក្រុមនីមួយៗមានរយៈពេល៣០នាទីដើម្បីពិភាក្សាដោយ មានការចូលរួមផ្តល់សក្ខីកម្មរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអំពីបទពិសោធន៍របស់ខ្លួន។

តំណាងក្រុមពិភាក្សានីមួយបានឡើងធ្វើបទបង្ហាញពីប្រធានបទរបស់ខ្លួន និងអំពីអ្វីដែលខ្លួនបានពិភាក្សា និងដឹងពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដូចខាងក្រោម៖

• ក្រុមទី១ ដែលមានសមាជិកក្រុមរួមមាន ញឹម បញ្ញា, មុយ ចាន់លាប, ស៊ុបអ៊ី រីណា, ឡាយ ម៉េងគាង, ឈី រក្សា, អ៊ឹម ឆេងសៀវ និង លី ស្រីពៅ ទទួលបានប្រធានបទស្តីពី «ការធ្វើការងារនៅការដ្ឋានឆ្ល័ត្រ»។ ក្រុមទី១ បានសង្ខេបអ្វីដែលខ្លួនពិភាក្សា និងដឹងពីការរៀបរាប់ពីបទពិសោធន៍របស់ លោក ឡឿន គឹមសាន៖

«នៅដើមឆ្នាំ១៩៧៦ ខ្មែរក្រហមបានរៀបផែនការបួនឆ្នាំលើកទី១ ពីឆ្នាំ១៩៧៧-១៩៨០។ ដើម្បីសម្រេចគោលបំណងផែនការបួនឆ្នាំ ខ្មែរក្រហមបង្ខំឲ្យប្រជាជនធ្វើការនៅតាមការដ្ឋានលើកទំនប់ និងធ្វើស្រែ។ លោក ឡឿន គឹមសាន គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងធ្លាប់ធ្វើការនៅការដ្ឋានឆ្ល័ត្របាននិយាយថា នៅឆ្នាំ១៩៧៦ គឺជាការចាប់ផ្តើមបង្កើតសហករណ៍ និងការធ្វើការ នៅកងចល័តនៅតាមការដ្ឋាន។ គឹមសាន ត្រូវបញ្ជូនទៅធ្វើការនៅកងចល័តរយដែលមាន ទិសដៅធ្វើស្រែ និងលើកទំនប់នៅការដ្ឋានឆ្ល័ត្រ។ គឹមសាន ត្រូវងើបពីម៉ោង៤ និងចូលប្រជុំជួររយៈពេលមួយម៉ោង។ ការងារចាប់ផ្តើមធ្វើពីម៉ោង៦ព្រឹកដល់ម៉ោង១១ និងពីម៉ោង ១ដល់ម៉ោង ៥រសៀល។ ម៉ោង ៦ដល់ម៉ោង៧ ល្ងាចគឺជាម៉ោងធ្វើការងារសង្គមនិយម ដែល គឹមសាន និងសមមិត្តផ្សេងទៀត ត្រូវទៅកាប់ទន្រ្ទានខែត្រនិងកំប្លោកដើម្បីយកមកធ្វើជាជី។ នេះគឺជាការរៀបរាប់ការងារពេញមួយថ្ងៃរបស់ គឹមសាន ក្នុងកងចល័តនៅការដ្ឋានឆ្ល័ត្រនៅក្នុងរបបខ្មែរក្រហម»។

• ក្រុមទី២ដែលមានសមាជិកក្រុមរួមមាន សូទី អាស៊ីរ៉ស៍,រ៉សាត់រ៉ស៊ីសាស់, បូមយូរ័ត្ន, ភិនចាន់ថេង, លី ស្រីមី, រិទ្ធីស្រីណែត និង ឡឿន ស្រីរី ទទួលបានប្រធានបទស្តីពី «ការភ្ជួរដីស្រែនៅការដ្ឋានឆ្ល័ត្រ»។ ក្រុមទី២បានសង្ខេបសាច់រឿងដែលខ្លួនពិភាក្សា និងដឹងពីការរៀបរាប់ពីបទពិសោធន៍របស់ អានរី៖

«ប្រជាជនត្រូវបានចាត់ចូលធ្វើការងារនៅតាមកងចល័តក្នុងរបបខ្មែរក្រហម ដើម្បីធ្វើការភ្ជួររាស់ លើកទំនប់ និងដាំដំណាំផ្សេងៗ។ អានរី ត្រូវបញ្ជូនទៅធ្វើស្រែនៅការដ្ឋានឆ្ល័ត្រនៅក្នុងឆ្នាំ១៩៧៦។ នៅរដូវវស្សា អានរី ត្រូវបានចាត់តាំងឲ្យកាន់គោមួយនឹម និងភ្ជួររាស់នៅលើវាលស្រែឆ្ល័ត្រដែលមាន ផ្ទៃដីទំហំប្រមាណ៥០០ហិកតា។ អានរី ត្រូវក្រោកតាំងពីម៉ោង៤ទៀបភ្លឺ និងទៅប្រជុំជួរ។ បន្ទាប់មក អានរី បររទេះគោទៅភ្ជួរដីស្រែ។ នៅកន្លែងភ្ជួរមានគោសរុបចំនួនប្រាំនឹមសម្រាប់ធ្វើការភ្ជួររាស់ដីស្រែចំនួន១ហិកតា។ អានរី ចាប់ផ្តើមភ្ជួរដីចាប់ពីម៉ោង៧ព្រឹកដល់ម៉ោង១០ព្រឹក។ បន្ទាប់មក អានរី សម្រាកហូបបបរ និងយកគោទៅឲ្យស៊ីស្មៅរហូតដល់ម៉ោង៤ល្ងាចទើបទៅយកមកវិញ។ នៅរដូវប្រាំង អានរី ត្រូវចាត់តាំងឲ្យទៅដឹកខសនៅពាមដាំងដើម្បីយកមកដាក់នៅរោងបាយ»។

• ក្រុមទី ៣ ដែលមានសមាជិកក្រុមរួមមាន សំ វិច្ឆិកា, ថុល សុធានី, ហួ សុវណ្ណរី, អ៊ី លក្ខអាលីហ្សា, វង សុខមាន និង អេស ម៉ានីស ទទួលបានប្រធានបទស្តីពី«ការងារក្នុងកងចល័តនារីឈានមុខ» ក្រុមទី៣ បានសង្ខេបអ្វីដែលខ្លួនពិភាក្សានិងដឹងពីការរៀបរាប់ពីបទពិសោធន៍របស់ អានរី៖

«បន្ទាប់ពីខ្មែរក្រហមដាក់ចេញផែនការបួនឆ្នាំ ប្រជាជនទទួលរងការធ្វើការហួសកម្លាំង និងហូបមិនគ្រប់គ្រាន់។ ចេង សុថុល អាយុ៦១ឆ្នាំរស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន លើកឡើងថា៖ នៅឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសចេញពីភូមិទៅពាមជីកង ដោយជិះទូក និងមិនមានកន្លែងស្នាក់នៅ។ ខ្ញុំដេកនៅព្រៃចេករយៈពេល ២០ថ្ងៃ ទើបមានឡានបន្តដឹកទៅតាំងគោក។ នៅពេលទៅដល់តាំងគោក ឪពុកម្តាយរបស់ខ្ញុំត្រូវដាក់ឲ្យធ្វើការងារប្រមូលស្រូវនៅការដ្ឋានស្នែងទង ក្នុងសង្កាត់ស្វាយភ្លើង។ ខ្ញុំត្រូវទៅបេះត្រកួនយកមកហូប។ នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវដាក់ឲ្យធ្វើការនៅកងចល័តឈានមុខដើម្បីវែកដីនៅការដ្ឋានកំពង់ត្របែក។





នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំ សហគមន៍ស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការងារមួយ ថ្ងៃនៅកងចល័តក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីលោក សោម សេរី និង លោក លឹម ផល្លី សមាជិកក្រុមប្រឹក្សាឃុំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវសិស្សមកពីវិទ្យាល័យកោះសូទិន។ (លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅពេលនោះមានសមាជិកចំនួន ១០០នាក់ ។ ខ្ញុំត្រូវក្រោកចាប់ពីម៉ោង៥ទៀបភ្លឺដើម្បីដើរទៅប្រជុំជួរ និងបន្ទាប់មកទៅធ្វើការតាមផែនការដាក់ឲ្យ។ ខ្ញុំនិងសមមិត្តនារីផ្សេងទៀតត្រូវស្លៀកពាក់ខោអាវពណ៌ខ្មៅ និងក្រមាពណ៌ខៀវ និងពាក់ស្បែកជើងកង់ឡាន។ បន្ទាប់ពីធ្វើការនៅការដ្ឋាននៅពេលថ្ងៃរួច ខ្ញុំត្រូវបន្តធ្វើការងារនៅពេលយប់ចាប់ពីម៉ោង៨ ទៅម៉ោង៩យប់ គឺបាតុកម្មវាយកណ្ដុរ។ ខ្ញុំធ្វើការនៅកងចល័តនារីឈានមុខនៅការដ្ឋានកំពង់ត្របែករហូតដល់ឆ្នាំ ១៩៧៩។ បន្ទាប់ពីរបប ប៉ុល ពត ដួលរំលំ ខ្ញុំវិលត្រឡប់មករស់នៅភូមិកំណើតវិញ»។

បន្ទាប់ពីការឡើងធ្វើបទបង្ហាញរបស់ក្រុមនីមួយៗ បានបញ្ចប់ លោក ស៊ាង ចិន្ដា បន្តដឹកនាំកិច្ចពិភាក្សាទូទៅ និងបកស្រាយសំណួររបស់យុវសិស្សទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម។ ជាចុងក្រោយ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានចែកសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)» ជាភាសាខ្មែរបោះពុម្ពលើកទី២ និងទស្សនាវដ្ដីស្វែងរកការពិតដល់សិស្សនិងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទុកជាឯកសារផ្ទាល់ខ្លួន និងដើម្បីធ្វើការឈ្វេងយល់បន្ថែមពី ប្រវត្តិសាស្ត្រនេះ។

នៅពេលរសៀល អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សទៅមើលចេតិយរំឭកសម្រាប់សហគមន៍ និងទីតាំងសម្លាប់ប្រជាជនខ្មែរ និងចាម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សទទួលបានការស្វាគមន៍ដោយ លោក តុង សុភា តំណាងសមាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានឃុំគគរ។ លោក តុង សុភា ក៏បានរៀបរាប់ពីព្រឹត្តិការណ៍នៃការសម្លាប់ប្រជាជននៅ ក្នុងរបបខ្មែរក្រហមនៅក្នុងភូមិឃុំរបស់គាត់។

# វេទិកាសហគមន៍នៅក្នុងភូមិទួលប្រាសាទ

**ហ៊ាន ពិសី**



មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាសហគមន៍មួយនៅក្នុងភូមិទួលប្រាសាទ នៃស្រុកអន្លង់វែង ដោយផ្ដោតទៅលើ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងដំណើរការនៃការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំវេទិកាសហគមន៍មួយនៅក្នុងភូមិទួលប្រាសាទ នៃស្រុកអន្លង់វែង ដោយផ្ដោតទៅលើ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងដំណើរការនៃការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា»។ វេទិកាសហគមន៍នេះត្រូវបានធ្វើឡើងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ ក្នុងសាលាឆទានមួយនៃភូមិទួលប្រាសាទ ដោយមានការចូលរួមពីប្រជាជនចំនួន២៧ នាក់រាប់បញ្ចូល ទាំងកុមារ ដែលមានស្រី ១៥នាក់ និងប្រុស ១៣នាក់។ ភូមិទួលប្រាសាទនេះ ក៏ត្រូវបានស្គាល់ថាជាភូមិចំណាស់មួយ ស្ថិតនៅក្នុងស្រុកអន្លង់វែង ដែលមានប្រជាជនរស់នៅសរុបចំនួន៨៨ គ្រួសារ។ ភាគច្រើនប្រជាជននៅទីនោះ រស់នៅពឹងផ្អែកទៅលើរបរកសិកម្ម និងការធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត។

បណ្ឌិត លី សុខឃាង ដែលជាអ្នកដឹកនាំនៅក្នុងការពិភាក្សានេះបានលើកយកនូវរឿងរ៉ាវទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)។ ក្រោយពេលដែលទទួលបានជ័យជម្នះនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានធ្វើការជម្លៀសប្រជាជនយ៉ាងបន្ទាន់ចេញដោយពីទី

ក្រុងទៅកាន់ទីជនបទៗ ក្នុងការដឹកនាំបែបផ្តាច់ការនៃរបបនេះ បានធ្វើឲ្យប្រជាជនខ្មែរជាង២លាននាក់ត្រូវបានស្លាប់ ដោយសារការធ្វើទារុណកម្ម ការធ្វើការងារដោយបង្ខំ និងការបង្អត់អាហារៗ បន្ទាប់ពីរបបនេះត្រូវបានដួលរលំអ្នកស្រាវជ្រាវបានរកឃើញថាមានរណ្តៅសាកសពជិត ២ម៉ឺនរណ្តៅ នៅទូទាំងប្រទេសកម្ពុជាដែលសេសសល់ក្រោយសម័យសង្គ្រាមៗ ដំណើរការនៃការស្វែងរកយុត្តិធម៌ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកម្ពុជាឬហៅកាត់ថា អ.វ.ត.ក បានធ្វើការកាត់ក្តីទៅលើមេដឹកនាំកំពូលនៃរបបកម្ពុជាប្រជាធិបតេយ្យនេះ ដោយបែងចែកជាសំណុំរឿង០០១, ០០២, ០០៣ និង០០៤ៗ នៅខែកញ្ញា ឆ្នាំ២០២២ ដំណើរការនៃការស្វែងរកយុត្តិធម៌នេះក៏ត្រូវបានបិទបញ្ចប់ជាស្ថាពរ បន្ទាប់ពីតុលាការធ្វើការកាត់ទោសឲ្យ ខៀវ សំផន ដែលជាអតីតមេដឹកនាំខ្មែរក្រហមតែម្នាក់គត់ដែលនៅរស់ឲ្យជាប់ពន្ធធានាអស់មួយជីវិតៗ ក្នុងអំឡុងពេលនៃការធ្វើបទបង្ហាញនេះ សង្កេតឃើញថាប្រជាជនមួយចំនួននៅក្នុងភូមិស្គាល់ឈ្មោះមេដឹកនាំខ្មែរក្រហមជាច្រើនបានយ៉ាងច្បាស់ដូចជា ប៉ុល ពត, នួន ជា, ខៀវ សំផន, អៀង សារី និងមេដឹកនាំផ្សេងទៀតៗ





មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាសហគមន៍មួយនៅក្នុងភូមិទួលប្រាសាទ នៃស្រុកអន្លង់វែង ដោយផ្តោតទៅលើ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងដំណើរការនៃការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជា» នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តាមរយៈការពិភាក្សាអំពីកេរដំណែលនៃតុលាការខ្មែរក្រហម បានបង្ហាញឲ្យឃើញថា ភាពស្មើគ្នាចំពោះមុខច្បាប់ គឺមានសារសំខាន់ណាស់សម្រាប់ប្រជាជនគ្រប់រូបៗ មិនតែប៉ុណ្ណោះវេទិកានេះក៏បានផ្តល់ឱកាសឲ្យប្រជាជនធ្វើការចែករំលែកអំពីបទពិសោធជីវិតដែលខ្លួនធ្លាប់បានឆ្លងកាត់នៅក្នុងសម័យសង្គ្រាម រួមទាំងការជជែកពីបញ្ហាផ្សេងៗដែលប្រឈមនៅក្នុងសហគមន៍ៗ ប្រជាជនក៏បានលើកយកបញ្ហាប្រឈមចម្បងបំផុតចំពោះភូមិទួលប្រាសាទគឺស្ពានផ្លូវដែលជារៀងរាល់ឆ្នាំត្រូវបានជន់លិច និងខូចខាតដោយសារកម្លាំងទឹកហូរនាពេលរដូវវស្សាៗ បញ្ហានេះបានធ្វើឲ្យប្រជាជនមានការលំបាក ជាពិសេសកុមារមិនអាចធ្វើដំណើរទៅរៀនបានៗ ក្នុងនោះប្រជាជនក៏បានលើកយកអំពីវិធីក្នុងការដឹកចម្លងអ្នកជំងឺឆ្លងទឹកតាមបែបបុរាណ ដែលខ្លួនធ្លាប់បានអនុវត្តនៅក្នុងអំឡុងពេលមានសង្គ្រាមៗ ប្រជាជនបានយកតង់កៅស៊ូចងក្របួចទាំងសងខាងឲ្យមានរាងដូចជាទូក រួចយកស្លឹកឈើដាក់នៅក្នុងតង់កៅស៊ូនោះ ហើយឲ្យអ្នកជំងឺដេកនៅពីលើៗ បន្ទាប់មកត្រូវសែងតង់កៅស៊ូដែលមានមនុស្សដេកនោះ ទៅដាក់បណ្តែតលើទឹកដោយមានអ្នកហែលទប់នៅត្រង់កន្លែងចងក្របួចទាំងសងខាងនោះដើម្បីកុំឲ្យលិចៗ ចុងបញ្ចប់នៃកម្មវិធីនេះប្រជាជនក៏បានលើកជាសំណើរមកកាន់ក្រុមការងារដើម្បីអំពាវនាវឲ្យមានការជួយឧបត្ថមជាទូកដរមួយគ្រឿង ទុកចម្លងប្រជាជនក្នុងគ្រាមានអាសន្នឬពេលរដូវទឹកឡើងៗ

# វេទិកាអប់រំសហគមន៍ នៅវត្តខ្សាច់រកកោះ

ផេង ពង្សរ៉ាស៊ី



*វេទិកាអប់រំសហគមន៍ស្តីពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម ដែលជាការរៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ក្រោមកិច្ចសហការពីអាជ្ញាធរមូលដ្ឋានឃុំដូងខ្ពស់ និងគណៈកម្មការវត្តខ្សាច់រកកោះ ត្រូវបានប្រារព្ធធ្វើនៅក្នុងបរិវេណវត្តខ្សាច់រកកោះ ភូមិតាសែ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ នៅព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

វេទិកាអប់រំសហគមន៍ស្តីពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម ដែលជាការរៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ក្រោមកិច្ចសហការពីអាជ្ញាធរមូលដ្ឋានឃុំដូងខ្ពស់ និងគណៈកម្មការវត្តខ្សាច់រកកោះ ត្រូវបានប្រារព្ធធ្វើនៅក្នុងបរិវេណវត្តខ្សាច់រកកោះ ភូមិតាសែ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ នៅព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣ ដោយមានការចូលរួមពីព្រះសង្ឃ អាចារ្យ គណៈកម្មការវត្ត និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ១៦នាក់ ព្រមទាំងសិស្សានុសិស្សមកពីវិទ្យាល័យសុខអាន ដូងខ្ពស់ ចំនួន ២០នាក់ ។ គោលបំណងនៃការប្រារព្ធធ្វើវេទិកាអប់រំនេះ គឺដើម្បីបង្កើតឲ្យមានការពិភាក្សាអន្តរជំនាន់ស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការទប់ស្កាត់អំពើហិង្សានៅកម្រិតបុគ្គល និងសហគមន៍។ បន្ថែមពីនេះទៀត វេទិកានេះក៏បានពិភាក្សាអំពីបញ្ហាប្រឈមដែលកំពុងតែកើតមាននៅក្នុងសហគមន៍នាពេលបច្ចុប្បន្ន។

## ការជ្រើសរើសទីតាំងសម្រាប់ធ្វើវេទិកា

ក្រុមការងារ ត្រូវបានណែនាំឲ្យជ្រើសរើសទីតាំងបរិវេណវត្តខ្សាច់រកកោះដើម្បីធ្វើវេទិកា ព្រោះថា ទី១) បរិវេណវត្តនេះមានសភាពធំទូលាយ និងបង្កលក្ខណៈងាយស្រួលក្នុងការធ្វើវេទិកា និងទី២) វត្តនេះមានប្រវត្តិធ្លាប់ត្រូវបានប្រើប្រាស់ធ្វើជាមន្ទីរពេទ្យខ្មែរ





វេទិកាអប់រំសហគមន៍ស្តីពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម ដែលជាការរៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ក្រោមកិច្ចសហការពីអាជ្ញាធរមូលដ្ឋានឃុំដូងខ្ពស់ និងគណៈកម្មការវត្តខ្នារកកោះ ត្រូវបានប្រារព្ធធ្វើនៅក្នុងបរិវេណវត្តខ្នារកកោះ ភូមិតាសែ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ នៅព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រហមក្នុងអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៧០ ហើយព្រះវិហារចាស់ទ្រុឌទ្រោមត្រូវបានប្រើប្រាស់ជាកន្លែងដាក់អំបិលក្នុងរបបខ្មែរក្រហម។ ខាងក្រោមនេះ ជាប្រវត្តិត្រួសៗពីវត្តខ្នារកកោះ ៖

ព្រះវិហារវត្តខ្នារកកោះ ស្ថិតនៅក្នុងភូមិតាសែ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ នៅតែបន្សល់ទុកស្លាកស្នាមដែលត្រូវបានបំផ្លិចបំផ្លាញដោយខ្មែរក្រហមរហូតមកដល់សព្វថ្ងៃនេះ។ អ្នកភូមិ ពុទ្ធបរិស័ទចំណុះជើងវត្ត ព្រមទាំងគណៈកម្មការវត្តខ្នារកកោះបានបោះបង់ព្រះវិហារនេះចោលមួយអន្លើរ ហើយបាននិងកំពុងកសាងព្រះវិហារថ្មីសន្ធាងមួយ ស្ថិតនៅក្បែរព្រះវិហារចាស់ប្រមាណ២០ម៉ែត្រ ដោយសារតែព្រួយបារម្ភពីការបាក់ស្រុតនៃអគារព្រះវិហារនេះ។ នៅខាងក្នុងព្រះវិហារចាស់ទ្រុឌទ្រោមនេះ មានបន្សល់ទុកព្រះពុទ្ធបដិមាធ្វើពីស៊ីម៉ងត៍ធំមួយអង្គ និងក្តារមឈូសបាក់បែកធ្វើអំពីឈើមួយ ស្ថិតនៅពីក្រោយបល្ល័ង្កព្រះ។ ជើងសសរទាំងអស់ដែលទ្រព្រះវិហារទាំងមូល មានសភាពប្រេះស្រាំខ្លាំង និងបែកជាបំណែកៗ។

ព្រះតេជគុណចៅអធិការវត្ត និងគណៈកម្មការវត្តបានប្រាប់ឲ្យដឹងថា សភាពប្រេះស្រាំទាំងនេះគឺបណ្តាលមកពីជាតិប្រៃនៃអំបិលដែលខ្មែរក្រហមបានស្តុកទុក នៅរយៈកាលគ្រប់គ្រងដោយ ប៉ុល ពត។ ជញ្ជាំងព្រះវិហារទាំងបួនទិស ក៏ត្រូវបានបាក់ស្រុតនិងរបេះដោយដុំៗ។ គំនូរពណ៌នៅតាមជញ្ជាំង និងដំបូល គឺនៅមានសភាពស្រស់ស្អាត ចម្រុះពណ៌ និងច្បាស់ៗ។ ក្រៅពីប្រើប្រាស់ជាឃ្លាំងអំបិល ខ្មែរក្រហមបានប្រើប្រាស់អគារព្រះវិហារនេះជាមន្ទីរពេទ្យ និងកន្លែងដាក់អ្នកជំងឺទៀត។ មិនមានអ្នកជំងឺស្លាប់នៅក្នុងព្រះវិហារនេះច្រើនទេ ហើយសាកសពទាំងនោះត្រូវបានសែងចេញយកទៅកប់ចោលនៅបរិវេណមួយដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីទីតាំងព្រះវិហារ។

ក្រោយឆ្នាំ១៩៧៩ ផ្នែកខ្លះនៃព្រះវិហារ ត្រូវបានជួសជុលឡើងវិញ ដើម្បីបម្រើដល់វិស័យព្រះពុទ្ធសាសនាដែលទើបងើបឡើងវិញបន្ទាប់ពីការបំផ្លិចបំផ្លាញរបស់ខ្មែរក្រហម។ បើតាមប្រវត្តិរបស់វត្តខ្នារកកោះដែលរៀបរាប់ដោយព្រះចៅអធិការបានឲ្យដឹងថា បរិវេណវត្តនេះត្រូវបានបង្កើតឡើងនៅលើ

ទីទួលមួយកន្លែងកាលពីឆ្នាំ១៨០៦ ហើយមកដល់ពេលបច្ចុប្បន្នមានអាយុកាល២១៧ឆ្នាំ គ្រប់គ្រងដោយព្រះគ្រូចៅអធិការ១៥ជំនាន់រួចមកហើយ។

សកម្មភាពនៃការធ្វើវេទិកា

លោក វ៉ាន់ ចន្ថន ជាអនុប្រធានសាងសង់វត្តខ្នារកកោះ ដែលជាអ្នកសម្របសម្រួលក្នុងកម្មវិធីវេទិកានេះ បានអញ្ជើញលោក ទេស ណារី ជាក្រុមប្រឹក្សាឃុំដូងខ្ពស់ ឡើងថ្លែងសុន្ទរកថាស្វាគមន៍ និងបើកវេទិកា។ លោកក្រុមប្រឹក្សា បានប្រាប់ពីមូលហេតុនៃការប្រារព្ធធ្វើវេទិកានៅពេលនេះថា ជាការបង្កើតកិច្ចពិភាក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបានលើកទឹកចិត្តអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឲ្យចែករំលែករឿងរ៉ាវជីវិតរបស់ខ្លួនប្រាប់ដល់ក្មេងៗជំនាន់ក្រោយដើម្បីការចងចាំ ព្រមទាំងបានលើកទឹកចិត្តដល់ក្រុមយុវជនទាំងអស់ឲ្យយកចិត្តទុកដាក់ស្តាប់ និងកត់ត្រាពីព្រឹត្តិការណ៍សំខាន់ៗដែលបានកើតមានលើជីវិតផ្ទាល់ខ្លួនរបស់អ្នករស់រានមានជីវិតម្នាក់ៗ។

ព្រះតេជគុណអនុគុណស្រុកបូរីជលសារ ព្រះនាម សយ វុទ្ធី បានផ្តាំផ្ញើបន្ថែមដល់ប្អូនៗយុវជនទាំងអស់ឲ្យត្រងត្រាប់ស្តាប់ការពន្យល់ និងការចែករំលែកបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហមពីសំណាក់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

បន្ទាប់មកលោក ផេង ពង្សរ៉ាស៊ី ជានាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានពន្យល់ត្រួសៗពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងបានសង្ខេបពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីជាចំណេះដឹងបន្ថែមដល់សិស្សានុសិស្ស និងអ្នករស់រានមានជីវិត។ លោក ផេង ពង្សរ៉ាស៊ី បានបន្ថែមថា ការលើកឡើងពីមាតិកាប្រវត្តិសាស្ត្រនៅពេលនេះ គឺគ្រាន់តែជាចំណេះដឹងទូទៅ ស្តីពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមប៉ុណ្ណោះ។ ចំណែករឿងរ៉ាវពិតដែលបានកើតឡើងនៅក្នុងភូមិតាសែ គឺជាបទពិសោធន៍ជាក់ស្តែង ដែលអ្នករស់រានមានជីវិតពីរបបនេះបានជួបប្រទះដោយផ្ទាល់ ហើយបទពិសោធន៍នេះនឹងត្រូវបានចងចាំដោយក្មេងៗជំនាន់ក្រោយដែលត្រូវជាចៅ ចៅទួតរបស់អ្នកទាំងនោះ។

## មតិយោបល់របស់ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ

លោក ផេង ពង្សរ៉ាស៊ី បានដាស់តឿនម្តងទៀតដល់ក្រុមយុវជនជំនាន់ក្រោយ ទាំងអស់ អំពីវិធីសាស្ត្រដ៏មានសារសំខាន់ខ្លះៗក្នុងការទប់ស្កាត់អំពើហិង្សានានាដែលអាចនឹងឈានដល់ការកកើតអំពើប្រល័យពូជសាសន៍នៅពេលអនាគត។ លោក ផេង ពង្សរ៉ាស៊ី បានបង្ហាញពីគន្លឹះខ្លះៗដែលយុវជនអាចចូលរួមទប់ស្កាត់អំពើហិង្សាក្នុងកម្រិតបុគ្គលបាន ដែលការទប់ស្កាត់នេះគឺជាបុសគល់នៃការចូលរួមកសាង និងអភិវឌ្ឍន៍ប្រទេសជាតិដោយគ្មានសង្គ្រាម។

## សន្និដ្ឋានរួម

ក្នុងរយៈពេលជាងពីរម៉ោងនៃការអនុវត្តវេទិកាអប់រំសហគមន៍នៅវត្តខ្នារកកោះ យើងសង្កេតឃើញថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំងអស់បានចែករំលែករឿងរ៉ាវរបស់គាត់យ៉ាងក្បោះក្បាយ និងពិតជាបានចូលរួមបង្រៀនដល់យុវជនជំនាន់ក្រោយពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍។ ចំណែកក្មេងៗជំនាន់ក្រោយដែលជាសិស្សានុសិស្សវិញក៏បានបង្ហាញពីចំណាប់អារម្មណ៍ខ្ពស់ក្នុងការត្រងត្រាប់ស្តាប់ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតទាំងអស់ដែលបានលើកឡើង។ តំណាងសិស្សានុសិស្សចំនួនពីរនាក់ដែលបានលើកឡើងពីចំណាប់អារម្មណ៍របស់ខ្លួនបានបង្ហាញថា ខ្លួននិងអ្នកឯទៀតមានអារម្មណ៍អាណិតអាសូរចំពោះអ្នករស់រានមានជីវិត និងខិតខំរៀនសូត្របន្ថែមទៀតដើម្បីចូលរួមទប់ស្កាត់អំពើហិង្សា។

## បណ្តាំផ្ញើរបស់ប្រធានភូមិ និងចាស់ព្រឹទ្ធាចារ្យចំពោះសិស្សានុសិស្ស

លោកតា អ៊ឹម ធន ដែលជាអាចារ្យធំនៅវត្តខ្នារកកោះបានធ្វើសេចក្តីសន្និដ្ឋានរួមមួយនិយាយទៅកាន់ក្មេងដែលជាសិស្សានុសិស្សទាំងអស់ថា ការសិក្សាពីប្រវត្តិសាស្ត្រដ៏ជូរចត់នាសម័យខ្មែរក្រហម គឺ





វេទិកាអប់រំសហគមន៍ស្តីពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម ដែលជាការរៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ក្រោមកិច្ចសហការពីអាជ្ញាធរមូលដ្ឋានឃុំដូងខ្ពស់ និងគណៈកម្មការវត្តខ្នារកកោះ ត្រូវបានប្រារព្ធធ្វើនៅក្នុងបរិវេណវត្តខ្នារកកោះ ភូមិតាសែ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ នៅព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មានសារសំខាន់ណាស់ក្នុងការថែរក្សាសន្តិភាពដែលមានស្រាប់។ លោកតា បានស្នើសុំឲ្យក្មេងៗទាំងអស់យកចិត្តទុកដាក់ពីប្រវត្តិសាស្ត្រនេះ និងស្នើសុំឲ្យបន្តការពិភាក្សាពីប្រវត្តិសាស្ត្រនេះជាមួយជីដូនជីតាផ្ទាល់នៃសិស្សម្នាក់ៗ នៅតាមគេហដ្ឋានរៀងខ្លួន បន្ទាប់ពីបានចូលរួមនៅក្នុងវេទិកានេះរួច។ លោកតា បានបន្តថា អ្វីដែលជាការលើកឡើងរបស់ក្រុមការងារ ក៏ដូចជាការលើកឡើងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺសុទ្ធសឹងតែជាការពិតជាក់ស្តែងដែលបានកើតឡើងនាសម័យខ្មែរក្រហម។

លោក អិន ឈឿន អនុប្រធានភូមិរទេះភ្លុក បានផ្តល់អនុសាសន៍ទៅកាន់សិស្សានុសិស្សទាំងអស់ឲ្យយកចិត្តទុកដាក់រៀនសូត្របន្ថែមទៀត ជាពិសេសរៀនសូត្រឲ្យបានស៊ីជម្រៅពីប្រវត្តិសាស្ត្រដ៏ជូរចត់ដែលបានកើតមានចំពោះជីដូនជីតារបស់ខ្លួន។ «មានតែការរៀនសូត្រទេ ទើបអាចបំបាត់អំពើហិង្សា និងការកាប់សម្លាប់គ្នាបាន។ ដូច្នេះ ក្មួយៗត្រូវតែខិតខំរៀនសូត្រ និងឈ្វេងយល់ឲ្យស៊ីជម្រៅលើប្រវត្តិ-សាស្ត្ររបស់យើង ជាពិសេសរឿងរ៉ាវដែលបានកើតឡើងលើគ្រួសាររបស់ក្មួយៗផ្ទាល់»។

**លោកប៉ាញ់ប៉ាល់ ភេទប្រុស អាយុ៨១ឆ្នាំ រស់នៅភូមិតាសែ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ រៀបរាប់ថា៖**

«... ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ គឺក្នុងឆ្នាំ១៩៧១ និង១៩៧២ ព្រះសង្ឃដែលគង់នៅក្នុងវត្តនេះ ត្រូវបានជម្លៀសចេញពីវត្តទាំងអស់ មិនដឹងជម្លៀសទៅកាន់កន្លែងណាខ្លះទេ។ ខ្ញុំក៏នៅមិនបានជាប់លាប់ដែរ ប៉ុន្តែគ្រាន់តែដឹងថា បរិវេណវត្តនេះ ត្រូវបានប្រើប្រាស់ជាមន្ទីរពេទ្យរបស់ខ្មែររំដោះ មានឈ្មោះថាមន្ទីរពេទ្យស្រុក១០៨។ ខ្ញុំដឹងថា មានកន្លែងស្លថ្នាំមួយ ស្ថិតនៅខាងកើតព្រះវិហារថ្មីនេះ។ ចំណែកខាងត្បូងព្រះវិហារគឺជាកន្លែងចុងភៅរបស់ពេទ្យ...»។

**លោក ហង្ស ផាន អាយុ៧៣ឆ្នាំ រស់នៅភូមិតាសែ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ រៀបរាប់ថា៖**

«ខ្ញុំមានអាយុ៧៣ឆ្នាំ ប៉ុន្តែខ្ញុំមិនបានដឹងពីប្រវត្តិវត្តនេះច្បាស់លាស់ឡើយ។ ប៉ុន្តែអ្វីដែលខ្ញុំនៅចងចាំបានគឺដោយសារតារបស់ខ្ញុំគឺលោកតា ហង្ស គឺជាគណៈកម្មការនៅវត្តនេះ គឺជាអ្នកនិយាយប្រាប់។ វត្តនេះ កាលដើមឡើយមានឈ្មោះថា វត្តកកោះ។ ដល់ពេលក្រោយមក វត្តនេះក៏បានប្តូរឈ្មោះទៅជាវត្តខ្នារកកោះ។ លោកតាលោកយាយមួយចំនួនក៏

ឆ្ងល់ដែរថា ហេតុអ្វីបានជាមានការដូរឈ្មោះដូច្នេះ។ ដើមហេតុដែលវត្តនេះកើតឡើងគឺថា មានដើមកកោះធំមួយស្ថិតនៅលើទួលមួយក្នុងភូមិមួយឈ្មោះបុស្សឫស្សីជោត។ ចាស់ៗបានដាក់ឈ្មោះថា ទួលកកោះ។ ក្រោយមក វត្តមួយត្រូវបានកសាងនៅលើទីទួលនេះ ហើយដាក់ឈ្មោះថា វត្តកកោះ។

លុះក្រោយមកទៀតវត្តនេះក៏ត្រូវរុះរើមកសាងសង់នៅក្នុងបរិវេណទួលត្រពាំងខ្នារដោយមានឈ្មោះថា វត្តទួលត្រពាំងខ្នារ។ មួយរយៈក្រោយមក ដោយសារតែវត្តនេះមានដើមកំណើតចេញពីទួលកកោះ អ្នកភូមិក៏បាននិយមហៅវត្តនេះថា វត្តខ្នារកកោះ រហូតមកដល់សព្វថ្ងៃនេះ។ វិហារទីមួយកាលដែលសាងសង់ដំបូង គឺតាំងពីមុនជំនាន់បារាំងគ្រប់គ្រងទៅទៀត។ កាលនោះវត្តនេះត្រូវបារាំងវាយបំផ្លាញចោល រូបចម្លាក់រូបទេពនាងខ្មៅចោល។ ពីដើមមក លោកតាខ្ញុំប្រាប់ថា រូបនេះមានបារមីខ្លាំងណាស់។ ប្រសិនបើមានអ្នកធ្វើការ និងអ្នកមានផ្ទៃពោះ ដើរកាត់មុខរូបចម្លាក់ទេពនាងខ្មៅនេះ គឺមានគ្រោះថ្នាក់ហើយ។ បើអ្នកធ្វើការ គឺប្រាកដជាធ្លាក់បុណ្យសក្តិ។ ឯអ្នកមានផ្ទៃពោះវិញ គឺប្រាកដជារលូតកូនជាក់ជាមិនខាន។ ក្រោយមកទៀត រូបព្រះពុទ្ធបដិមាមួយអង្គធំ ក៏ត្រូវវាយបំផ្លាញចោលដែរ ដោយសារតែរូបបដិមានេះមានចម្លាក់នាងហ៊ីងព្រះធរណីនៅផ្នែកខាងក្រោយ ដោយសារតែរូបចម្លាក់នេះបានធ្វើឲ្យក្មេងៗខ្លាច។

តមកដល់ជំនាន់ប៉ុល ពត នៅឆ្នាំ១៩៧៥ ប្រជាជនដែលបានជម្លៀសមកពីភ្នំពេញ ត្រូវយកមកដាក់នៅក្នុងបរិវេណវត្តនេះ ហើយនៅឆ្នាំ១៩៧៦ បរិវេណវត្តខ្នារកកោះនេះត្រូវប្រើប្រាស់ជាមន្ទីរពេទ្យស្រុក ១០៨។ ព្រះវិហារចាស់ដែលស្ថិតនៅជាប់ព្រះវិហារថ្មី គឺជាកន្លែងស្តុកថ្នាំពេទ្យ។ កន្លែងសាលារៀនបឋមសិក្សា (ស្ថិតនៅជាប់នឹងព្រះវិហារចាស់) គឺជាកន្លែងព្យាបាល។ ចំណែកសាលាបាឡីវិញ គឺជាកន្លែងស្នាក់នៅរបស់កម្មាភិបាលខ្មែរក្រហម»។

***លោក សុខ ស្រ៊ាង អាយុ៧៥ឆ្នាំ រស់នៅភូមិតាសែ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ រៀបរាប់ថា៖***

«ខ្ញុំសុំលើកព្រឹត្តិការណ៍នៅក្រោយឆ្នាំ១៩៧០ មកនិយាយប្រាប់ក្មួយៗ ព្រោះថាមានប្អូនៗ ក្មួយៗខ្លះមិនជឿទេថាមានគេយកមនុស្សទៅសម្លាប់ចោល។ ដូច្នេះសូមក្មួយៗស្តាប់ឲ្យច្បាស់ថា ក្រោយពីលន់ នល់ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ពីតំណែង លន់ នល់ក៏បានឡើងជានាយករដ្ឋមន្ត្រីនាពេលនេះ។ ក្រោយមក សម្តេចព្រះ នរោត្តម សីហនុ បានអំពាវនាវឲ្យប្រជាជនចូលព្រៃម៉ាគីដើម្បីតស៊ូ។ ព្រៃម៉ាគី មានន័យថាព្រៃសាមគ្គី។ នៅពេលនោះប្រជាជនទាំងគ្នាចូលព្រៃ ព្រោះស្រឡាញ់សម្តេចឪ។ ប៉ុន្តែដំបូងៗ អ្នកចូលព្រៃទាំងនោះវាយមិនឈ្នះ លន់ នល់ ទេ។ ប្រជាជនរស់នៅក្នុងភូមិនេះ មានអ្នកនៅខាងក្រៅ និងអ្នកនៅខាងក្នុង (ខាងក្រៅ សំដៅលើការចូលរួមកម្លាំងជាមួយ លន់ នល់។ ចំណែកអ្នកនៅខាងក្នុង សំដៅលើអ្នករួមកម្លាំងជាមួយខ្មែរក្រហម)។ គ្រូបង្រៀននៅតាមភូមិ ត្រូវខាង លន់ នល់ អូសទាញទៅអស់ហើយ ព្រោះខាងរណសិរ្សបានបិទសាលារៀនអស់ហើយពេលនោះ។ អ្នកខ្លះចូលធ្វើជាទាហានពាក់ស័ក្តិ៣ ស័ក្តិ៤។ គ្រូខ្ញុំឈ្មោះ ចៅ ជួន បានចូលធ្វើទាហានលន់ នល់ នៅជ្រៃលេរ ពាក់ស័ក្តិ ២។ ដូច្នេះ ភូមិនេះបានក្លាយទៅជា «តំបន់ទាញគោង» ឬ «តំបន់ប្រទាញប្រទង់»។

នៅចន្លោះឆ្នាំ១៩៧២ និងឆ្នាំ១៩៧៣ នៅក្នុងភូមិខ្ញុំគឺចាប់ផ្តើមតឹងតែងឡើងៗ គឺលែងមានរបបហូបចុកឯកជនហើយ គឺហូបរួម។ ពុំមាននរណាម្នាក់ហ៊ានប្រព្រឹត្តអ្វីផ្តេសផ្តាសឡើយ។ ខ្ញុំសុំលើកពីប្រវត្តិរបស់ខ្ញុំដូចតទៅ ៖ ឪពុកក្មេកខ្ញុំត្រូវកម្មាភិបាលប្រើឲ្យទៅដឹកអង្ករនៅសំឡាញ ស្រុកអង្គរជ័យ ខេត្តកំពត។ ឪក្មេកខ្ញុំប្រកែកមិនព្រមទៅ ព្រោះកូនគាត់ដែលត្រូវជាប្រពន្ធខ្ញុំ ទើបតែឆ្លងទន្លេបាន៣ថ្ងៃ។ ពីរបីថ្ងៃក្រោយមកឪក្មេកខ្ញុំបានមកប្រាប់ខ្ញុំថា កូន! គេហៅឪឲ្យទៅប្រជុំ ហើយគេនិយាយថា គេចង់ចាប់ឪហើយ ព្រោះឪមិនបានទៅដឹកអង្ករនៅសំឡាញ។ ប្រាំមួយថ្ងៃក្រោយមក គេមកហៅឪក្មេកខ្ញុំឲ្យទៅក្រាំងឆេះ គឺគេយកគាត់ទៅដាក់គុកនៅទីនោះ។ បីបួនថ្ងៃក្រោយមក ខ្ញុំឮថាគេយកឪក្មេកខ្ញុំទៅវាយចោល។ ថ្ងៃនោះក្រុមរណសិរ្សវាយមនុស្សចោលពីរនាក់។ ម្នាក់ទៀត

ឈ្មោះ ហៀង។ ខ្ញុំឮតាមគេនិយាយតគ្នាថា ក្រុមរណសិរ្សចង់កម្ចាត់អ្នកមានសក្តិភូមិ។ ក្រោយមក គេមកចាប់តាឈឺននៅត្រឡាចម្នាក់ទៀតយកទៅបាញ់ចោល ឲ្យប្រជាជនមើលឃើញជាក់ស្តែង។ តាឈឺនគឺជាអ្នកមានទ្រព្យសម្បត្តិក្នុងភូមិម្នាក់ដែរ។

ថ្ងៃមួយ មានការប្រយុទ្ធគ្នានៅក្នុងភូមិ។ ពួក លន់ នល់ បានបាញ់ផ្លោងពីផ្សារលើរមកធ្លាក់នៅក្នុងភូមិខ្ញុំ។ ប្រជាជនទាំងអស់នាំគ្នារត់ទៅ «ដីរោក» ដើម្បីគេចគ្រាប់ផ្លោង១០៥មីលីម៉ែត្រ។ បន្តិចក្រោយមក ពួក លន់ នល់ បានចូលមកដល់ភូមិ និងបានសម្លាប់ក្រុមរណសិរ្សអស់រាប់រយនាក់ ស្លាប់ពេញត្រង់សេ (លេណដ្ឋាន)។ ចំណែកទាហាន លន់ នល់ វិញ ក៏ស្លាប់ច្រើនណាស់ដែរ។

មុនឆ្នាំ១៩៧៥បន្តិច ខ្មែរក្រហមវាយបានកំពង់ជ្រៃ។ ប្រជាជននៅក្នុងស្រុក ១០៨ភាគច្រើន ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅព្រៃគាំ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ នៅខែមេសា ឆ្នាំ១៩៧៥ មានប្រជាជនជម្លៀសមកពីភ្នំពេញ និងទីកន្លែងផ្សេងៗទៀតច្រើនណាស់ មកកាន់ទីនេះ។ អ្នកខ្លះបានស្លាប់ក្នុងពេលជម្លៀស។ អតីតទាហាន និងមន្ត្រីរដ្ឋការជំនាន់ លន់ នល់ ត្រូវខ្មែរក្រហមបោកបញ្ឆោតថាឲ្យបានចូលធ្វើការដូចដើម និងពាក់ស័ក្តិដូចដើម។ មានអ្នកចាញ់បោកខ្មែរក្រហមច្រើនណាស់ បានស្ម័គ្រចិត្តចុះឈ្មោះក្នុងបញ្ជីដើម្បីបានវិលត្រឡប់មកកាន់ភ្នំពេញវិញ។ ប៉ុន្តែតាមពិត អ្នកចុះឈ្មោះទាំងនោះ ត្រូវខ្មែរក្រហមនាំយកទៅសម្លាប់ចោលនៅភ្នំខ្លែងទាំងអស់។ ក្រោយមក ខ្ញុំត្រូវគេជម្លៀសឲ្យទៅនៅត្រពាំងអណ្តើក ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំត្រូវខ្មែរក្រហមឲ្យចូលនៅក្នុងកងចល័តពិសេស។ ខ្ញុំហូបមិនដែលបានឆ្អែតទេ។ ក្នុងរបបខ្មែរក្រហម ខ្ញុំអាចសុំប្រធានកងមកលេងស្រុកកំណើតបានម្តងដែរ។ ប៉ុន្តែពេលមកដល់ភូមិ ខ្ញុំគ្មានឃើញនរណាម្នាក់នៅផ្ទះទេ»។

សិស្ស សួន ដេត ភេទប្រុស អាយុ១៧ឆ្នាំ បាននិយាយថា «ខ្ញុំមានចំណាប់អារម្មណ៍ខ្លាំងណាស់ នៅពេលដែលបានស្តាប់ការលើកឡើងរបស់លោកតាៗពីប្រវត្តិឆ្លងកាត់របបខ្មែរក្រហម។ ខ្ញុំជឿជាក់មួយរយភាគរយថា ពិតជាមានរបបខ្មែរក្រហមកើតឡើងមែន។ ខ្ញុំមានអារម្មណ៍អាណិតអាសូរចំពោះលោកតាលោកយាយដែលមានបទពិសោធន៍កំសត់ជូរចត់ឆ្លងកាត់របបខ្មែរក្រហម។ ខ្ញុំនឹងខិតខំរៀនសូត្រដើម្បីជួយអភិវឌ្ឍសង្គមជាតិយើង»។

សិស្ស ជួង លីអ៊ី ភេទស្រី អាយុ១៨ឆ្នាំ បាននិយាយថា «ខ្ញុំពិតជាមានអារម្មណ៍ សង្វេគ ពេលដែលខ្ញុំបានឮពីប្រវត្តិសាស្ត្រខ្មែរ នាសម័យមុន ដែលឆ្លុះបញ្ចាំងពីទិដ្ឋភាពយ៉ាងជូរចត់របស់ប្រជាជនកម្ពុជា។ ក្នុងនាមនាងខ្ញុំជាសិស្សមួយរូបដែលកំពុងសិក្សានៅថ្នាក់ទី១២ ខ្ញុំប្តេជ្ញាចិត្តខិតខំសិក្សាដើម្បីឲ្យមានអនាគតល្អ និងជួយឲ្យប្រទេសជាតិមានភាពរីកចម្រើនតទៅមុខ។ ខ្ញុំមិនធ្វើឲ្យប្រទេសជាតិធ្លាក់ចុះ និងខ្ទិនថយដូចសម័យមុនឡើយ»។

## បញ្ហាប្រឈមនៅក្នុងសហគមន៍នាពេលបច្ចុប្បន្ន

លោកអនុភូមិឈ្មោះ អ៊ិន ឈឿន បានប្រាប់ដល់អ្នកចូលរួមក្នុងវេទិកា ទាំងអស់ពីបញ្ហាប្រឈមដែលកំពុងកើតមាននៅក្នុងភូមិរបស់គាត់ថា អ្នកភូមិនៅមានចិត្តស្ទាក់ស្ទើរក្នុងការសម្រេចចិត្តទទួលយកវ៉ាក់សាំងការពារជំងឺកូវីដ-១៩។ លោក អ៊ិន ឈឿន បានស្នើសុំឲ្យប្រជាជនក្នុងភូមិគាត់ ឈ្វេងយល់ឲ្យបានច្រើនថែមទៀតពីគុណសម្បត្តិនៃការទទួលវ៉ាក់សាំងការពារជំងឺកូវីដនេះ ព្រោះថាវាអាចជួយថែរក្សាសុខភាព និងអាយុជីវិតបានយូរតទៅទៀត។



វេទិកាអប់រំសហគមន៍ស្តីពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម ដែលជាការរៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ក្រោមកិច្ចសហការពីអាជ្ញាធរមូលដ្ឋានឃុំដូងខ្ពស់ និងគណៈកម្មការវត្តខ្នារកកោះ ត្រូវបានប្រារព្ធធ្វើនៅក្នុងបរិវេណវត្តខ្នារកកោះ ភូមិតាសែ ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ នៅព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ចាន់ នាង ៖ ឪពុកខ្ញុំធ្វើបុណ្យឧទ្ទិសកុសល ឱ្យខ្ញុំបីដង ព្រោះគាត់គិតថាខ្ញុំស្លាប់ហើយ



ចាន់ នាង សព្វថ្ងៃរស់នៅឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (អ៊ុំ ធារី / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ចាន់ នាង មានអាយុ ៦៨ឆ្នាំ សព្វថ្ងៃខ្ញុំរស់នៅក្នុងភូមិរលួស ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ខ្ញុំមានស្រុកកំណើតនៅភូមិពោធិ៍កំបោរ ឃុំវិហារហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល។ ខ្ញុំរៀនត្រឹមថ្នាក់ទី១១ កាលពីសង្គមចាស់ក្រោយមកឈប់រៀនដោយសារកើតមានរដ្ឋប្រហារទម្លាក់សម្ដេច ព្រះនរោត្តម សីហនុ ឆ្នាំ១៩៧០។ ខ្ញុំមានម្ដាយឈ្មោះ វណ្ណ សុត្រ និង ឈ្មោះឪពុក ចាន់ ហ៊ិន សព្វថ្ងៃពួកគាត់បានស្លាប់។ ខ្ញុំមានបងប្អូនបង្កើតចំនួន ៨ នាក់ និង ស្លាប់អស់ចំនួន ៣ នាក់ នៅក្នុងរបបខ្មែរក្រហម។

កាលនោះគ្រួសារខ្ញុំរស់នៅឃុំវិហារហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល ឪពុកខ្ញុំបានជីកលេណដ្ឋានសម្រាប់ឲ្យពួកយើងលាក់ខ្លួន។ នៅពេលភូមិអសន្តិសុខ អ្នកភូមិតែងសំលៀងកាំបិតផ្គាក់ និងស្នូ ទុកការពារខ្លួនប្រសិនជាទាហានធីវគីប្លយូនខាងត្បូងចូលមកធ្វើអ្វីមិនល្អដាក់អ្នកភូមិ។

នៅក្នុងឆ្នាំ១៩៧១ របបសាធារណរដ្ឋខ្មែរបានដើរចាប់យុវជនធ្វើទាហាន ហើយគ្រួសារណាមានកូនប្រុសគ្រប់អាយុធ្វើទាហានមេភូមិនឹងមកកត់ឈ្មោះ។ ឃើញដូច្នេះឪពុកខ្ញុំបបួលគ្រួសារមករស់នៅបន្ទាយលង្វែកដោយសារគាត់មានដងន្លង់នៅទីនោះ ម្យ៉ាងទៀតទីនោះមានដីទូលាយអាចដាំដំណាំបាន។ ក្រោយមកទាហាន លន់ នល់ ឈប់ឲ្យយើងរស់នៅបន្ទាយ ខ្លាចមានគ្រោះថ្នាក់ ហើយបានឲ្យពួកយើងមករស់នៅសាលាស្រុកជ្រៃបាក់ ខេត្តកំពង់ឆ្នាំង វិញ។ នៅកន្លែងថ្មីមានការចែកស្បៀងអាហារឲ្យប្រជាជនរៀងរាល់មួយខែម្ដង ដូចជា អង្ករ ប្រហុក សៀង និង ឆៃប៉ូវ។

នៅឆ្នាំ១៩៧៣ កងទ័ពរំដោះខ្មែរក្រហមបានវាយឈ្នះទាហាន លន់ នល់ នៅភូមិដែលខ្ញុំរស់នៅ ហើយកៀរប្រជាជនចេញ ជាពិសេសកៀរយកបាននារី ក្នុងនោះមានខ្ញុំដែរដោយសារតែខ្ញុំដេកលក់។ យប់នោះឪពុករបស់ខ្ញុំបានទាញដៃខ្ញុំ ប៉ុន្តែខ្ញុំមិនក្រោក។ ពេលខ្ញុំដឹងខ្លួនមិនឃើញឪពុកម្ដាយខ្ញុំ ឡើយ ហើយខ្ញុំបែកគាត់តាំងពីពេលនោះមក។ ខ្ញុំឃើញទាហានរំដោះចូលមក និងនិយាយមកកាន់ខ្ញុំថាមិត្តនារីឯងគឺជាគិញ លន់ នល់។ ខ្ញុំប្រាប់ថា ខ្ញុំមិនដឹងទេ កងទ័ពរំដោះក៏ចាប់ដៃខ្ញុំជាប់នឹងយកខ្ញុំទៅជាមួយ។ យើងដើរមួយយប់មួយថ្ងៃទើបមកដល់ជើងភ្នំមួយ ប៉ុន្តែខ្ញុំមិនស្គាល់ឈ្មោះ ឡើយ។ កងទ័ពរំដោះបញ្ជូនខ្ញុំទៅភូមិច្រកកណ្ដោល ឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ យើងនៅផ្ទះមួយដែលមានឈ្លបភូមិក្មេងៗអាយុប្រហែលជា១៣ទៅ១៨ឆ្នាំ នៅចាំតាមដានឃ្លាំមើលយើងទាំងយប់ថ្ងៃ។ ជារៀងរាល់ល្ងាច តែងមានការប្រជុំនិងសួរខ្ញុំថា «មិត្តនារី មាននឹកម៉ែឪបងប្អូនបុរទេ?» ព្រោះខ្មែរក្រហមឲ្យយើងលះបង់កុំឲ្យយើងនឹកម៉ែឪបងប្អូនហើយដើម្បីរស់ខ្ញុំក៏ឆ្លើយថាមិននឹកទេ ខ្ញុំកសាងខ្លួនតាមយុទ្ធមិត្តហើយ។ រយៈពេលមួយសប្ដាហ៍ក្រោយមកទើបអង្គការយកខ្ញុំទៅដាក់ឲ្យរស់នៅតាមផ្ទះអ្នកភូមិ។ ខ្ញុំធ្វើការដូចប្រជាជនទូទៅ ខ្ញុំឃើញប្រជាជនមូលដ្ឋានធ្វើអីគឺខ្ញុំធ្វើហ្នឹងតាមគេ ដូចជា ធ្វើចម្ការ និងដាំដំឡូង។ យូរៗខ្មែរក្រហមទុកចិត្តឲ្យខ្ញុំចូលនារីឃុំជៀបដែលមានប្រធានឃុំគឺជាមនុស្សស្រីចាត់តាំងឲ្យខ្ញុំនៅខាងដាំបាយ ចំពេលដែលអង្គការបង្កើតសហករណ៍

រួមប្រហែលជាខែមិថុនា ឆ្នាំ១៩៧៥។

ក្រោយមកអង្គការបញ្ចូលខ្ញុំទៅក្នុងកងនារីស្រុកទឹកផុស និងបានចាត់តាំងខ្ញុំឲ្យលើកប្រព័ន្ធទំនប់ និងជីកប្រឡាយនៅម្តុំវរមាស។ ខ្ញុំធ្វើការគ្មានពេលទំនេរឡើយ គឺចាប់ផ្តើមធ្វើពីព្រលឹមរហូតដល់ម៉ោង៩យប់ទើបឈប់សម្រាក។ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅរស់នៅខេត្តពោធិ៍សាត់។ ដោយសារខ្វះមនុស្សដឹកនាំនៅទីនោះ អង្គការបានចាត់តាំងខ្ញុំឲ្យដឹកនាំប្រជាជនវែកដី ចំណែកការហូបចុក គឺពុំទទួលបានរបបអាហារគ្រប់គ្រាន់ឡើយ។

នៅដើមឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមចូលមក ខ្មែរក្រហមកៀងខ្ញុំនិងប្រជាជនឡើងទៅលើភ្នំ។ ប្រជាជនខ្លះទៅទាំងគ្រួសារ ហើយគ្រួសារដែលមានម្តាយឬឪពុកចាស់ដើរទៅមុខលែងរួច ក៏ធ្វើធ្មើរដាក់គាត់ចោលនៅតាមផ្លូវ។ កាលនោះមានមនុស្សមកពីកន្លែងផ្សេងៗដើរពេញព្រៃ។ ពេលចេញទៅដំបូងមានគ្នា៣០នាក់ ក្រោយមកនៅសល់តែជាង១០នាក់ប៉ុណ្ណោះ ដោយសារខ្វះស្បៀងអាហារ។ ខ្ញុំដើររហូតដល់ភ្នំរលាក់កងជើង និងដល់ខេត្តកោះកុង។ យើងបានពិភាក្សាគ្នាដើម្បីត្រឡប់មកផ្ទះវិញ ព្រោះប្រសិនបើបន្តដំណើរទៅមុខទៀតប្រហែលជាមិនរស់ទេ។ យើងដើរត្រឡប់មកដល់ខេត្តកំពង់ស្ពឺ ក៏ឃើញអ្នកភូមិបរទេះគោ។ នៅពេលឃើញយើងមានគ្នា៥ទៅ៦នាក់ អ្នកភូមិទាំងនោះបានលើកកាំភ្លើងបាញ់សំដៅមកយើង ដូច្នេះយើងក៏នាំគ្នារត់ទៅពួននៅដំបូកស្ទើរមិនទាន់។ យើងនាំគ្នាលើកដៃឡើងហើយរត់ទៅរកអ្នកភូមិទាំងនោះ។ អ្នកភូមិបានសួរឈ្មោះទីលំនៅរបស់ខ្ញុំ និងឪពុកម្តាយខ្ញុំ។ ដោយសារសេចក្តីអាណិតអាសូរ អ្នកភូមិឲ្យខ្ញុំស្នាក់នៅកំពង់ស្ពឺជាមួយ។ នៅតាមផ្លូវកងទ័ពវៀតណាមឃើញខ្ញុំពាក់ខ្មៅ ក៏ឃាត់ខ្ញុំឲ្យឈប់ និងសួរនាំ។ កងទ័ពវៀតណាមជូនខ្ញុំទៅកន្លែងបកប្រែភាសា។ ពេលនោះខ្ញុំជួបឈ្មោះញឹប គឺជាអ្នកបកប្រែភាសាឲ្យកងទ័ពវៀតណាមនិងប្រជាជនខ្មែរដែលចុះមកពីលើភ្នំ ដែលក្រោយមក ញឹប បានក្លាយជាប្តីរបស់ខ្ញុំ។ នៅទីនោះ ញឹប បានស្នើសុំកងទ័ពវៀតណាមត្រឡប់មករស់នៅស្រុកកំណើតវិញដែរ ប៉ុន្តែកងទ័ពវៀតណាមមិនទាន់ឲ្យគាត់មក គឺឲ្យគាត់នៅរង់ចាំបកប្រែឲ្យប្រជាជនដែលចុះពីលើភ្នំអស់សិន។ ដោយសារញឹបស្នើសុំញឹកញាប់ពេកកងទ័ពវៀតណាមក៏ឲ្យគាត់ត្រឡប់មកផ្ទះវិញ។ ខណៈនោះខ្ញុំក៏ត្រឡប់មករស់នៅស្រុកកំណើតញឹបដែរ។ ពេលខ្ញុំដល់ភូមិឈ្មោះ តាភា បានស្នើសុំខ្ញុំធ្វើជាកូនចិញ្ចឹម។ ក្រោយមកខ្ញុំរៀបការជាមួយញឹបតាមប្រពៃណី។ កាលនោះយាយ ភួង គឺជាភ្នួងតុបតែងខ្លួនឲ្យខ្ញុំ ព្រោះយាយ ភួង បានលាក់ទុកហិបគ្រឿងសម្អាងមុនពេលកងទ័ពខ្មែរក្រហមចូលមកដល់ភូមិ។

បន្ទាប់ពីរៀបការរួច ខ្ញុំមានកូនចំនួន៣នាក់ ទាំងកូននៅក្នុងផ្ទៃអាយុ៨ខែ។ ក្រោយមកខ្ញុំក៏ចេញទៅតាមរកឪពុកម្តាយដែលបានបែកគ្នានៅស្រុកកំណើតក្នុងខេត្តកណ្តាល។ ខ្ញុំបានដាក់អង្ករទៅតាមខ្លួនចំនួន ៣គីឡូ ហើយខ្ញុំផ្តាំប្តីខ្ញុំថារយៈពេល ៣ថ្ងៃ អស់អង្ករខ្ញុំនឹងត្រឡប់មកផ្ទះវិញ។ ប្រសិនបើខ្ញុំនៅយូរមានន័យថា ខ្ញុំបានជួបបងប្អូនខ្ញុំហើយ។ ខ្ញុំដឹកដៃកូនទៅជាមួយ។ កាលនោះខ្ញុំមានលុយ៣០០រៀល។ មកដល់ផ្សារអូរឫស្សី ខ្ញុំឃើញឡាន ឡាំប្រីតា ដែលបើកដឹកភ្ញៀវទៅមក។ ខ្ញុំដឹកដៃកូន និងហៅ ឡាននោះជិះអស់ថ្លៃ១៧រៀល។ អ្នកបើក ឡាន ឡាំប្រីតាបានជូនខ្ញុំទៅដល់ព្រែកក្តាម ដើម្បីឡើងជិះរ៉ឺម៉កបន្តសំដៅទៅស្រុកពញាឮ និងទៅខដុង្គ។ នៅតាមផ្លូវខ្ញុំប្រាប់អ្នកបើករ៉ឺម៉កឲ្យដាក់ខ្ញុំចុះនៅកំពង់ហ្លួង ប៉ុន្តែអ្នកបើករ៉ឺម៉កបានបើកហួស ដូច្នេះខ្ញុំបានប្រកែកគ្នាជាមួយម្ចាស់រ៉ឺម៉ក។ សំណាងល្អមីងម្នាក់ដែលនៅកិនស្រូវក្បែរនោះគ្រឡេកឃើញ ហើយមកសួរខ្ញុំថា «អូនធ្វើដំណើរទៅណា»។ ខ្ញុំប្រាប់មីងនោះថា «ខ្ញុំមានប្តីនៅខេត្តព្រៃវែងហើយ ខ្ញុំមករកឪពុកម្តាយបងប្អូននៅភូមិស្រុកនេះ»។ មីងម្នាក់នោះសួរខ្ញុំពីឈ្មោះឪពុកម្តាយ ហើយពេលខ្ញុំប្រាប់ឈ្មោះទៅគាត់ ទើបគាត់ភ្ញាក់ ព្រោះខ្ញុំត្រូវជាក្មួយរបស់គាត់ និងប្រាប់ខ្ញុំថាឪពុករបស់ខ្ញុំនៅរស់ គឺស្លាប់តែបង ហេង និងម្តាយរបស់ខ្ញុំ ចំណែកបងពីរនាក់នៅជាមួយឪពុក ហើយបងពីរនាក់ទៀតនៅបាត់ដំបង។ ពូរបស់ខ្ញុំដឹងថាខ្ញុំមក គាត់ក៏មកអើតមើលខ្ញុំ។ ខ្ញុំឃើញគាត់ក៏ជម្រាបសួរ ប៉ុន្តែគាត់មិនចាំខ្ញុំទេ ទាល់តែខ្ញុំប្រាប់ឈ្មោះទើបគាត់ស្គាល់។ ពូរបស់នាំខ្ញុំទៅជួបឪពុករបស់ខ្ញុំដែលកំពុងទប់ភ្លឺស្រែ។ ដំបូងឪពុករបស់ខ្ញុំងើយមើលមុខខ្ញុំប៉ុន្តែគាត់មិនស្គាល់ខ្ញុំទេ។ ខ្ញុំស្ទុះទៅឱបគាត់ ហើយយំ ទើបគាត់ស្គាល់ ហើយយើងយំទាំងអស់គ្នា។ ឪពុករបស់ខ្ញុំគិតថាខ្ញុំស្លាប់ ហើយគាត់បានធ្វើបុណ្យខទិសកុសលឲ្យខ្ញុំ៣ដងមកហើយដែរ។ បន្ទាប់មក បងប្រុសរបស់ខ្ញុំក៏ត្រឡប់មកផ្ទះវិញ និងបានជួបខ្ញុំ ហើយយើងយំទាំងអស់គ្នាម្តងទៀត។

**ជាវ៉ារដ្ឋ មេត្តា**

## «ទួលពិឃាដ» (ត)

# ១១. ទំព័រជីវិតទី២លើទឹកដីចាស់ (ត)

### សង្គ្រាន្តគ្រោះភ័យ

### *គ្រាប់កាំភ្លើងអាការទទួលទេវតាឆ្នាំថ្មី*

គ្រាន់តែឈានជើងចេញពីដើមពោធិ៍សម្បុកអកមកដល់ពោធិ៍រុំភ្លាម សំឡេងគ្រាប់កាំភ្លើងអាកាបាញ់ចេញពីភូមិក្រាំងលាន់ឮរំពងដូចគ្រាប់ភ្លៀង។

ខ្ញុំស្រាលខ្លួនស្វាក បាត់ព្រលឹងព្រលះអស់ពីខ្លួន ហើយឆ្ងល់ថាមានរឿងអ្វីកើតឡើងទៀតហើយ។ សំឡេងនេះខ្ញុំខានឮយូរហើយ តែខ្ញុំគិតក្នុងចិត្តថាប្រហែលជាកងទ័ពវៀតណាមពើបប្រទះនឹងកងទ័ពកងចក្រប្ដុកងចលនាផ្សេងៗហើយ។ ឱ! តាយាយ បងប្រុសស្រី ប្អូនៗ មិនដឹងសុខទុក្ខយ៉ាងណាទេ។

ខ្ញុំក៏ទុចដំណើរង៉ក់ចង់ថយក្រោយទៅរកភូមិឃោតស្រុកកំណើតឪពុកខ្ញុំវិញ។ គិតរួចស្រេចស្រាប់តែឮសំឡេងស្រែកចេញពីដើមពោធិ៍រុំមកថា "នែក្មួយវង្ស មកជ្រកកន្លែងនេះសិនទៅ កុំអាលចូលភូមិអី ព្រោះមិនដឹងមានរឿងអ្វីទេ ឮតែសំឡេងគ្រាប់បាញ់គ្នាមិនដាច់" ។

ខ្ញុំក្រឡេករកម្ចាស់សំឡេងនោះនៅចុងពោធិ៍ តែមិនឃើញអ្វីសោះ ខ្ញុំក្រឡេកមើលមកក្រោមវិញស្រាប់តែឃើញអ្នកភូមិប្អូនប្រាំនាក់ ជ្រកក្រោមដើមពោធិ៍រុំ។ ខ្ញុំរត់ទៅរកពួកគាត់ហើយក្រាបសម្ងំនៅទីនោះ។ ពួកគាត់សួរខ្ញុំថាមកពីណា ខ្ញុំបានរ៉ាយរ៉ាប់តាមដំណើររឿង ហើយខ្ញុំបានហុចនំគមឲ្យពួកគេម្នាក់មួយៗ។

ខ្លួនខ្ញុំភ័យបែកញើសដោកគិតថា តាយាយ បងប្រុស បងថា ប្អូនៗ មិនដឹងយ៉ាងម៉េចទេ។ បើសិនគេទាំងអស់គ្នាមានគ្រោះថ្នាក់ ខ្ញុំត្រូវរស់នៅយ៉ាងណា? ពិតជាការគិតគ្មានកោះត្រើយ។

ថ្ងៃនេះជាថ្ងៃចូលឆ្នាំ ហេតុអ្វីបានជាក្លាយជាយ៉ាងនេះ? ឱ! ទេវតាអើយ ប្រជានុរាស្ត្រពិតជាមិនដែលមានសេចក្ដីសុខទេ ព្រះជាម្ចាស់ជួយថែរក្សាផង។ ខ្ញុំសម្លឹងទៅរកទួលស្វាំងលើកដៃបន់ស្រន់អស់ហើយ សូមឲ្យគ្រាប់កាំភ្លើងឆាប់រលត់ទៅ។

មួយស្របក់ក្រោយមក សំឡេងគ្រាប់កាំភ្លើងបានថមថយ ប៉ុន្តែនៅឮសូររប៉េះរប៉ោះម្ដងៗ។ អ្នកភូមិទាំងនោះបានកេះខ្ញុំហើយនិយាយថា "ម៉ោះក្មួយយើងទៅពួននៅឯដំបូកនោះវិញ ឲ្យឆ្ងាយពីផ្លូវខ្លាចក្រែងក្រុមណាមួយបាក់ទ័ពរួចរត់ចេញមកតាមផ្លូវទំនប់នេះ។ ដូច្នេះយើងត្រូវគេចកុំឲ្យពួកគេឃើញ។"

បន្ទាប់ពីស្ងាត់គ្រាប់កាំភ្លើង ពួកយើងនាំគ្នាដើរតាមភ្លឺស្រែសំដៅទៅភូមិកាត់អូរតាសឹង ដោយចូលពីចំហៀងវិញ ម្នាក់ៗហាក់ដូចជានៅភ័យខ្លាចនៅឡើយ ដើរបណ្ដើរ មើលមុខគ្នាបណ្ដើរ។

# ដែកកេះសម្លីគ អាល័យចង្ក្រានផ្ទះ

មិនយូរប៉ុន្មានពួកយើងបានដើរមកដល់ផ្លូវរទេះខាងជើងឆៀងខាងលិចភូមិ។ មើលទៅដូចជាមិនមានអ្វីគួរឲ្យព្រួយបារម្ភ យើងបានបែកគ្នាសំដៅទៅរកផ្ទះ រៀងៗខ្លួន។

នៅតាមផ្លូវដូចជាមិនមានអ្វីកើតឡើងទេ ខ្ញុំក៏ស្ទុះចូលក្នុងផ្ទះរួចឡើងទៅលើមិនឃើញបងស្រី ប្អូនវ៉ា តាយាយសោះ។ ឃើញតែអីវ៉ាន់នៅរាយប៉ាយពេញផ្ទះ។ ខ្ញុំចាប់ផ្តើមភ័យត្រជាក់ចុងដៃចុងជើង មួយប៉ប្រិចភ្នែកខ្ញុំឃើញយាយចេញពីកន្លៀតទូហើយខ្ញុំសួរគាត់ថា "យាយមកពួនកន្លែងនេះធ្វើអ្វី?" យាយតបថា "ចៅដឹងទេអម្បាញ់មិញ កងទ័ពយៀកណាមបានចូលមកក្នុងភូមិរបស់យើងប្រហែលសាមសែសិបនាក់ ដោយបាញ់កាំភ្លើងឡើងលើ ហើយពួកគេឡើងមកលើផ្ទះ រើកកាយមិនដឹងរកអ្វីទេ។"

ពេលនោះយាយស្រក់ទឹកភ្នែកនិយាយទាំងអួលដើមក៖ "ពួកគេបានប្រមូលអស់រលីងនំអន្សមដែលយាយដាក់ថ្វាយទេវតា និងដែកកេះប្រើថ្មីដែលអ៊ុំទូចរបស់ចៅឯងទើបតែយកអង្គរដូរទុកគ្រាន់ឲ្យយាយបង្កាត់ភ្លើងដាំបាយ ព្រោះប្រើដែកប៊ុកពិបាកបង្កាត់ភ្លើងណាស់"។ ខ្ញុំក៏មានការសោកស្តាយដែរ។ គាត់បន្តទៀតថា៖ "អម្បាញ់មិញ យាយស្មានតែពួកគេឡើងមកផ្ទះទៀត ទើបយាយរត់ទៅពួននៅកន្លៀតទូនោះ តាមពិតគឺចៅឯងសោះ"។

"ចុះ ស្អីគេនៅក្នុងថ្នក់ក្រមានោះ" គាត់សួរមកខ្ញុំ ខ្ញុំតបថា "នឹងហើយ ខ្ញុំភ្លេចប្រាប់យាយ នេះអន្សមនិងនំគមដែលអ៊ំៗនិងពូមីងបានផ្ញើមកឲ្យយាយតា និងបងប្រុស ស្រី ប្អូនវ៉ា។" គាត់បន្តទៀតថា "តើពួកគេសុខសប្បាយទេ ខ្ញុំបន្តថា សុខសប្បាយទាំងអស់គ្នាទេ"។ បញ្ចប់វាចាភ្លាម ខ្ញុំក៏សួរទៅយាយថា "ចុះ តា បងដាបងណាត និងប្អូនវ៉ា ទៅណាអស់ហើយ?" គាត់តបមកថា "តារបស់ចៅឯងទៅលេងអ៊ុំទូចឯងនៅ ឯភូមិព្រៃក្រ ឡាញ់តូចតាំងពីព្រលឹមម៉្លេះ ចំណែកចិន្តា ចៅណាត និងចៅវ៉ា ទៅលេងនៅឯខាងកើតភូមិ"។



ទិដ្ឋភាពតំណាង៖ កងទ័ពវៀតណាមបានចូលមកផ្ទះខ្ញុំចំពេលចូលឆ្នាំខ្មែរ និងដៃឈោងយកដែកកេះ។ (ឡុង វង្សសមិទ្ធ/ សៀវភៅ ទួលពិឃាដ)

# វិប្បដិសារីច្រំដែល

ពេលនោះ ខ្ញុំទម្លាក់ថ្នក់អន្សម នៅលើរនាបឫស្សី ហើយដើរសំដៅទៅខាងកើតភូមិ។

មកដល់ផ្លូវកណ្ដាលភូមិ ខ្ញុំឃើញអ្នកភូមិ ប្អូនដប់អ្នករត់ស្រចុះស្រឡើង។ រំពេចនោះដែរ ខ្ញុំឃើញធំតែមរត់ត្រហេបត្រហបតាមផ្លូវសំដៅទៅទំនប់បឹង មានទាំងក្រមាជូតទឹកភ្នែក។ ខ្ញុំក៏រត់តាមគាត់មកដល់ដើមទំនប់បឹង ស្រាប់តែឃើញទាហានវៀតណាមពីរនាក់ក្រៀកស្មាបងណាតជាប់ម្ខាងម្នាក់ ហើយនិយាយជាភាសាវៀតណាម ដែលខ្ញុំស្ដាប់បានតែពាក្យថា "បុល ប៊ិត បុល ប៊ិតឌីៗ"។ តាមពិតពួកគេចង់និយាយថា "ប៉ុល ពត តែមិនច្បាស់"។

ខ្ញុំស្រឡាំងកាំងស្ទេកមុខ។ បងណាត ខំងាកមកក្រោយ ឃើញធំតែម និងអ្នកភូមិប្អូនដប់នាក់រត់តាមពីក្រោយ។ ធំតែមនិយាយលើកដៃសំពះអង្វរដល់ទាហានទាំងនោះ លាយទឹកភ្នែកដោយគាត់ពោលថា "មិនមែនប៉ុល ពត ទេ គឺជាកូនខ្ញុំធ្វើស្រែចម្ការនៅភូមិនេះយូរហើយ" ។ តែពួកគេនៅតែក្រៀកបងណាតជាប់ ហើយបណ្ដើរទៅមុខឮតែសំឡេងខុសៗ និងបុល ប៊ិតៗ។

បងណាត ស្លៀកក្រមា និងពាក់អាវខ្មៅ ដែលសល់ពីកាលនៅធ្វើកងចល័តងាកមើលមកក្រោយដែលមានតែទឹកភ្នែកហូររហាម។ ទោះជាមានការអង្វរករពីធំតែម និងអ្នកភូមិយ៉ាងណាក៏ដោយ ក៏ពួកទាហានទាំងនោះមិនព្រមនៅតែក្រៀកបណ្ដើរទៅមុខដោយស្ដាប់គ្នាមិនបានឮតែពាក្យ ខុសៗ ឌីៗ ប៉ុល ប៊ិត។

មិនយូរប៉ុន្មានខ្ញុំឃើញបងស្រី និងប្អូនរ៉ា រត់ត្រហេបត្រហបលាយឡំទឹកភ្នែក មានការតក់ស្លុត និងមានពូឌី គឺជាអ្នកភូមិផង គេហៅគាត់ថា ឌីច្រេន មកជាមួយដែលគាត់អាចនិយាយភាសាវៀតណាមបាន។

បន្ទាប់មកពូ ឌីច្រេន និយាយជាមួយពួកទាហានទាំងនោះជាភាសាវៀតណាម ហើយបាននិយាយឆ្លើយឆ្លងគ្នាទៅវិញទៅមក ដោយពូ ឌីច្រេន បានបកប្រែប្រាប់ទៅពួកគេ រួចទាហានវៀតណាមទាំងនោះក៏លែងក្រៀកបងណាត។

ពូ ឌីច្រេន បាននិយាយប្រាប់ធំតែមថា មូលហេតុដែលគេចាប់ក្មួយណាត ព្រោះដោយសារតែក្មួយណាតគេចចេញពីពួកគេ ហើយម្យ៉ាងទៀតក្មួយណាតពាក់អាវខ្មៅ ពួកគេគិតថាជាពួក ប៉ុល ពត ។

បន្ទាប់ពីនោះមកពួកគេអនុញ្ញាតឲ្យបងណាតត្រឡប់មកផ្ទះវិញ ហើយធំតែមលើកដៃសំពះអរគុណដល់ពួកគេ។ ពួកគេញញឹមងក់ក្បាលជាសញ្ញាថាមិនអីទេហើយពួកទាហានទាំងនោះបានចេញដំណើរតាមទំនប់បឹងទៅ។ ធំតែម និងអ្នកភូមិគក់ទ្រូងភ័យគ្រប់គ្នាដោយអស់ព្រលឹងព្រលះពីក្នុងខ្លួន។

ពេលនោះបងណាត បាននិយាយរ៉ាយរ៉ាប់ថា នៅពេលទាហានទាំងនោះបានចូលមកក្នុងភូមិ ហើយបាញ់កាំភ្លើងទៅលើ គាត់ក៏សម្ងំក្នុងផ្ទះធំតែម។ បន្ទាប់ពីស្ងាត់គ្រាប់កាំភ្លើង គាត់គិតថាពួកគេប្រហែលជាចេញពីភូមិអស់ហើយ។ គាត់មកអង្គុយលេងនៅមាត់ទ្វារផ្ទះបានបន្តិច ស្រាប់តែឃើញទាហានទាំងនោះដើរតាមផ្លូវ គាត់ស្ទុះចូលទៅក្នុងផ្ទះវិញដោយទាញទ្វារបិទ ស្របពេលនោះពួកគេឃើញគាត់ក៏រត់ឡើងមកចាប់គាត់ក្រៀកបណ្ដើរចុះក្រោមតែម្ដង ដោយស្រែកថា "ប៉ុលប៊ិតៗ"។ គាត់ខំប្រកែកដោយគ្រវីក្បាលថាមិនមែនទេៗ តែនិយាយគ្នាស្ដាប់មិនបានសោះ ហើយអ្នកភូមិនិងធំតែមនិយាយគ្នាថា បើសិនជាយើងអង្គុយធម្មតាប្រហែលជាមិនអីទេ មកពីយើងគេចពីពួកគេ។ ពួកគេគិតថា ជាពួក ប៉ុល ពត បានជាចាប់យ៉ាងដូច្នេះ។

ខ្ញុំដឹងថានៅពេលនោះឲ្យតែយើងស្លៀកពាក់ខោ ឬអាវខ្មៅ ហើយជួបពួកទាហានវៀតណាម គេគិតថាពួក ប៉ុល ពត ហើយនឹងចាប់យើងបញ្ជូនមកជំនាញការស្រុកដើម្បីសួរនាំ។

ដើរមកដល់ផ្ទះ ធំតែម បាននិយាយទៅកាន់ពូ ឌីច្រេន ថាអរគុណ ហើយប្អូន បើសិនជាមិនមានប្អូនឌីឯងមិនដឹងជាយើងគិតដូចម្ដេចទេ រួចក៏បែកគ្នារៀងៗខ្លួនចូលផ្ទះ។

ខ្ញុំ ធំតែម បងណាត បងជា ប្អូនរ៉ា នៅផ្ទះធំតែមមួយស្របក់។ ពេលនោះធំតែម នាំបងណាតមកក្បែរពាងទឹក ហើយប្រាប់ថាកូនមកអង្គុយក្បែរពាងទឹកនេះមក ម្ដាយស្រោចទឹកឲ្យរំដោះគ្រោះហ៍ចេញ បន្ទាប់មកយើងទាំងបួននាក់បានដើរមកផ្ទះវិញ។

តាមផ្លូវខ្ញុំមើលទៅមុខបងប្រុស បងស្រី ប្អូន អារម្មណ៍ក្រៀមក្រំ សោកស្ដាយនៃវិប្បដិសារីដេរស្ដីគ្មានពេលល្ហែ ថាសង្ឃឹមនឹងជីវិតថ្មីរីកស្រស់

**ឡុង ឧត្យសមិទ្ធ**

**(តនៅលេខក្រោយ)**

រូបក្របមុខ៖

កងកុមារចាប់កណ្ដូរនៅតាមវាលស្រែនៅក្នុងរបបខ្មែរក្រហមៗ

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

កងយុវជនកំពុងធាក់រហាត់ទឹកនៅក្នុងរបបខ្មែរក្រហមៗ

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 12200

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 278, February 2023 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.